ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 07-May-2015, 16:00
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៥**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី២៧៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៊ាង

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIPS)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក ឌេល លីសាក់ *(Mr.Dale LYSAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកកែន
*(Mr. Arthur VERCKEN)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក វ៉េន ពៅ

លោក ហុង គឹមសួន

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក អាកទួរ វែកគែន | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក ខៀវ សំផន | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៥០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការដាក់បង្ហាញឯកសារគន្លឹះដោយក្រុមមេធាវីការពារក្តី ពាក់ព័ន្ធជាមួយនឹងអង្គហេតុសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ៊ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគីដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន លើកលែងតែលោក សុន អរុណ មេធាវីជាតិការពារក្តីឲ្យលោក នួន ជា អវត្តមាន ដោយមូលហេតុសុខភាព។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សូមអរគុណលោកប្រធាន។

[០៩:០៣:០០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៨ ខែមេសា ឆ្ន២០១៥ ដែលបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៥។ មេធាវីការពារក្តីរបស់ខ្លួន បានប្រាប់អំពី

ផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈឈឺចង្កេះរ៉ាំរ៉ៃ មានអារម្មណ៍វិលមុខពេលអង្គុយយូរ និងផ្ដល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

[០៩:០៥:២២]

ផ្អែកលើដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះក្នុងអំឡុងពេលនៃដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី ដែលដំបូងនេះ គឺមេធាវីការពារក្ដី នួន ជា ឡើងបង្ហាញនូវឯកសារគន្លឹះពាក់ព័ន្ធជាមួយនឹងអង្គហេតុសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម សូមជម្រាបសួរលោកមេធាវី និងភាគីទាំងអស់។ បទបង្ហាញរបស់ខ្ញុំនៅថ្ងៃនេះត្រូវបែងចែកជាបីផ្នែក។ ផ្នែកទី១ គឺទាក់ទងទៅនឹងឯកសារពាក់ព័ន្ធទៅនឹងក្រាំងតាចាន់។ ឯកសារទី២ គឺពាក់ព័ន្ធទៅនឹងស្ថានភាពការងារ និងស្ថានភាពរស់នៅក្នុងស្រុកត្រាំកក់ និងឯកសារ -- និងប្រភេទទី៣ គឺទាក់ទងទៅនឹងការប្រព្រឹត្តចំពោះក្រុមគោលដៅ។

នៅព្រឹកនេះ ខ្ញុំនឹងបង្ហាញឯកសារទាំងអស់ចំនួន៣០ ដែលវាតិចជាងបញ្ជីដែលយើងបានចែកផ្សាយកាលពីមុននេះបន្តិច ដោយសារតែយើងបានដកចេញឯកសារមួយចំនួន។ ជាដំបូង ខ្ញុំសូមធ្វើបទបង្ហាញទាក់ទងទៅនឹងឯកសាររបស់ក្រាំងតាចាន់ គឺមាន១៣៨ឯកសារ នៅលើសំណុំរឿង ខ្ញុំ -- គឺនៅក្នុងដូចដែលមានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធរបស់ អូ.ស៊ី.ភី ដែលហៅថាកំណត់ត្រាស្រុកត្រាំកក់ ដែលឯកសារទាំងអស់នេះ គឺជាឯកសារពាក់ព័ន្ធទៅនឹងសកម្មភាពនៅក្នុងស្រុកត្រាំកក់ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

[០៩:០៦:៥០]

ច្បាស់ណាស់ថាឯកសារទាំងអស់គ្នានេះ គឺជាភស្តុតាងគន្លឹះរបស់ខាងព្រះរាជអាជ្ញានៅក្នុងផ្នែកនៃការជំនុំជម្រះនេះ។ ប៉ុន្តែមានតែឯកសារចំនួនបីក្នុងចំណោមឯកសារ១៣៨ប៉ុណ្ណោះ ដែលយើងអាចរកឃើញឯកសារច្បាស់ដើម ហើយទោះបីជាបែបនេះក្តីក៏ឯកសារច្បាប់ដើមទាំងអស់នេះមិនមាននៅក្នុងសំណុំរឿងទាំងអស់នោះរបស់យើងឡើយ។ ឯកសារទាំងអស់នេះ គឺជាឯកសារថតចម្លង ចំណែកឯកសារច្បាប់ដើម គឺយើងមិនដឹងថានៅទីណានោះឡើយ។ ដូច្នេះគឺថាវាមិនអាចនោះឡើយដែលយើងអាចធ្វើការបញ្ជាក់ទៅលើអ្វីដែល ពេជ្រ ដឹម បានអះអាងដែលថានឹងមានការសម្លាប់នៅលើឯកសារដែលសរសេរជាប៊ិចពណ៌ក្រហម។ យើងមិនអាចពិនិត្យមើលអំពីលក្ខណៈនៃឯកសារជាច្រើនដែលមានលេខ E3 ដែលហាក់ដូចជាការប្រមូលផ្តុំនៃឯកសារផ្សេងៗគ្នាជាច្រើនរួមបញ្ចូលទាំងឯកសារឆ្លើយតបទៅវិញទៅមក។

នៅក្នុងនីតិរដ្ឋ គឺថាបញ្ហាទាំងអស់នេះគឺជាបញ្ហាយ៉ាងសំខាន់ ជាពិសេសដែលទាក់ទងទៅនឹងឱនភាពដែលខ្ញុំនឹងពិភាក្សានៅពេលបន្តិចទៀតនេះ ដែលថាឯកសារមួយចំនួនអាចត្រូវបានគេក្លែងក្លាយដែលវាហាក់ដូចជាដូចគ្នាទៅនឹងអ្វីដែលគេរៀបរាប់អំពីហេតុការណ៍នៅក្រាំងតាចាន់។ ដូច្នេះខ្ញុំនឹងដាក់នូវសំណើផ្លូវការឲ្យមានការស៊ើបអង្កេតទៅលើកំណត់ត្រាមួយចំនួនរបស់កំណត់ត្រាត្រាំកក់។ ឥឡូវនេះ ខ្ញុំសូមបង្ហាញនូវឯកសារគឺជាឯកសារ ដែលផ្តល់ព័ត៌មានអំពីផ្នែកនៃកំណត់ត្រាដែលគេហៅថាកំណត់ត្រាស្រុកត្រាំកក់។ ឯកសារទាំងអស់នេះ គឺE3/188 ដែលជាកំណត់ហេតុស្តាប់ចម្លើយរបស់ ឆាំង យុ ដែលជាប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជាចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៩។ ERN ដែលពាក់ព័ន្ធគឺភាសាអង់គ្លេសមានលេខ 00342450 ដល់ 5, ខ្មែរមានលេខ 00334755 ដល់ 61 និងបារាំងមានលេខ 00485435 ដល់ 40។

[០៩:០៩:០៧]

នៅក្នុងឯកសារនេះ ឆាំង យុ បានផ្តល់នូវព័ត៌មានបន្ថែម ហើយនិងកំណត់នូវប្រភពសំខាន់ៗ មួយចំនួនពាក់ព័ន្ធនឹងផ្នែកនៃកំណត់ត្រាស្រុកត្រាំកក់ ហើយនិងខ្សែរយៈនៃការឃុំខ្លួន។ គាត់បានកត់សម្គាល់ថាឯកសារទាំងអស់នេះត្រូវបានគេរកឃើញនៅពេលវេលាខុសៗគ្នា ហើយទទួលបានពីប្រភពខុសៗគ្នា។ គាត់បានពន្យល់បន្ថែមថាឯកសារច្បាប់ដើមពាក់ព័ន្ធទៅក្រាំងតាចាន់ត្រូវបានបាត់បង់ ប៉ុន្តែវាមិនច្បាស់លាស់ថាតើឯកសារនោះបាត់បង់ដោយរបៀបណា បាត់បង់នៅពេលណា ហើយនិងតើបាត់បង់នៅទីកន្លែងណា។ ប៉ុន្តែគាត់បានពន្យល់ថា លោក ស៊ូ ភិរិន្ទ ដែលបច្ចុប្បន្ននេះជារដ្ឋលេខាធិការគណៈរដ្ឋមន្ត្រី ទីស្តីការគណៈរដ្ឋមន្ត្រី ដែលយើងបានស្នើសុំឲ្យកោះហៅមកធ្វើជាសាក្សីបន្ថែមនៅក្នុងផ្នែកនៃការជំនុំជម្រះនេះ។ គឺថាៗគាត់បានទទួលឯកសារទាំងអស់នេះពីរណសិរ្សស្រុក ហើយផ្តល់ឯកសារទាំងអស់នេះទៅឲ្យ ប៉ែន យៀវនិន តែម្នាក់តែប៉ុណ្ណោះ។ យោងតាម ឆាំង យុ, ប៉ែន យៀវនិន និយាយថាគាត់បានប្រគល់ឯកសារទាំងអស់នេះត្រឡប់ទៅវិញ ហើយឯកសារទាំងអស់នេះនៅក្នុងទូលស្លែង ដែលតាមពិតទៅឯកសារនេះមិនមាននៅក្នុងទូលស្លែងនោះឡើយ។ ប៉ុន្តែផ្ទុយទៅវិញ ស៊ូ ភិរិន្ទ និយាយថា ប៉ែន យៀវនិន មិនបានប្រគល់ឯកសារច្បាប់ដើមឲ្យមកវិញនោះឡើយ។ ឆាំង យុ ក៏ផ្តល់ព័ត៌មានពាក់ព័ន្ធទៅនឹងប្រភពនៃកំណត់ត្រាស្រុកត្រាំកក់។ ឧទាហរណ៍៖ គាត់បានបញ្ជាក់ផងដែរនៅក្នុងកំណត់ត្រារបស់គាត់ ដែលថានាយករដ្ឋមន្ត្រី ហ៊ុន សែន គឺជាប្រភពនៃឯកសារដែលចុះលេខឯកសារ D នៅក្នុងប្រព័ន្ធចុះលេខរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ យុ ឆាំង ក៏និយាយថា ប្រភពដទៃទៀតគឺមកពីស្រុកមកពីខេត្តតាកែវ។ ហើយឯកសារខ្លះទៀតត្រូវបានគេយកចេញពីមន្ទីររណសិរ្សស្រុក ប៉ុន្តែវាមិនច្បាស់ថាតើរណសិរ្សហ្នឹងទទួលឯកសារហ្នឹងមកពីណា។ គាត់ក៏បាននិយាយផងដែរថា រណសិរ្សស្រុកបានប្រមូលផ្តុំឯកសារទាំងអស់នេះមកពីថ្នាក់ភូមិនិងថ្នាក់ឃុំ ប៉ុន្តែរណសិរ្សស្រុកមិនបានប្រមូលផ្តុំឯកសារច្បាប់ដើមមកក្រាំងតាចាន់នោះឡើយ។

[០៩:១១:៤២]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំស្នើសុំឲ្យមេធាវីនៅពេលដែលគាត់ធ្វើការយោង ដូចដែលខ្ញុំធ្វើ

គឺឲ្យគាត់លើកជា ERN ឲ្យច្បាស់លាស់ផង។ គាត់បង្ហាញអំពីលក្ខណៈរបស់ឯកសារជាជាងបង្ហាញទៅលើអ្វីដែលបានបញ្ជាក់។ ដូច្នេះគឺថាដើម្បីឲ្យនីតិវិធីនេះវាមានភាពអាចជឿជាក់បាន ដូច្នេះគាត់ត្រូវបញ្ជាក់អំពីថាតើគាត់ដកស្រង់មកពីណា ដូច្នេះដើម្បីកុំឲ្យយើងធ្វើការកំណត់ខុសលក្ខណៈ។

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំអាចធ្វើដូច្នេះបានលោកប្រធាន។ ខ្ញុំគ្រាន់តែចង់ឲ្យមាន -- ខ្ញុំគិតថាវាជាលក្ខណៈស្មុគស្មាញ ប៉ុន្តែឥឡូវនេះខ្ញុំនឹងធ្វើ។ ចង់ឲ្យខ្ញុំត្រឡប់ឡើងវិញ ហើយរៀបរាប់នូវឯកសារយោង ឬក៏លេខយោង ឬមួយក៏ខ្ញុំបន្តទៅមុខទៀត? ខ្ញុំនឹងបន្តទៀតដូច្នេះ។--

**ប្រធានអង្គជំនុំ៖**

លោកមេធាវីត្រឡប់ក្រោយវិញ ហើយរៀបរយឲ្យបានច្បាស់លាស់ ដោយមានយោងនូវលេខឯកសារ លេខទំព័រ ERN ឲ្យបានច្បាស់លាស់នូវអ្វីដែលលោកបានលើកឡើង ដើម្បីងាយភាគីទាំងអស់បានពិនិត្យតាមដាន រួមទាំងអង្គជំនុំជម្រះផង ដើម្បីពិនិត្យថាតើវាមានមូលដ្ឋានអ្វីខ្លះដែលលោកបានលើកឡើងក្នុងការបង្ហាញឯកសារគន្លឹះនេះ ជាប្រយោជន៍សម្រាប់ធ្វើការពិចារណានៅថ្ងៃខាងមុខទៀត។

[០៩:១៣:២៧]

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំនឹងធ្វើដូច្នេះលោកប្រធាន។ ដូច្នេះខ្ញុំសូមចាប់ផ្តើមនូវផ្នែកទី២ នៃឯកសារនេះដែល យុ ឆាំង ផ្តល់ព័ត៌មានទាក់ទងទៅនឹងរបាយការណ៍ -- កំណត់ត្រាស្រុកត្រាំកក់។ ទី១ គឺថាខ្ញុំសូមអានឡើងវិញ គឺថានាយករដ្ឋមន្ត្រី ហ៊ុន សែន គឺជាប្រភពនៃឯកសារដែលចុះលេខឯកសារ D នៅក្នុងប្រព័ន្ធចុះលេខរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ អង់គ្លេសមានលេខ 00342452, ខ្មែរមានលេខ 00334745-7, បារាំងមានលេខ 00485437។ គាត់ក៏បាននិយាយផងដែរថា ប្រភពដទៃទៀតមកពីខេត្តតាកែវ គឺអង់គ្លេសមានលេខ 00342455, ខ្មែរមានលេខ 00334746-0, បារាំងមានលេខ 00485437។ គាត់ក៏បាននិយាយថា ឯកសារខ្លះទៀតយកមកពីមន្ទីរណសិរ្សស្រុក ប៉ុន្តែវាមិនច្បាស់ថាតើរណសិរ្សស្រុកទទួលឯកសារហ្នឹងមកពីណា។ អង់គ្លេសមានលេខ 00342454, ខ្មែរមានលេខ 00334745-9, បារាំងមានលេខ 00485439។ រណសិរ្សស្រុកប្រមូលឯកសារមកពីថ្នាក់ភូមិ និងថ្នាក់ឃុំ ប៉ុន្តែពួកគេមិនប្រមូលឯកសារច្បាប់ដើមពីក្រាំងតាចាន់នោះឡើយ។ ហើយជាចុងក្រោយ នៅក្នុងផ្នែកនេះគឺទាក់ទងទៅនឹងចម្លើយរបស់ យុ ឆាំង បន្ថែមពីលើនេះ នៅពេលដែលធ្វើការស្រាវជ្រាវនៅក្នុង ស-២១ ឯកសារមួយ

ចំនួនត្រូវបានគេរកឃើញនៅក្នុងទូឈើ អង់គ្លេសមានលេខ 00342453, ខ្មែរមានលេខ 00334745-8 និងបារាំងមានលេខ 00485438។ ហើយឯកសារពាក់ព័ន្ធមួយចំនួនដទៃទៀត ត្រូវបានរកឃើញនៅពេលក្រោយ។ ប៉ុន្តែគេផ្តល់លេខនៅក្នុងលំដាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា អង់គ្លេសមានលេខ 00342452, ខ្មែរមានលេខ 00334745-7 និងបារាំងមានលេខ 00485437។

[០៩:១៦:០៧]

ឥឡូវនេះ ខ្ញុំសូមបញ្ចប់ផ្នែកទី១នៃឯកសារដែលខ្ញុំត្រូវបង្ហាញនៅព្រឹកនេះ។ ហើយឥឡូវនេះ ប្រសិនបើយើង ទោះបីថាយើងមិនគិតអំពីការព្រួយបារម្ភថា យើងពឹងផ្អែកខ្លាំងទៅលើកំណត់ស្រុកត្រាំកក់ ហើយពិចារណាទៅលើឯកសារតែទៅលើខ្លឹមសារក៏ដោយ ក៏ឯកសារទាំងអស់នេះ មិនបានរៀបរាប់អំពីរូបភាពដ៏កាចសាហាវជាទូទៅ នៅក្នុងរបបដែលព្រះរាជអាជ្ញាធ្វើឲ្យយើងជឿជាក់ឡើយ។ ឥឡូវនេះ ខ្ញុំសូមបង្ហាញឯកសារមួយចំនួន ដែលឯកសារមួយចំនួនខាងព្រះរាជអាជ្ញាបានបង្ហាញរួចទៅហើយ ដែលបង្ហាញអំពីទស្សនៈផ្សេងមួយនៃហេតុការណ៍ខ្លះដែលពាក់ព័ន្ធទៅនឹងក្រាំងតាចាន់។ យើងបានបែងចែកឯកសារទាំងអស់នេះទៅជាប្រាំប្រភេទ។ ប្រភេទទី១ គឺឯកសារដែលបង្ហាញថា មានការព្យាយាមជាច្រើនដងដើម្បីធ្វើការអប់រំកែប្រែប្រជាជន។ ឯកសារទាំងអស់នេះបង្ហាញថា មានការព្យាយាមច្រើនដងដើម្បីធ្វើការអប់រំប្រជាជនឲ្យផ្លាស់ប្តូរអាកប្បកិរិយានៅថ្នាក់ស្រុក នៅថ្នាក់ឃុំ មុនពេលបញ្ហាហ្នឹងត្រូវបានគេលើកឡើង ឬសឹងតែមិនមានការឡើងទាំងអស់។ ឥឡូវនេះ ខ្ញុំសូមបង្ហាញឧទាហរណ៍ចំនួនបួន។ ឯកសារទី១ បង្ហាញថា ទាហាន និងមន្ត្រីរដ្ឋការ លន់ នល់ ស្ថិតក្នុងចំណោមអ្នកដែលត្រូវគេធ្វើការអប់រំជាច្រើនដង។ ឯកសារ E3/4092 កាលពីម្សិលមិញ ព្រះរាជអាជ្ញាក៏បានបង្ហាញរួចទៅហើយដែរ។ ឯកសារនេះ មានចំណងជើងថា សៀវភៅកត់ត្រាអ្នកស៊ើបអង្កេតនៅក្រាំងតាចាន់ ហើយមានចម្លើយសារភាពរបស់មនុស្ស១០៧នាក់ រួមទាំងស្ត្រី បុរស យុវជន និងទាហាន លន់ នល់។ អង់គ្លេសមានលេខ ERN គឺ00834826 ដល់ 8, ខ្មែរមានលេខ 00271162 ដល់ 4 និងបារាំងមានលេខ 00721306។ ឯកសារនេះ រៀបរាប់នូវហេតុការណ៍ជាច្រើនដែលមនុស្សត្រូវបានគេអប់រំជាច្រើនដង នៅថ្នាក់ឃុំ។ ហើយវាក៏បានបង្ហាញថា តើការបញ្ជូនមនុស្សទៅមន្ទីរអប់រំ មិនមែនមានន័យថា ជាការស្លាប់នោះឡើយ ប៉ុន្តែមានន័យថា ប្រជាជនអាចត្រឡប់មកពីមន្ទីរអប់រំមកឃុំវិញ។ ជាពិសេសឯកសារ E3/4092 បានរៀបរាប់យ៉ាងហោចណាស់ ក៏មនុស្សពីរនាក់ដែលត្រូវបានគេអប់រំ ហើយដែលជាអតីតទាហាន លន់ នល់។

[០៩:១៩:០៦]

ទី១ គឺអង់គ្លេសមានលេខ 00834827, ខ្មែរមានលេខ 00271162 ដល់ 63, បារាំងមានលេខ 00721306។ គឺពាក់ព័ន្ធទៅនឹងអនុសេនីយ៍ឈ្មោះ ប៉ុក ប៊ុនលី។ ប៉ុក ប៊ុនលី គាត់ស្ថិតនៅក្នុងឃុំអង្គតាសោម បានប្រព្រឹត្ត ដែលបានលួចជាច្រើនដង ដែលជាហេតុផលធ្វើឲ្យតំណាងសហករណ៍ចាប់ខ្លួន ហើយបញ្ជូនគាត់ទៅមន្ទីរអប់រំជាច្រើនដង។ គង់ វ៉េត ជាព្រឹទ្ធបាលរបស់ លន់ នល់ ដែលរស់នៅក្នុងឃុំអង្គតាសោម គឺជាចោរដ៏ធំ គឺជាមេចោរដែលលួចដំឡូងប្រាំដង ដូងបីដង ហើយនិងពោតពីរដង ហើយជាអ្នកដែលតំណាងសហករណ៍អប់រំជាច្រើនដង ប៉ុន្តែនៅតែជំទាស់ដោយក្បាលរឹង។ គឺអង់គ្លេសមានលេខ 00834828, ខ្មែរមានលេខ 00271164, បារាំងមានលេខ 00721307 ដល់ 08។

ឯកសារបន្ត លោកប្រធាន គឺខ្ញុំចង់បង្ហាញអំពីប្រជាជនថ្មីដែលត្រូវទទួលការអប់រំច្រើនជាងម្តង។ ឯកសារ E3/4101 គឺជារបាយការណ៍មកពីក្រាំងតាចាន់ផ្ញើជូនមន្ទីរស្រុក ចុះថ្ងៃ០៧ មីនា ឆ្នាំ៧៧ ហើយចុះហត្ថលេខាដោយ អាន់។ អង់គ្លេសមានលេខ 00322124, ខ្មែរមានលេខ 00271034, បារាំងមានលេខ 00854216។ របាយការណ៍នេះបានរៀបរាប់អំពី គឹម វ៉ាន់នី ជាប្រជាជនថ្មីដែលត្រូវបានគេចាត់តាំងទៅកងយុវជននៅក្នុងឃុំស្រែរនោង។ គាត់លួចជាញឹកញាប់ដូចជា ដូង ដំឡូង ហើយឡើងដើមដូង ឡើងដើមត្នោត លួចផឹកទឹកដូង ទឹកត្នោតរបស់សហករណ៍។ ប្រធានកងបានអប់រំគាត់ជាច្រើនដង ប៉ុន្តែគាត់នៅតែលួច។ ហើយឯកសារមួយទៀតបានបង្ហាញថា ហោចណាស់ក៏មានមនុស្សប្រាំនាក់ រួមបញ្ចូលទាំងមន្ត្រីរដ្ឋការ និងទាហាន លន់ នល់ ប្រជាជនថ្មី និងចោរដែលលួចជាញឹកញាប់បានទទួលការអប់រំជាច្រើនដងដើម្បីកែប្រែអត្តចរិតរបស់គេ។

[០៩:២២:២២]

ឯកសារបន្ទាប់ដែលខ្ញុំលើកនេះគឺ E3/2424 គឺជាការប្រមូលផ្តុំរបាយការណ៍រវាងមន្ទីរឃុំ មន្ទីរស្រុក ហើយនិងក្រាំងតាចាន់ដែលហាក់ដូចជាធ្វើឡើងនៅក្នុងឆ្នាំ១៩៧៨។ អង់គ្លេសមានលេខ 00322217 ហើយ ERN បញ្ចប់នៅត្រង់ 20, 22 និង 25។ ខ្មែរ ERN មានលេខ 00270755 ហើយ ERN បញ្ចប់នៅត្រង់លេខ 59, 62, 63 និង 75។ បារាំងមានលេខ 00612215 ហើយ ERN បញ្ចប់នៅត្រង់លេខ 21 និង 23 ដល់ 24។ របាយការណ៍នេះគឺ E3/2424 នេះបានរៀបរាប់អំពីប្រវត្តិនៃការអប់រំឡើងវិញជាច្រើនដងទៅលើមនុស្សមួយចំនួន។ ឧទាហរណ៍៖ នៅក្នុងរបាយការណ៍ថ្ងៃ១៨ សីហា ៧៨ មកពី ឆេង នៅក្នុងឃុំអង្គតាសោមជូនសមមិត្តបងជាទីគោរពរបស់ស្រុក១០៥ បានរៀបរាប់អំពី

គង់ វ៉េត ដែលជាអតីតទាហានដែលមិនដឹងឋានន្តរស័ក្តិគឺជាមេចោរ។ គាត់ត្រូវបានគេអប់រំជាច្រើនដង ដោយក្រុម ដោយកង ហើយនិងដោយកិច្ចប្រជុំសមូហភាពក្នុងរយៈពេល ៣ឆ្នាំកន្លងមកហើយ។ ប៉ុន្តែដោយសារតែការអប់រំហ្នឹង វាមិនអាច ដូច្នេះហើយទើបយើងចាំបាច់ត្រូវអប់រំគាត់ដោយវិធីសាស្ត្រក្តៅ។ អង់គ្លេសមានលេខ 00322220, ខ្មែរមានលេខ 00270755, បារាំងមានលេខ 00612219។ ហើយឯកសារដដែលនេះគឺ យើងឃើញអំពីលិខិតចុះថ្ងៃទី០៨ កក្កដា មកពី ប៊ុន ហើយនិង យ៉ាត់ ផ្ញើចេញពីទីកន្លែងដែលមិនដឹង ជូនចំពោះបក្សមូលដ្ឋានជាទីគោរព ពាក់ព័ន្ធទៅនឹងឈ្មោះ នី ជាវេជ្ជបណ្ឌិតខាងវះកាត់មកពីទីក្រុងភ្នំពេញ ដែលបានប្រព្រឹត្តអំពើថោកទាប ហើយនិងលួចជាច្រើនដង ហើយគាត់ត្រូវបានគេអប់រំជាច្រើនដង ប៉ុន្តែយ៉ាងណាក៏ដោយនៅតែរំលោភបំពានទៅលើមាគ៌ាបក្ស។

[០៩:២៥:០២]

ឯកសារមានលេខ ERN 0032222 (ស៊ីក), ខ្មែរមានលេខ 00270759 និងបារាំងមានលេខ 00612219។ នៅក្នុងឯកសារ E3/2424 ដដែលគឺមានឯកសារមួយទៀតដែលកាលបរិច្ឆេទអ្នកផ្ញើនិងអ្នកទទួលគឺមិនដឹង ប៉ុន្តែបានរៀបរាប់អំពីព័ត៌មានពីរ ទាក់ទងទៅនឹងមនុស្សពីរនាក់បន្ថែមទៀត រស់នៅក្នុងអង្គតាសោម។ ទី១ គឺឈ្មោះ ប៉ុក ប៊ុនលី ជាប្រជាជនថ្មីអាយុ២៧ឆ្នាំ ដែលមានជាតិកំណើតវៀតណាម ដែលមានជំទាស់ជាច្រើនរួមបញ្ចូលទាំងការលួច ដែលគេអប់រំគាត់ជាច្រើនដង រហូតដល់ពេលដែលគេយកគាត់មកអប់រំនៅក្នុងមន្ទីរឈ្លបឃុំ។ ក៏ប៉ុន្តែរបាយការណ៍ហ្នឹងបានរៀបរាប់ថា ទោះបីថាគេអប់រំគាត់ក៏ដោយ ប៉ុន្តែគាត់នៅតែធ្វើអំពើដដែលៗ។ អង់គ្លេសមានលេខ 00322225, ខ្មែរមានលេខ 00270763 និងបារាំងមានលេខ 00612223 និង 00612224។ ឱម ចន្ថា ខ្ញុំសូមដកស្រង់៖ “ដែលធ្វើការងារក្នុងកងកម្លាំងខ្មាំង ហើយរស់នៅក្នុងតំបន់រំដោះរបស់ខ្មាំង បានលួច ហើយនិងញុះញង់ឲ្យមានការវាយ -- ឲ្យមានការប្រឆាំងបដិវត្តន៍។ បក្សយើងបានសម្រេចនាំគាត់មកមន្ទីរឈ្លបឃុំ ដើម្បីអប់រំម្តងរួចមកហើយ។ ប៉ុន្តែក្នុងពេលអប់រំ យុវជនរូបនេះបានរត់ចេញពីមន្ទីរចំនួនពីរដង ហើយក្រោយមកទៀតបក្សសម្រេចថា ត្រូវនាំគាត់មកមន្ទីរយុវជន។” ហើយដកស្រង់ថ្មី៖ “ទោះបីថាគេអប់រំគាត់ជាញឹកញាប់ជារៀងរាល់ថ្ងៃគាត់នៅតែលួច។” អង់គ្លេសមានលេខ 00322225, ខ្មែរមានលេខ 00270 762 និងបារាំងមានលេខ 00612223។ ហើយជាចុងក្រោយសម្រាប់ផ្នែកនេះគឺ ឯកសារ E3/2424 គឺឯកសារមកពី ឈឿន នៅស្រុកត្រាំកក់ ចុះថ្ងៃ២៧ កក្កដា ៧៨ ហើយផ្ញើជូនបងកម្មាភិបាលប៉ូលិសស្រុកជាទីស្រឡាញ់។ បានរៀបរាប់អំពី សួន ភី អាយុ២៥ឆ្នាំមកពីស្រុក១០៥ -- មកពីស្រុក១០៩ ក្នុង

ខេត្តតាកែវ ពូកែលួចរបស់សហករណ៍ ដែលកម្មាភិបាលយើងព្យាយាមអប់រំ ទោះបីជាតាមវិធីណាក៏ដោយ។ អង់គ្លេសមានលេខ 00322217, ខ្មែរ 00270775 និងបារាំងមានលេខ 00612215។

[០៩:២៨:១៨]

ឯកសារបន្តលោកប្រធានគឺ E3/2048 ឯកសារនេះក៏ត្រូវបានព្រះរាជអាជ្ញាបង្ហាញកាលពីម្សិលមិញ គឺជារបាយការណ៍ផ្ញើជូន អាន់ ដោយអ្នកផ្ញើដែលមិនដឹង ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំក៏មិនដឹង ដែលរៀបរាប់អំពីល្អបឃុំនាំអ្នកដែលធ្លាប់អប់រំពីមុនយកមកអប់រំបន្ថែម។ អង់គ្លេសមានលេខ 00276566, ខ្មែរមានលេខ 00079094, បារាំងមានលេខ 00611663។ របាយការណ៍នេះ គឺឯកសារ E3/2048 បានបង្ហាញអំពី កែវ ណេត ហើយនិង ច្រឹង ដែលទាំងអស់គ្នាមានឋានៈជាមន្ត្រី។ កែវ ណេត ញុះញង់ ច្រឹង ឲ្យរត់ ហើយឲ្យលួចរបស់ប្រជាជនជាញឹកញាប់ ដោយមិនមានការភ័យខ្លាច។ អ្នកសរសេររបាយការណ៍ក៏បានរៀបរាប់ផងដែរថា មូលដ្ឋានបានរៀបរាប់បានអប់រំអស់លទ្ធភាពរួចទៅហើយ។

ឯកសារទី៤ និងឯកសារចុងក្រោយដែលជាឧទាហរណ៍មួយទៀតនូវការព្យាយាមជាច្រើនដងដើម្បីអប់រំ ប្រជាជនដែលហាក់ដូចជាបានលួចសម្ភារៈពីឃុំ ក៏ដូចជាបំផ្លាញសម្ភារៈឃុំជាច្រើននោះ គឺឯកសារ E3/2107 ដែលកាលពីម្សិលមិញព្រះរាជអាជ្ញាក៏បានបង្ហាញផងដែរនោះ គឺជាសៀវភៅកំណត់ត្រាក្រាំងតាចាន់។ អង់គ្លេសមានលេខ 00290205, 2245 ដល់ 46 និង56, ខ្មែរមានលេខ 0068 -- 006805 (ស៊ីក), 00607480 និង 81, បារាំងមានលេខ 00655726, 39, 60 ដល់61, 68 និង69។ នៅក្នុងឯកសារ E3/2107 នេះគឺរៀបរាប់ថា ជូ សុវណ្ណ ដែលជាអតីតលោកសង្ឃរស់នៅក្នុងកន្លែងជាច្រើន រួមបញ្ចូលទាំងឃុំគុសបានលួច។ ខ្ញុំដកស្រង់ “ទឹកត្នោត ដូង ព្រមទាំងដំឡូងជាញឹកញាប់ រហូតដល់អង្គការចាំបាច់ត្រូវអប់រំ ហើយកសាងគាត់ជាច្រើនដង។” អង់គ្លេសមានលេខ 00290205, ខ្មែរ 00068050, បារាំងមានលេខ 00655726។ យើងក៏ឃើញបុគ្គលម្នាក់ឈ្មោះ កង សឿន ដែលសម្លាប់គោសហករណ៍ដោយប្រើប៊ុងតោ ហើយអង្គការបានអប់រំគាត់ម្តងរួចមកហើយ។ បុគ្គលដដែលនេះ គឺមិនបានលាងអង្ករ ហើយគាត់ធ្លាប់សម្លាប់មាន់ពីរបីដង ហើយយកទៅហូប។ អង់គ្លេសមានលេខ 00290222, ខ្មែរ 00068060, បារាំង 00655739។ ហើយក៏រៀបរាប់អំពីបុរសម្នាក់ឈ្មោះ ក្រូច ផា ដែលជាល្អបស្រុកដែលបានរំលោភនារីម្នាក់។ គាត់ប្រឆាំងជាមួយនឹងកងទ័ពយើងជាញឹកញាប់នៅទឹកសាប ហើយបានប្រព្រឹត្ត -- ហើយបានរំលោភបំពានលើការហូប ហើយខាងប្រធានកងបានអប់រំគាត់ជាញឹកញាប់។ ប៉ុន្តែគាត់មានទំនាស់បន្ទាប់ពីប្រធានបានអប់រំរបស់គាត់ ហើយរហូតដល់ប្រធាន

បានអប់រំគាត់រហូតដល់ថ្ងៃ០៩ មុនពេលដោះលែងគាត់។ អង់គ្លេសមានលេខ 00290245 ដល់ 6, ខ្មែរមានលេខ 00068074 និងបារាំងមានលេខ 00655760 ដល់ 61។

[០៩:៣២:៥៤]

ជា សុផល ដែលចូលទាហាន ឆ្នាំ៧៣ គឺជាសមាជិករបស់កងយុវជនឃុំគុស ហើយត្រូវបានគេរៀបរាប់ថាជាមេចោរ។ របាយការណ៍បានរៀបរាប់ថា តំណាងកងបានអប់រំគាត់ជាច្រើនដង ប៉ុន្តែវាមិនអាចកែប្រែគាត់បានឡើយ គឺអង់គ្លេសមានលេខ 00290256, ខ្មែរមានលេខ 00068080, បារាំងមានលេខ 00655768។

ជាចុងក្រោយ លោកប្រធាន គឺខ្ញុំរៀបរាប់អំពី ង៉ូវ គា មកពីជាងទង មកពីឃុំជាងទង ត្រូវបានរៀបរាប់ថា បានលួចធំ លួចអង្ករ លួចស្ករផែន ហើយមានទំនាស់ជាមួយចុងភៅ ហើយបានគ្រវែងអីវ៉ាន់នៅទៅលើរោងបាយ ហើយអង្គការបានអប់រំគាត់ជាច្រើនដង អំពីអាកប្បកិរិយានេះ។ ហើយរបាយការណ៍បានបន្តថា គាត់នៅតែលួចដដែលនេះ។ ឯកសារមានលេខ 00290256, ខ្មែរមានលេខ 00068081, បារាំងមានលេខ 00655769។

បាទ ឥឡូវនេះ ខ្ញុំនឹងចូលទៅប្រធានបទមួយផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងផ្ទៃក្នុងរបស់ក្រាំង-តាចាន់។ ឯកសារនេះ គឺនិយាយពាក់ព័ន្ធទៅនឹងការប្រព្រឹត្តចំពោះមនុស្សដែលបង្កជាបញ្ហា ដោយរាយ-ការណ៍ជូនអំពីបញ្ហានេះ និងអំពីអត្តចរិតមិនត្រឹមត្រូវនេះ ស្នើសុំសេចក្តីណែនាំ។ ឥឡូវនេះ ខ្ញុំសូមចាប់ផ្តើមជាមួយនឹងឯកសារដែលបានបង្ហាញពីម្សិលមិញ គឺឯកសារ E3/2453 ដែលសហព្រះរាជអាជ្ញាបានបង្ហាញពីម្សិលមិញ គឺជាកម្រងនៃរបាយការណ៍នៅក្នុងស្រុកត្រាំកក់ ជាពិសេសគឺពាក់ព័ន្ធនឹងរបាយការណ៍អង់គ្លេស ERN 00388577 ដល់ 80 ដល់ 84 និងដល់ 86។ ខ្មែរ 00270773 ដល់ 77 ដល់ 72 (ស៊ីក) ដល់ 84 ហើយនិងបារាំង 00611769 ដល់ 71 ដល់ 74 និងដល់ 75។ របាយការណ៍ទី១ ចុះថ្ងៃទី១៣ តុលា ១៩៧៧ ដែលសរសេរដោយ ឃុន មកពីឃុំស្រែរនោងជូនទៅបក្ស ដែលនិយាយសកម្មភាពរបស់ ហន ជាស្ត្រីមេម៉ាយនៅក្នុងឃុំស្រែរនោងដែលជាមេចោរ។ ឃុន បានស្នើសុំឲ្យសេចក្តីសម្រេចអំពីបក្សអំពីរបាយការណ៍នេះដែលមាននៅត្រង់ERNអង់គ្លេស 00388580, ខ្មែរ 00270777, បារាំង 00611771។

[០៩:៣៦:១៧]

របាយការណ៍មួយទៀតមកពីអង្គតាសោមជូនទៅស្រុកត្រាំកក់ ដែលមានព័ត៌មានលម្អិតពាក់ព័ន្ធ

នឹងមនុស្សពីរនាក់ និងស្នើសុំចង់ដឹងថា សូមដកស្រង់ "តើ -- អ្វីក៏ដោយដែលអង្គការអាចនឹងសម្រេចទៅបាន" គឺជា ERN អង់គ្លេស 00388577, ខ្មែរ 00270773, បារាំង 00611769។ របាយការណ៍ទី៣ គឺមកពីឈ្មោះ មៀ នៅឃុំញ៉ែងញ៉ងផ្ញើជូនទៅបក្សស្រុកដែលរបាយការណ៍នេះបញ្ចប់ទៅដោយ គឺ សូមដកស្រង់ "សូមជម្រាបជូនបក្ស ហើយនិងស្នើសុំសេចក្ដីសម្រេចអំពីបក្ស"។ ពាក់ព័ន្ធនឹងព័ត៌មានដែលបានផ្ញើនេះ ERN ជាភាសាអង់គ្លេស 00388584, ខ្មែរ 00270782 និងបារាំង 00611774។

ហើយជាចុងក្រោយ គឺរបាយការណ៍ទី៤ដែលមកពី មៀទ នៃឃុំញ៉ែងញ៉ង ពាក់ព័ន្ធនឹងមនុស្សបួននាក់ ឡូ, សួស, យន់ និង បាង ដែលចង់ -- សូមដកស្រង់ "កម្មោចបដិវត្តយើង" បញ្ចប់ការដកស្រង់។ របាយការណ៍នេះគឺបញ្ចប់ សូមដកស្រង់ "សូមអង្គការ -- ជម្រាបព័ត៌មានជូនអង្គការអំពីមនុស្សទាំងបួននាក់នេះ និងសូមបក្សសម្រេចទៅតាមនោះ" ERN ជាភាសាអង់គ្លេសគឺ 00388586ៗ, ខ្មែរ 00270784, បារាំង 00611775។

[០៩:៣៨:១៥]

ឯកសារបន្ទាប់មកទៀត ដូចដែលខ្ញុំបានបង្ហាញគឺឯកសារ E3/2048 ដែលជាកម្រងឯកសារដែលយើងខ្ញុំជឿជាក់ថាមានការពាក់ព័ន្ធនៅសវនាការត្រង់ផ្នែកនេះ។ ERN ជាភាសាអង់គ្លេស 0027 6562 ហើយនិងដល់ 64, ខ្មែរ 00079087 ដល់ 8 និងដល់ 91, ជាភាសាបារាំង 00611658 ដល់ 61។ នៅក្នុងឯកសារE3/2048នេះ ដំបូងគឺជាកំណត់ត្រាចុះថ្ងៃទី០៣ មេសា ១៩៧៧ មកពីឈ្មោះជន ឃុំពពេល ស្នើសុំ សូមដកស្រង់ "អង្គការធ្វើសេចក្ដីសម្រេច" បញ្ចប់ការដកស្រង់។ ទាក់ទងទៅនឹងប្រជាជនថ្មីមួយចំនួនរួមទាំង សូមដកស្រង់ "ថាតើត្រូវធ្វើ ឬត្រូវៗបញ្ជូនពួកគេឬក៏យ៉ាងណានោះ" សូមបញ្ចប់ការដកស្រង់។ ERN ភាសាអង់គ្លេស 00276562, ខ្មែរ 00079087 ដល់ 88, បារាំង 0061 1658។

ឯកសារមួយទៀតនៅក្នុងកម្រងឯកសារតែមួយ គឺជាកំណត់ត្រាមកពីឃុំសហករណ៍ -- លេខាសហករណ៍ឃុំតាភេម ឈ្មោះ ឃិត ផ្ញើជូនអង្គការពាក់ព័ន្ធទៅនឹងទាហានប្រាំមួយនាក់ ទាំងអស់នេះគឺថាពាក់ស័ក្តិ១ និងស័ក្តិ២ ដែល សូមដកស្រង់៖ "បានធ្វើសកម្មភាពជារៀងរាល់ថ្ងៃ"។ សូមដកស្រង់ "ហើយ*(ឮមិនច្បាស់)*អង្គការ"។ ដកស្រង់ "ចេញសេចក្ដីសម្រេចយ៉ាងណាក៏ដោយយើងខ្ញុំស្នើសុំសេចក្ដីណែនាំអំពីអង្គការ" សូមបិទការដកស្រង់។ ERN ជាភាសាអង់គ្លេស 00276564, ខ្មែរ 00079091, បារាំង 00611661។

ខ្ញុំសូមចូលទៅឯកសារមួយទៀត គឺឯកសារ E3/4105 របាយការណ៍នេះគឺមកពីសេនាជនឃុំត្រាំកក់ ឃុំ -- ពីឈ្លបឃុំត្រាំកក់ ហើយនិងផ្ញើជូនទៅអង្គការស្រុក ចុះថ្ងៃ១៩ មេសា ១៩៧៧។ ERN ភាសាអង់គ្លេស 0032135, ខ្មែរ 00270993, បារាំង 00856212។ របាយការណ៍នេះស្នើសុំសេចក្ដីណែនាំបន្ថែមពីអង្គការស្រុក១០៥ ក្រោយពីការចាប់ខ្លួនសមាជិកនៅក្នុងឃុំ និងបាន -- របាយការណ៍នេះនិយាយដូចតទៅ សូមដកស្រង់ "យើងខ្ញុំស្នើសុំអង្គការស្រុក ថាតើគួរត្រូវបញ្ជូនអ្នកទីនេះទៅទីណា ឬក៏ដោះស្រាយដោយរបៀបណា សូមផ្ដល់មតិ" បញ្ចប់ការដកស្រង់។

[០៩:៤១:២៥]

ឥឡូវខ្ញុំចូលទៅប្រភេទឯកសារមួយផ្សេងទៀត លោកប្រធានគឺពាក់ព័ន្ធទៅនឹងការប្រើប្រាស់វិធីក្ដៅក្នុងការសួរចម្លើយ។ ហើយផ្ទុយទៅនឹងរូបភាពរបស់សហព្រះរាជអាជ្ញាដែលបានបង្ហាញអំពីព្រឹត្តិ-ការណ៍នៅគុកក្រាំងតាចាន់ នៅក្នុងឯកសារដែលបញ្ជាក់ថា វិធីក្ដៅនៃការសួរចម្លើយមិនត្រូវបានតែងតែប្រើប្រាស់នោះទេ ហើយតាមពិតគឺប្រើប្រាស់ដោយកម្របំផុត។ ឯកសារនេះដំបូងគឺនិយាយយ៉ាងវែងដោយសហព្រះរាជអាជ្ញាកាលពីម្សិលមិញ គឺឯកសារ E3/4095 ជាសៀវភៅកំណត់ត្រាសួរចម្លើយដែលជាចម្លើយសារភាពលើកទី៥ "និងពួកអាក្បត់ ប៉ុល ពត, អៀង សារី" បញ្ចប់ការដកស្រង់។ ERN ជាភាសាអង់គ្លេស 00747287 ដល់ 79, ខ្មែរ 00271124 និងបារាំង 00721252 ដល់61។

លោកប្រធានសៀវភៅកំណត់ត្រានេះគឺជាឯកសារមួយដ៏វែង ពាក់ព័ន្ធទៅនឹងព័ត៌មានទាក់ទងទៅនឹងការសួរចម្លើយអ្នកទោសប្រហែលជា១០៥នាក់នៅឯគុកក្រាំងតាចាន់ រួមទាំងចំនួនទាហាន លន់ នល់ ដ៏ច្រើន ដូចដែលសហព្រះរាជអាជ្ញាបានបង្ហាញលម្អិតកាលពីម្សិលមិញ។ ក៏ប៉ុន្តែនៅគ្រប់ការបញ្ជាក់ទាំងអស់នេះ វិធីក្ដៅគឺថាមានការលើកឡើង ថាបានប្រើប្រាស់ចំពោះមនុស្សតែពីរនាក់ក្នុងចំណោមមនុស្សទាំងអស់នោះ។ គឺពាក់ព័ន្ធតែឈ្មោះ យ៉ាង កយ ដែលរាយការណ៍ដែលបញ្ជាក់ថា សូមដកស្រង់ "បុគ្គលនោះត្រូវបានសួរចម្លើយដោយ", សូមដកស្រង់ "ប្រើប្រាស់វិធីក្ដៅខ្លះដើម្បីជីករកខ្សែរយៈរបស់វា ប៉ុន្តែវាបានបដិសេធមិនឆ្លើយទេ"។ ERN ជាភាសាអង់គ្លេស 00747287, ខ្មែរ 0027 1124, បារាំង 00271252។ ហើយពាក់ព័ន្ធទៅនឹងបុគ្គលម្នាក់ទៀតឈ្មោះ ថាច់ អ៊ុក របាយការណ៍បាននិយាយថា សូមដកស្រង់ "គឺថាគាត់ត្រូវវាយដំនៅក្នុងពេលសួរចម្លើយ ប៉ុន្តែវាមិនសារភាពទេ"។ ERN ជាភាសាអង់គ្លេស 00747279 ហើយនៅពេលនេះខ្ញុំមិនអាចបង្ហាញ ERN ជាភាសាខ្មែរបាននៅឡើយទេ។ ឥឡូវខ្ញុំអាចគឺ 00271118។ បាទ ខ្ញុំថាត្រូវបានបង្គាប់ឲ្យនិយាយមកយឺតបន្តិច។ ERN ជា

ភាសាបារាំង 00721261។

[០៩:៤៤:២៦]

ឯកសារទី២ លោកប្រធាន យើងខ្ញុំជឿជាក់ថា វាបង្ហាញនូវអង្គហេតុដូចតែគ្នានេះឯង គឺ ឯកសារ E3/4092 ជាឯកសារដែលខ្ញុំបានបញ្ជាក់ខាងដើម ពាក់ព័ន្ធទៅនឹងសៀវភៅកត់ត្រាសួរចម្លើយ នៅគុកក្រាំងតាចាន់ ពាក់ព័ន្ធទៅនឹងមនុស្សចំនួន១០៧ និងរួមទាំងស្ត្រី បុរស-ស្ត្រី យុវជន ហើយនិង ទាហាន លន់ នល់។ ERN ជាភាសាអង់គ្លេស 00834795 ដល់ 05, ដល់16 និងដល់22។ ERN ជា ភាសាខ្មែរ 00271135 ដល់46, ដល់55, ដល់59។ ភាសាបារាំង 00721276 ដល់87, ដល់96 និង 302។ លោកប្រធាន ដូចឯកសារខាងលើដែរ មនុស្សទាំង១០៧នាក់នេះ គឺថាបានរៀបរាប់លម្អិតនៅក្នុង ឯកសារនេះ គឺថាមានឱកាសតែបួនលើកប៉ុណ្ណោះ ដែលបុគ្គលទាំងអស់នេះត្រូវបាន សូមដកស្រង់ "សួរ ចម្លើយយ៉ាងតឹងតែង"។ បញ្ចប់ការដកស្រង់។ ខ្ញុំក៏សូមធ្វើការកត់សម្គាល់អំពីអត្ថបទជាភាសាបារាំង ការសួរចម្លើយមិនបានប្រើពាក្យថា "យ៉ាងតឹងតែង" នេះទេ។ គឺមានការបាត់បង់ក្នុងការបកប្រែរវាង ភាសាបារាំងទៅភាសាអង់គ្លេស។ គឺមានតែឱកាសបួនលើកប៉ុណ្ណោះ ពាក់ព័ន្ធទៅនឹងបុគ្គលដែលឃុំខ្លួន ត្រូវបានប្រើប្រាស់វិធីក្តៅតែបួនលើកតែប៉ុណ្ណោះ។

លោកប្រធាន គឺថាយើងខ្ញុំនឹងលើកឡើងមកនិយាយនូវឯកសារទាំងអស់នេះវិញ ប្រហែលក្នុង ពេលដែលយើងត្រូវធ្វើការជំទាស់ទៅលើឯកសារនៅចុងក្រោយនៃសប្តាហ៍នេះ។ ក៏ប៉ុន្តែសៀវភៅកត់ត្រា នេះ គឺពាក់ព័ន្ធជាពិសេស ហាក់បញ្ជាក់ថាវិធីក្តៅត្រូវបានប្រើប្រាស់ ហើយនិងបានស្នើសុំថា ហើយនិង ស្នើលើកឡើងថា វាមិនមែនជាការអនុវត្តជាបទដ្ឋានស្តង់ដារនោះទេ។ លើសពីនេះទៅទៀត ទាក់ទងទៅ នឹងសៀវភៅកត់ត្រាទី១ E3/4095 ដូចដែលតំណាងសហព្រះរាជអាជ្ញាបានលើកឡើងកាលពីម្សិលមិញ ថាមនុស្សមួយចំនួននៅក្នុងបញ្ជីនេះ រួមមានក្រុមគ្រួសាររបស់សាក្សី មាស សុខា។ រួមបញ្ចប់គឺមាន មាស សុខា ម្តាយរបស់ មាស សុខា ឈ្មោះ ហ៊ុន គឹមសេង និងបងស្រីរបស់គាត់ឈ្មោះ មាស សារ៉ាត់ ដែលអ្នកទាំងពីរ គឺថាបានស្នើសុំមកចូលខ្លួនធ្វើជាសាក្សី។ ឥឡូវនេះ ដូចដែលយើងដឹងហើយ ប្រជាជន ទាំង -- នៅរស់រានមានជីវិតនៅឡើយទេ មកដល់សព្វថ្ងៃនេះ។ លើកលែងតែសហព្រះរាជអាជ្ញាអាច បង្ហាញភស្តុតាងផ្ទុយ គឺវាអាចដែលថា ប្រជាជនមួយចំនួននៅក្នុងសៀវភៅកំណត់ត្រានេះអាចនៅរស់ រានមានជីវិតនៅឡើយ ហើយអ្នកទាំងអស់នេះ គឺមិនត្រូវបានសម្លាប់នៅគុកក្រាំងតាចាន់នោះទេ។

[០៩:៤៧:៥៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំធ្វើការជំទាស់មួយនៅត្រង់ចំណុចនេះ គឺថាមេធាវីការពារក្ដីត្រូវបានបង្ហាញឲ្យបង្ហាញឯកសារ ហើយក៏បានឆ្លងចូលទៅដល់ពេលធ្វើ គេហៅ ការពិភាក្សាដេញដោលជាចុង ការបិទពិភាក្សាដេញដោលជាចុងក្រោយ។ ខ្ញុំសូមក្រោកឈរដើម្បីឆ្លើយតបពាក់ព័ន្ធទៅនឹងចម្លើយរបស់អ្នកយាម គឺថាម្នាក់ៗ -- គឺថាមានតែពីរបីនាក់ទេ ដែលត្រូវបានសម្លាប់។ អានេះតាមសម្ដីរបស់អ្នកយាមនៅទីនោះ។ គាត់បានធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ មិនមានមូលដ្ឋានអ្វីដែលនិយាយថា គ្រប់ពេលវេលាទាំងអស់ ជាការជំទាស់តវ៉ា តែថាកាលណាមានការធ្វើទារុណកម្ម ត្រូវតែមានការកត់ត្រា។ នៅពេលដែលគាត់បានបញ្ចេញនេះ និងឯកសារនេះ។ ដូច្នេះ យើងត្រូវកំណត់ព្រំដែនក្នុងការបង្ហាញឯកសារតែប៉ុណ្ណោះ ហើយមិនត្រូវធ្វើឡើងនូវទឡ្ហីករណ៍ណាមួយទេ។ អ៊ីចឹងហាក់បីដូចជាគាត់យកសក្ខីកម្មរបស់សាក្សីយកមកធ្វើការលើកឡើង ធ្វើការជំទាស់តវ៉ាទៅវិញ មិនជាការបង្ហាញនោះទេ។

[០៩:៤៩:២៤]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥០:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ ប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ ដើម្បីឆ្លើយបញ្ជាក់ជូនភាគីអំពីបញ្ហានេះ។ សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សហព្រះរាជអាជ្ញាបានលើកឡើងនៅក្នុងសវនាការនៃការបង្ហាញឯកសារបែបនេះ យើងត្រូវតែកំណត់រវាងការបង្ហាញឯកសារ ឬក៏ការលើកឡើងនូវខ្លឹមសាររបស់ឯកសារយកមកធ្វើការជំទាស់តវ៉ា។ យើងខ្ញុំសូមរំឭកថា នេះមិនមែនជាកិច្ចបញ្ចប់កិច្ចពិភាក្សាដេញដោលទេ ដូច្នេះសូមលោកផ្ដោតទៅលើតែលើការបង្ហាញឯកសារតែប៉ុណ្ណោះបានហើយដែលមិនមានពាក់ព័ន្ធ មិនត្រូវពាក់ព័ន្ធជាមួយនឹងការវាយតម្លៃ។

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំនឹងបំពេញកិច្ចនេះឱ្យបានត្រឹមត្រូវ។ ខ្ញុំពន្យល់គ្រាន់តែថា មួយឃ្លាពីរឃ្លា ថាវាហេតុអ្វីយ៉ាងដូច្នេះ ក៏ប៉ុន្តែខ្ញុំព្យាយាមគិតថាធ្វើម៉េចមិនឱ្យវាចូលទៅដល់វគ្គកិច្ច បិទកិច្ចពិភាក្សាដេញដោលនោះទេ។

ឥឡូវនេះលោកប្រធាន ខ្ញុំសូមចូលទៅឯកសារដែលអាចបង្ហាញការប្រើប្រាស់ផ្សេងៗនូវពាក្យថា "កម្ទេច"។ ឯកសារនេះមាននៅក្នុងកំណត់ត្រារបស់ស្រុកត្រាំកក់ដែលបញ្ជាក់ក្នុងនោះ មានពាក្យថា "ស្មាស" "កម្ទេច" ដែលមានអត្ថន័យខុសៗគ្នា ហើយមិនអាចឱ្យអត្ថន័យវាស្មើនឹងពាក្យថា "ការសម្លាប់ចោល" នោះទេ។ ឧទាហរណ៍ នៅក្នុងឯកសារ E3/2053 គឺថាមិនមានចុះកាលបរិច្ឆេទទេ របាយការណ៍ជូនបក្សដែលសរសេរឡើងដោយឈ្មោះ ធឹម ជាមេសហករណ៍ត្រពាំងធំខាងត្បូងដោយសង្ខេបនូវចម្លើយសារភាពរបស់មនុស្សពីរនាក់។ ERN ជាភាសាអង់គ្លេស 00276578, ខ្មែរ 00079122, បារាំង 00334996។ របាយការណ៍ទាក់ទងទៅនឹងមនុស្សមានឈ្មោះថា អ៊ុក ផាត់ ហើយនិងឈ្មោះ ស៊ី ដែលបានរកឃើញនូវខ្សែរយៈរបស់គេ និងមានផែនការ -- ពួកគេមានផែនការជាក់ស្តែងគឺមានផែនការ សូមដកស្រង់ "ផែនការ៥ឆ្នាំ ដើម្បីធានាអំពីការកម្ទេចសហករណ៍យើងក្នុងរយៈពេល៥ឆ្នាំ"។ បញ្ចប់ការដកស្រង់។ អាចរយៈពេល៥ឆ្នាំ ឬមួយក៏២ឆ្នាំ ឬក៏យ៉ាងណាក្តីសូមដកស្រង់ "វាចាំបាច់ត្រូវតែកម្ទេចចោលសហករណ៍ ហើយនិងជំទាស់ទៅនឹងការហូបរួម"។ បញ្ចប់ការដកស្រង់។ បន្ថែមទៅលើនេះទៀត របាយការណ៍បាននិយាយថា អ៊ុក ផាត់ និង ស៊ី សូមដកស្រង់ "មានផែនការទាក់ទងជាមួយយួន និងថៃដើម្បីប្រើប្រាស់អាវុធកម្ទេចបដិវត្តន៍"។ បញ្ចប់ការដកស្រង់។

[០៩:៥៣:៥២]

ឯកសារ E3/2453 គឺចុះកាលបរិច្ឆេទ ១៨ តុលា មកឈ្មោះ មៀទ ឃុំញ៉ែងញ៉ង ឯកសារជា ERN ជាភាសាអង់គ្លេស 00388586, ខ្មែរ 00270784 និងបារាំង 00611775។ របាយការណ៍នេះគឺបានកំណត់អត្តសញ្ញាណខ្សែរយៈរបស់បុគ្គលបួននាក់ឈ្មោះ ឡូ អេងទ្រី, ឈ្មោះ សួស ទី, យន់ យាន, បាង ណាន ដែលក្នុងនោះ "ខ្ញុំធ្វើការវិភាគរបស់ខ្ញុំគឺគេមានផែនការកម្ទេចបដិវត្តន៍របស់យើង" បញ្ចប់ការដកស្រង់។ ឯកសារ E3/4092 ដែលសហព្រះរាជអាជ្ញាបានបង្ហាញពីម្សិលមិញ ហើយដូចខ្ញុំលើកឡើងពីខាងដើមនេះ គឺជាសៀវភៅកំណត់ត្រាការសួរចម្លើយនៅគុកក្រាំងតាចាន់ ពាក់ព័ន្ធទៅនឹងការសួរចម្លើយមនុស្ស១០៧នាក់។ ERN ជាភាសាអង់គ្លេស 00834818, ខ្មែរ 00271155 ដល់56 និងបារាំង 00721304។ នៅត្រង់ចំណុចនេះ សូមឱ្យអង្គជំនុំជម្រះមេត្តាយកចិត្តទុកដាក់ទៅលើសៀវភៅកំណត់

ត្រា ដែលនិយាយអំពីសកម្មភាពរបស់ ផាន់ នឿន សូមដកស្រង់ "រៀបចំកិច្ចប្រជុំដើម្បីបង្កើតផែនការជាមួយនឹងបក្ខពួករបស់វាប្អូន -- ដែលមានមនុស្សប្អូននាក់ ដើម្បីកម្ទេចសហករណ៍យើង"។ ERN ជាភាសាអង់គ្លេស 00834817 ដល់ 8, ខ្មែរ 00271155, បារាំង 00721304។

លោកប្រធាន ប្រភេទនៃឯកសារចុងក្រោយដែលខ្ញុំត្រូវបង្ហាញនូវព្រឹកនេះ វាអាចផ្តល់ឱ្យយល់អំពីព្រឹត្តិការណ៍ផ្ទៃក្នុងនៅគុកក្រាំងតាចាន់ ដែលមានឯកសារពីរដែលទាក់ទងទៅនឹងស-២១ ជាពិសេសហើយដែលក៏ខ្ញុំថា គឺពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខដទៃទៀតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យផងដែរ។ ប្រភេទនៃឯកសារនេះ ដែលបាន ដែលកំពុងនិយាយហ្នឹង ដែលថាអ្នកទោសខ្លះ ដោយសារតែវាមានចំនួនច្រើនមែនទែន គឺត្រូវបានដោះលែងពីស-២០ -- មានតែប្រាំពីរនាក់ប៉ុណ្ណោះ ដែលរស់រានមានជីវិតពីស-២១។

[០៩:៥៦:៣៨]

ខ្ញុំសូមយោងទៅឯកសារ E3/7326 ដែលជាឯកសារដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ហៅថា "ប៉ុល ពត ហើយនិងអ្នកទោសរបស់គាត់នៅក្នុងគុកសម្ងាត់ស-២១"។ បញ្ចប់ការដកស្រង់ និងទស្សនៈយល់ឃើញពាក់ព័ន្ធទៅនឹងការដោះលែងអ្នកទោសនៅស-២១។ ERN ជាភាសាអង់គ្លេស 01002075 ដល់ 85 មិនមានការបកប្រែជាភាសាខ្មែរនៅឡើយទេ លោកប្រធាន ហើយភាសាបារាំងក៏មិនទាន់បានបកប្រែនៅឡើយដែរចំពោះឯកសារនេះ។ ហើយឯកសារនេះ គឺថាមជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់នូវប្រភេទផ្សេងគ្នានានានៃអ្នកទោស ដែលត្រូវបានដោះលែងពីស-២១ ដូចជា កុមារ ហើយកម្មាភិបាលខ្មែរក្រហមមួយចំនួន។ ឯកសារបង្ហាញព្រឹត្តការណ៍នៃការពិតនោះផ្តល់នូវបញ្ជីអ្នកទោសដ៏វែងដែលមជ្ឈមណ្ឌលឯកសារកម្ពុជានិយាយថា ត្រូវបានដោះលែងចេញពី ស-២១ ហើយដែលត្រូវបានរាយការណ៍ថា នៅរស់រានមានជីវិតនៅឡើយ គឺអ្នកដែលមានស្ថានភាពមិនច្បាស់លាស់ និងប្រជាជនដែលបានស្លាប់ក្រោយឆ្នាំ១៩៧៩។

[០៩:៥៧:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ ផ្អាកបន្តិចសិនលោកមេធាវី!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ឌេល លីសាក់៖**

ខ្ញុំមិនបាន -- រកមិនឃើញឯកសារ E3/7326 នោះទេ។ គឺថា យើងត្រូវបានបង្គាប់ឲ្យបង្ហាញនូវឯកសារពាក់ព័ន្ធទៅនឹងស្រុកត្រាំកក់។ ខ្ញុំមិនចង់ជំទាស់នៅដំណាក់កាលនេះ ប៉ុន្តែខ្ញុំចង់ឃើញឯកសារនេះ។ ពីព្រោះអ្នកទោស ដែលគេបានដោះលែងពីស-២១ គឺត្រូវគេបញ្ជូនទៅព្រៃស មិនបានដោះលែងឲ្យរួចខ្លួនទាំងស្រុងតែម្តងនោះទេ។ ដូច្នេះ ខ្ញុំសូមឲ្យបង្ហាញឯកសារពាក់ព័ន្ធទៅនឹងការដោះលែងអ្នកទោសនេះ។

[០៩:៥៨:៥១]

**លោក វ៉ិចទ័រ កូប៉េ៖**

អ៊ូ!

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

លោកមេធាវី កូប៉េ លោកអាចពន្យល់បានទេថា ឯកសារនុ៎ងវាពាក់ព័ន្ធអីទៅនឹងផ្នែកនៃសវនាការយើងនៅថ្ងៃនេះនោះ គឺស្រុកត្រាំកក់ និងគុកក្រាំងតាចាន់នោះ? ខ្ញុំសូមសារភាពថា ស-២១ មិនស្ថិតនៅក្នុងវិសាលភាពនៃផ្នែកនេះទេ។ អ៊ីចឹងសូមលោកពន្យល់បំភ្លឺទៅមើល!

**លោក វ៉ិចទ័រ កូប៉េ៖**

ប៉ុន្តែស-២១ ត្រូវបានគេទាញចូលជាច្រើនដងនៅក្នុងផ្នែកនេះ ប៉ុន្តែភាពពាក់ព័ន្ធនៃឯកសារនេះ គឺចង់បង្ហាញថា មានអ្នកទោសជាច្រើនមកពីស-២១ ត្រូវបានគេដោះលែង ដែលវាធ្វើឲ្យ -- ដែលវាបង្ហាញពីភាពផ្ទុយពីទស្សនៈរបស់ព្រះរាជអាជ្ញាដែលថា អ្នកទោស -- មិនមានអ្នកទោសត្រូវបានគេដោះលែងពីក្រាំងតាចាន់នោះទេ។

នៅពេលដែលយើងធ្វើការប្រៀបធៀបនេះ ខ្ញុំគិតថាវាក៏ពាក់ព័ន្ធផងដែរ ដោយសារតែមានការដោះលែងពីស-២១ ក៏អាចមានការដោះលែងពីក្រាំងតាចាន់ដែរ។ លោកសហព្រះរាជអាជ្ញា ឯកសារ E307/5.2.10។ លោកប្រធាន លោកចៅក្រម ឡាវ៉ែន៍ ឯកសារដែលខ្ញុំបង្ហាញហ្នឹងក៏ពាក់ព័ន្ធទៅ E3/39992 គឺជាអត្ថបទរបស់កាសែតខាមបូឌា ដេលី ចុះថ្ងៃទី២៨ សីហា ២០០៨។ អង់គ្លេសមានលេខ 00548253 ដល់ 4, ខ្មែរមានលេខ 00814871 ដល់ 73 និងបារាំងមានលេខ 00836686 ដល់ 92។

[១០:០១:០៩]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កូប៉េ ទោះបីជាយើងមិនពិនិត្យអង្គហេតុពាក់ព័ន្ធនឹងស-២១ ហើយយើងក៏មិនពិភាក្សាថា តើអ្នកទោសត្រូវបានដោះលែងពីស-២១ ឬក៏យ៉ាងម៉េចនោះ តើមានការបញ្ជាក់អំពីករណីហ្នឹង? អ៊ីចឹងលោកចង់បង្ហាញថា អ្នកទោសនៅក្រាំងតាចាន់ហ្នឹងក៏ត្រូវបានគេដោះលែងដែរ តើអ៊ីចឹងទេភាពឡូស៊ីករបស់លោកនោះ? ខ្ញុំដូចជាពិបាកយល់អំពីអ្វីដែលលោកលើកឡើងនេះណាស់។

**លោក វ៉ិចទ័រ កូប៉េ៖**

អត្ថបទដែលខ្ញុំដកស្រង់ចេញពី ខេមបូឌា ដេលី គឺជាអត្ថបទនៅថ្ងៃ -- នៅខែ -- នៅឆ្នាំ២០០៨ ជាអត្ថបទមុនដែលគេជំនុំជម្រះ -- ដែលកំពុងជំនុំជម្រះទៅលើ ឌុច ដែលបាននិយាយថា មានអ្នកទោស ១៧៧នាក់ ត្រូវបានគេដោះលែងពីស-២១។ ដែលអង្គជំនុំជម្រះសាលាដំបូងមិនបានដាក់បញ្ចូលទៅក្នុងសាលក្រមរបស់ខ្លួនឡើយ ដែលថាមានមនុស្សជាច្រើនត្រូវបានដោះលែង ហើយចំពោះក្រាំងតាចាន់ក៏អាចមានចំនួនអ្នកទោសជាច្រើនត្រូវបានដោះលែងផងដែរ។

ខ្ញុំគិតថាការដែលយើងបង្ហាញឯកសារពីរនេះគឺយើង -- គឺធ្វើឲ្យយើងឃើញថា អាចថាខ្លឹមសារនៃបទបង្ហាញរបស់យើងបង្ហាញថាមានអ្នកទោសត្រូវបានគេដោះលេងពីមន្ទីរសន្តិសុខនានា។

[១០:០២:៤២]

**លោក ឌេល លីសាក់៖**

ជាដំបូងខ្ញុំនៅតែរកមិនឃើញឯកសារដដែល មិនដឹងថា គាត់អានញាប់ពេក ឬមួយក៏យ៉ាងម៉េចដែរ គឺឯកសារដែលខ្ញុំមិនដែលដឹង។ យ៉ាងណាក៏ដោយខ្ញុំគិតថា ឥឡូវវាដូចជាឆាប់រហ័សពេកដែលលើកយកពីចំណុចនេះមក ព្រោះថាយើងបានដាក់ភស្តុតាង ហើយយើងមិនទាន់ដោះស្រាយទៅលើបញ្ហាស-២១។ ហើយម្យ៉ាងទៀត អ្នកទោសហ្នឹងត្រូវបានគេបញ្ជូនទៅព្រៃស ហើយក្រោយមកបញ្ជូនត្រឡប់មកស-២១ សម្លាប់វិញ។ ដូច្នេះ អានេះហើយគឺជាបញ្ហាទាក់ទងទៅនឹងអ្នកទោសស-២១ ប៉ុន្តែយើងគួរតែទុកចាំដល់ពេលស-២១ សឹមដោះស្រាយ មិនមែននៅពេលនេះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំរីករាយនឹងនិយាយឡើងវិញនូវអ្វីដែលព្រះរាជអាជ្ញា ព្រោះថាឯកសារនេះគឺវាមានបញ្ជីឈ្មោះអ្នកទោសជាច្រើន ហើយព្រះរាជអាជ្ញាក៏ធ្វើដូចគ្នានេះដែរ។ ការដែលយើងលើកយកក្រាំងតាចាន់មក

គិតក្នុងបរិបទ ស-២១ គឺមិនមែនជាអ្វីដែលស្ថិតនៅក្រៅ--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវី លោកធ្វើការបង្ហាញរបៀបដូចជាសារណាបញ្ចប់ការពិភាក្សាដេញដោលដូច្នេះដែរ ប៉ុន្តែដូច្នេះយើងគួរតែចំណាយពេលច្រើននៅទៅលើចំណុចទាំងអស់នោះ។

[១០:០៤:០៥]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគ្រាន់តែធ្វើបទបង្ហាញឯកសារតែពីរប៉ុណ្ណោះ ទាក់ទងទៅនឹងការងាររបស់ ឆាំង យុ ដែលទាក់ទងទៅនឹងថាមានអ្នកទោសត្រូវបានគេដោះលែង។ ដូចដែលខ្ញុំបានបញ្ជាក់អ៊ីចឹង លោកប្រធាន ឥឡូវនេះខ្ញុំសូមបន្តទៅលើប្រធានបទថ្មីមួយទៀត គឺឯកសារដែលមិនអាចជឿជាក់បាន ឬក៏ឯកសារក្រាំងតាចាន់ដែលមិនអាចជឿជាក់ ដែលមានតម្លៃភស្តុតាងតិចតួចប៉ុណ្ណោះ។

ដូចដែលខ្ញុំបានបញ្ជាក់អំពីប្រភេទជាច្រើននៃឯកសារដែលយើងជឿជាក់ថា ពាក់ព័ន្ធយ៉ាងខ្លាំងក្នុងការកំណត់សម្រេចអំពីហេតុការណ៍នៅក្រាំងតាចាន់។ ឥឡូវនេះ ខ្ញុំចង់បង្ហាញអំពីឯកសារមួយចំនួនដែលផ្ទុយពីអ្វីដែលយើងជឿជាក់។ យើងជឿជាក់ថា មានតម្លៃភស្តុតាងតិចតួចប៉ុណ្ណោះ ដោយសារតែឯកសារហ្នឹងអាចថា មួយចំនួនត្រូវបានគេក្លែងបន្លំ។

ជាដំបូងគឺការក្លែងបន្លំដែលគេធ្វើឡើងក្រោយឆ្នាំ៧៩ ខ្ញុំនឹងពិភាក្សាទៅលើឯកសារចំនួនពីរ គឺឯកសារទី១ ដែលពឹងផ្អែកទៅលើដីកាដំណោះស្រាយ កថាខណ្ឌ៥១៤, ៥០០ និងកថាខណ្ឌ១៨៣៥ដែលជាមូលដ្ឋានដែលសហចៅក្រមស៊ើបអង្កេតបានស្នើថា យ៉ាងហោចណាស់ក៏មានមនុស្ស១៥០០០នាក់ត្រូវបានសម្លាប់នៅក្រាំងតាចាន់។ ឯកសារនោះ គឺឯកសារ E3/2107 គឺជាសៀវភៅកំណត់ត្រាមកពីក្រាំងតាចាន់ដែលមានរៀបរាប់ចំនួន៩១ផ្នែក។ អង់គ្លេសមានលេខ 00290205, ខ្មែរមានលេខ 00068049, បារាំងមានលេខ 00655725។ នៅត្រង់ERN ដែលមានលេខ 00290205 គឺមានចំណារមកពីអ្នកបកប្រែខ្មែរបារាំង -- ខ្មែរ-អង់គ្លេសរបស់ អ.វ.ត.ក ដែលពាក់ព័ន្ធទៅនឹងការសរសេរអ្នកបកប្រែសរសេរថា ទំព័របន្ទាប់សរសេរខ្វែង -- សរសេរកាត់មិនៗដូចនៅក្នុងអក្សរសរសេរនៅផ្នែកដទៃនៃឯកសារនោះឡើយ។ នៅពេលដែលយើងពិនិត្យមើលឯកសារច្បាប់ដើមខ្មែរគឺបញ្ជាក់ថា អក្សរសរសេរដៃនោះ គឺខុសពីគេ កំណត់ត្រាដែលសរសេរកាត់ខ្លួនឯងបញ្ជាក់ថា រហូតមកដល់ថ្ងៃនេះ យើងបានកម្ទេចៗខ្មាំង១៥០០០នាក់។ ហើយនេះគឺជាកំណត់ត្រាដែលសហចៅក្រមស៊ើបអង្កេតពឹងផ្អែកក្នុងដីកា

ដំណោះស្រាយ។ តាមពិតទៅគឺមានអក្សរសរសេរខៀកខ្លួនឯង សរសេរដោយអក្សរពីរប្រភេទ ជួរបួនខាងលើ គឺសរសេរដោយអក្សរមួយ ចំណែកជួរពីរខាងក្រោមគឺសរសេរដោយអក្សរផ្សេងដែលកាលពីម្សិលមិញសាក្សី -- ដែលពីសប្តាហ៍មុនសាក្សី ពេជ្រ ជឹម ក៏បានអះអាងដែរ បន្ថែមទៅលើនេះទៀតនៅក្នុងកំណត់ត្រាទាំង៩១ និងក្នុងសៀវភៅគឺមានចំណារសរសេរដែលហាក់ដូចជាខុសបរិបទ ដែលមានតែមួយប៉ុណ្ណោះដែលនិយាយអំពីអ្នកឆ្លើយតប ហើយប្រយោគនិយាយថាបក្សបានទទួលព័ត៌មានអំពីចំណុចអស់នេះ។ ជាការបញ្ជាក់ច្បាស់ថា តើវាសរសេរនៅទីណាគឺ -- ហើយការចុះហត្ថលេខាគឺវាហាក់ដូចជាខុសកន្លែងខុសពីកន្លែងផ្សេងទៀតនៅក្នុងសៀវភៅ។

[១០:០៧:៤៩]

ខ្ញុំកត់សម្គាល់ឃើញថា ភាពអាចជឿជាក់បាននៃកំណត់ត្រាសរសេរដៃហ្នឹងគឺត្រូវបានពិភាក្សាដោយសាក្សីជាច្រើនរួចមកហើយក្នុងពេលសវនាការ ហើយខ្ញុំនឹងមិននិយាយឲ្យលម្អិតទេ។ ប៉ុន្តែខ្ញុំចង់សន្និដ្ឋានថា យើងជឿជាក់ថាឯកសារទាំងអស់នេះ គឺជាឯកសារដែលត្រូវបានគេក្លែងក្លាយក្រោយឆ្នាំ៧៩ ដើម្បីបង្កើនចំនួនមនុស្សស្លាប់នៅក្រាំងតាចាន់ឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ នៅទំព័រគម្របនៃឯកសារនេះ គឺបញ្ជាក់ថាគឺមានចម្លើយសារភាពរបស់ជនក្បត់ ប៉ុល ពត និង អៀង សារី ដែលជាកំណត់ត្រាច្បាស់ណាស់ត្រូវបានបន្ថែមក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ខេល លីសាក់៖**

ខ្ញុំគិតថានេះគឺជាទឡ្ហីករណ៍ ប៉ុន្តែនេះមិនមែនជាហេតុផលដែលខ្ញុំឡើងជំទាស់ទេ។ គាត់និយាយអំពីឯកសារពីរផ្សេងគ្នា គឺសៀវភៅកំណត់ត្រាដែលមានកំណត់ត្រា១៥០០០ ប៉ុន្តែវាជាឯកសារផ្សេងមិនមែនជាឯកសារតែមួយ ហើយនៅពេលដែលគាត់និយាយអំពីការសរសេរអក្សរពីរហ្នឹង គាត់ថាការក្លែងក្លាយ។ ឯកសារដែលមានអក្សរសរសេរដៃនៅទំព័រខាងលើដែលនិយាយថា ចម្លើយសារភាពទី៥របស់អាក្បត់ ប៉ុល ពត, អៀង សារី គឺមិនមែននៅក្នុងសៀវភៅនេះទេ គឺថាគាត់បង្ហាញឯកសារផ្សេងពីរខុសៗគ្នា។ ដូច្នេះហើយខ្ញុំសូមជំទាស់។ ប្រសិនបើគាត់ចង់លើកទឡ្ហីករណ៍បង្ហាញ អាហ្នឹងជារឿងមួយផ្សេង។

[១០:០៩:៣៨]

**លោក វិចទ័រ កូប៉េះ**

ខ្ញុំយល់ស្របថាវាជាឯកសារពីរផ្សេងគ្នា ប៉ុន្តែវាជាឯកសារដែលនិយាយថាបនក្បត់ ប៉ុល ពត, អៀង សារី ជាឯកសារដែលធ្វើឡើងក្រោយឆ្នាំ៧៩ ហើយខ្ញុំចង់បញ្ជាក់ថាសៀវភៅកំណត់ត្រានោះវាស្ថិតនៅក្នុងដៃអាជ្ញាធរក្រោយឆ្នាំ៧៩ ដែលវាអាចថាជាការចារនៅក្រោយឆ្នាំ៧៩។ ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំគិតថាខ្ញុំយល់ស្របជាមួយព្រះរាជអាជ្ញាដែលថា នេះជាឯកសារពីរផ្សេងគ្នា។

ឯកសារ E3/4145 នេះគឺជាឯកសារដែលជាការប្រមូលផ្តុំបញ្ជីឈ្មោះអ្នកទោសផ្សេងៗគ្នាមកពីក្រាំងតាចាន់។ អង់គ្លេសមានលេខ 00762844 ហើយ ERN បញ្ចប់នៅត្រង់លេខ 37, ខ្មែរមានលេខ 00068736, បារាំងមានលេខ 00761100 ហើយ ERN បញ្ចប់នៅត្រង់លេខ 093។ ទំព័រមួយទៀតគឺមានអង់គ្លេសមានលេខ 00762844 គឺជាទំព័រដែលសរសេរដៃយ៉ាងគគ្រិច ដែលមានការកែប្រែ ដែលថាបញ្ជីឈ្មោះ ឃុត សែន គឺជាអ្នកទោសមួយដែលត្រូវបានឃុំខ្លួនរាប់ឆ្នាំរង់ចាំសេចក្តីសម្រេចរបស់បក្ស ហើយ ឃុត សែន បានបញ្ជាក់ថា យោងទៅលើគាត់។ ឯកសារដែលមានឈ្មោះក្រាំងតាចាន់ ថាជា “ម-១០៥” នោះគឺជាឯកសារតែមួយដែលនៅក្នុងកំណត់ត្រាក្រាំងតាចាន់។ ក្រៅពីនេះក៏រៀបរាប់អំពី ហ៊ុន គឹមសេង និង មាស សារ៉ាត់ ថាជាអ្នកទោស ប៉ុន្តែកត់ត្រាប្រវត្តិរូបរបស់ពួកគេដោយមិនត្រឹមត្រូវ។ ផ្ទុយទៅវិញ គឺវាផ្ទុយទៅនឹងកំណត់ត្រារបស់ស្រុក។ ផ្ទុយទៅវិញទំព័រដែលមានអង់គ្លេសមានលេខ 00762837 នៅក្នុងឯកសារចងក្រងដដែល ដែលហាក់ដូចជាផ្អែកទៅលើតាមការពិនិត្យខ្លឹមសារមូលដ្ឋាន និងការរូបភាព បង្ហាញថាវាជាឯកសារច្បាប់ដើមដែលវាយដាក់ទីឡូ ហើយសរសេរនៅលើទម្រង់ដែលច្បាស់លាស់ ដែលនិយាយយោងទៅលើព័ត៌មានអ្នកទោសសូម្បី -- បង្ហាញឲ្យបានច្បាស់លាស់។ ដូច្នេះយើងអាចឃើញថាឯកសារមុនវាជាឯកសារដែលមានការក្លែងក្លាយ។

[១០:១២:០៨]

លោកប្រធាន លោក លោកស្រីចៅក្រម ឯកសារទាំងអស់នេះខ្ញុំសូមបញ្ចប់ការសន្និដ្ឋានរបស់ខ្ញុំមុនពេលឈប់សម្រាកសិន។ ប៉ុន្តែឯកសារទាំងអស់នេះហាក់ដូចជាត្រូវបានគេធ្វើឡើងក្រោយឆ្នាំ៧៩ ជាមធ្យោបាយក្នុងការរៀបចំឡើងនៅលើខ្លឹមសារនៃអ្វីដែលកើតឡើងនៅក្រាំងតាចាន់។ ហើយឯកសារដទៃទៀត និងកម្មសិទ្ធិភាពរបស់ឯកសារដទៃទៀតដែលត្រូវបាននេះត្រូវបានបដិសេធ។ ដូច្នេះខ្ញុំគិតថានេះប្រហែលជាផ្នែកបន្ត គឺឯកសារទាក់ទងទៅនឹងការក្លែងក្លាយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែ ខ្ញុំឃើញថាហាក់ដូចជាដល់ម៉ោងឈប់សម្រាកហើយ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ការជំទាស់ខ្ញុំយឺតពេលទៅហើយ ក៏ប៉ុន្តែនេះជាការលើកជជែកពិភាក្សាដេញដោលទៅហើយ មិនមែនជាការបង្ហាញឯកសារទេ។ ដូច្នេះយើងមិនទាំងអាចអាន ERN ទាន់ផង យើង -- គាត់ទៅហួសពីអ្វីដែលអង្គជំនុំជម្រះបានកំណត់ដែរ។ អ៊ីចឹងនៅពេលដែលយើងធ្វើការកត់សម្គាល់របស់យើងនៅថ្ងៃព្រហស្បតិ៍នោះ សូមលោកប្រធានមេត្តាអនុញ្ញាតឲ្យយើងធ្វើដូចគាត់ផង គឺធ្វើដូចជាការពិភាក្សាដេញដោលបញ្ចប់អ៊ីចឹង។

[១០:១៣:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ ជាការពិតណាស់ ព្រោះអង្គជំនុំជម្រះបានកំណត់នូវកិច្ចដំណើរការនៃការបង្ហាញឯកសារគន្លឹះនេះ មានភាគីដាក់បង្ហាញឯកសារគន្លឹះរៀងៗខ្លួន និងទុកមួយពេលមួយភាគីសម្រាប់ជំទាស់តវ៉ាទៅនឹងការដាក់បង្ហាញឯកសាររបស់ភាគីម្ខាងទៀត។ ដូច្នេះពេលវេលាសម្រាប់ជំទាស់តវ៉ា អង្គជំនុំជម្រះបានបែងចែករួចរាល់ហើយ មួយភាគីមួយពេល ដែលយើងនឹងលើកធ្វើថ្ងៃ៣០ គឺថ្ងៃព្រហស្បតិ៍ ទី៣០ ខែមេសា ឆ្នាំ២០១៥។ បើជំទាស់បច្ចុប្បន្ននេះមានការជំទាស់តវ៉ារួចហើយនេះ ទំនងជាលុបចោលនូវពេលវេលាដែលបានបែងចែកឲ្យក្នុងការជំទាស់តវ៉ាទៅលើការដាក់បង្ហាញឯកសារគន្លឹះរបស់ភាគីម្ខាងៗហើយ។ បានន័យថាមិនចាំបាច់ទេ ព្រោះជំទាស់បណ្ដើរៗ ដល់ពេលដាក់បង្ហាញឯកសារចប់គឺចប់តែម្ដង។

ដូច្នេះករណីជាច្រើនគួរតែរង់ចាំកត់សម្គាល់ ហើយរង់ចាំដល់ពេលត្រូវជំទាស់តវ៉ាទៅលើការដាក់បង្ហាញឯកសារគន្លឹះរបស់ភាគីម្ខាងទៀត។ ចំណុចណាដែលខ្លួនមិនសុខចិត្ត ខ្លួនយល់ថាមិនត្រឹមត្រូវបង្ហាញមកអង្គជំនុំជម្រះដើម្បីឲ្យចូលក្នុងប្រតិចារឹក។

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់និងសាមសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៥ នាទី ដល់ម៉ោង ១០:៣២ នាទី)*

[១០:៣២:០៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅមេធាវីការពារក្តី នួន ជា ដើម្បីបន្តការដាក់បង្ហាញនូវឯកសារគន្លឹះរបស់ខ្លួន។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណ លោកប្រធាន។ ខ្ញុំមានឯកសារក្រាំងតាចាន់ចំនួនបួនទៀតដែលត្រូវបន្តទៅមុខ។ បន្តគឺប្រហែលជាការក្លែងបន្លំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺ E3/2785 ជាលិខិតដែលចុះហត្ថលេខាដោយមនុស្សម្នាក់ឈ្មោះ សាន ផ្ញើជូនបង អាន់ ចុះថ្ងៃ០៧ ខែមីនា។ អង់គ្លេសមានលេខ 0032 2193, ខ្មែរមានលេខ 00079115, បារាំងមានលេខ 00753636។ លិខិតនេះបង្ហាញពីបុគ្គលម្នាក់ដែលព្យាយាមរត់ទៅវៀតណាម ប៉ុន្តែក្នុងពេលផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ តាសាន បានផ្តល់សក្ខីកម្មថា ទោះបីគាត់ទទួលស្គាល់ថាឯកសារនេះសរសេរដោយគាត់ ប៉ុន្តែឯកសារនេះ មិនមែនជាឯកសារសរសេរដោយផ្ទាល់ដៃខ្ញុំឡើយ។

[១០:៣៣:៣១]

ឯកសារបន្ទាប់គឺ E3/2423 វាជាកំណត់ត្រាពី សាន ផ្ញើជូនមនុស្សម្នាក់ដែលមិនដឹង មិនដឹងកាលបរិច្ឆេទទៀត ស្នើសុំឲ្យមានការសួរចម្លើយអ្នកទោសមួយចំនួន។ អង់គ្លេសមានលេខ 00322210, ខ្មែរមានលេខ 00079128, បារាំងមានលេខ 00611732។ ឯកសារនេះបង្ហាញអ្នកទោសពីរនាក់ឈ្មោះ ហ៊ុល ហើយនិង សៀន ហើយសួរអំពីបណ្តាញរបស់ពួកគេ។ ក្នុងពេលផ្តល់សក្ខីកម្ម តាសាន បាននិយាយថា "នេះមិនមែនជាអក្សរសរសេរដោយដៃរបស់ខ្ញុំនោះឡើយ"។

ហើយឯកសារចុងក្រោយគឺ E3/2452 ឯកសារនេះគឺជាការចងក្រងលិខិត ដែលសរសេរដោយឈ្មោះ នៅ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ៧៧ មកពីស្រែរនោង។ អង់គ្លេសមានលេខ 00843036, ខ្មែរមានលេខ 00270998, បារាំងមានលេខ 00872836។ លិខិតដែលលើកឡើងនេះ គឺនិយាយអំពីប្រជាជន

ថ្មីម្នាក់ឈ្មោះ សែង កែវ ដែលត្រូវបានរត់ចោលកងរបស់គាត់២ថ្ងៃ ប៉ុន្តែសាក្សី នុត នូវ ដែលបង្ហាញនៅអង្គជំនុំជម្រះនេះ បានយល់ស្របថា គាត់បានទៅ -- គាត់ជាមេឃុំស្រែរនោង ប៉ុន្តែគាត់និយាយពីរដងក្នុងសក្ខីកម្មថា លិខិតនេះមិនមែនអក្សរសរសេរដៃរបស់ខ្ញុំទេ ហើយគាត់មិនចាំអក្សរសរសេរដៃនោះឡើយ។ នូវ បញ្ជាក់ថាមិនមានអ្នកដទៃណាម្នាក់ឈ្មោះ នៅ ឡើយ ហើយគិតថាប្រហែលជាអ្នកដទៃ ឬក៏អាចថាស្មៀនជាអ្នកសរសេរលិខិតនេះ។

[១០:៣៥:៣១]

ហើយនៅលិខិតចុងក្រោយ ទាក់ទងទៅនឹងក្រាំងតាចាន់ដែលខ្ញុំចង់បង្ហាញនៅព្រឹកនេះ គឺបញ្ជីសម្លាប់ទាហាន លន់ នល់។ នេះគឺជាលិខិត ឬក៏បញ្ជីបង្ហាញពីការសម្លាប់អ្នកទោស លន់ នល់ នៅស្រុកត្រាំកក់ គឺឯកសារ E3/4083 គឺឯកសារដែលមានឈ្មោះថា "ចំនួនអ្នកទោស"។ អង់គ្លេសមានលេខ 00323943 ដល់78, ខ្មែរមានលេខ 00068024 ដល់ 37 និងបារាំងមានលេខ 00778851 ដល់ 79។ ដូចដែលបានពិភាក្សានៅក្នុងសាលសវនាការ គឺមានភាពខុសគ្នាយ៉ាងខ្លាំង រវាងឯកសារខ្មែរ និងឯកសារអង់គ្លេស និងឯកសារបារាំង។ នៅក្នុងឯកសារខ្មែរ ចំណារហាក់ដូចជាមាននៅគ្រប់កន្លែង នៅក្នុងឯកសារដែលយើងយល់ថា គេបកប្រែថា "ក.ទ" ប៉ុន្តែភាសាអង់គ្លេសបែរជាប្រើសញ្ញា "ខ្វែង" ហើយចំណែកភាសាបារាំង ឯកសារភាសាបារាំងប្រើពាក្យថា "អេលីមីនេ"។ ប៉ុន្តែមិនទាន់មានការបង្ហាញថាតើចំណារ "ក.ទ" ហ្នឹងមានន័យថា "កម្ទេច" ឬក៏ដែលថាពាក្យថា "កម្ទេច" ហ្នឹងមានន័យថា "សម្លាប់" នោះទេ។ ហើយខ្ញុំសង្កេតឃើញថា មានកាលបរិច្ឆេទសម្លាប់អ្នកទោសម្នាក់ គឺសរសេរថាថ្ងៃ០៨ មករា ៧៩ ហើយយើងដឹងថា គឺ១ថ្ងៃក្រោយវៀតណាមបានជ្រៀតចូលលុកលុយ។ គឺអង់គ្លេសមានលេខ 00323948, ខ្មែរ 00068025 បារាំងមានលេខ 00778863។

ហើយជាចុងក្រោយ ខ្ញុំសូមកត់សម្គាល់ថា ឯកសារច្បាប់ដើមរបស់ខ្មែរ មិនមែនជាឯកសារច្បាប់ដើមនោះទេ ប៉ុន្តែគ្រាន់តែជាការថតចម្លងដែលអន់តែប៉ុណ្ណោះ។ ហើយឯកសារ -- ហើយអ្នកបកប្រែខ្មែរអង់គ្លេសលើកទី១ ជឿជាក់ពួកគេមិនអាចបកប្រែឯកសារ ហើយគេដាក់ឯកសារទៅក្នុងសំណុំរឿង ដែលបញ្ជាក់ថា ឯកសារហ្នឹងមិនអាចមើលបាន ហើយថាមិនមានការបកប្រែ។

[១០:៣៨:០៩]

លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំសូមបញ្ចប់ផ្នែកទី១នៃបទបង្ហាញរបស់ខ្ញុំ ហើយខ្ញុំសូមបន្តទៅផ្នែកទី២ គឺស្ថានភាពរស់នៅ និងស្ថានភាពការងារ។ នៅក្នុងស្រុកត្រាំកក់ ក៏ដូចជា

សហករណ៍ត្រាំកក់ ហើយខ្ញុំគិតថា នេះជាផ្នែកខ្លីដែលខ្ញុំបង្ហាញតែឯកសារចំនួនប្រាំពីរតែប៉ុណ្ណោះ។ ជាដំបូង ខ្ញុំចង់បង្ហាញឯកសារចំនួនពីរដែលផ្តល់ព័ត៌មានទាក់ទងទៅនឹងគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ទាក់ទងទៅនឹងសុខភាព។ គឺឯកសារ E3/226។ នេះ គឺជាកំណត់ត្រាកិច្ចប្រជុំ របស់ក្រសួងសុខាភិបាល និងសង្គមកិច្ច ចុះថ្ងៃ១០ មិថុនា ឆ្នាំ៧៦។ អង់គ្លេសមានលេខ 00183365 ហើយ ERN បញ្ចប់ត្រង់លេខ 67 និង 69, ខ្មែរមានលេខ 00017150 ហើយ ERN បញ្ចប់ត្រង់លេខ 52 និង 55 និងភាសាបារាំងមានលេខ 00296159 ហើយ ERN បញ្ចប់ត្រង់លេខ 61 និង 63។ នៅក្នុងកិច្ចប្រជុំនេះ មានរបាយការណ៍ជាច្រើនត្រូវបានគេធ្វើឡើងពាក់ព័ន្ធទៅនិងស្ថានភាពសុខភាព នៅក្នុងកម្ពុជាប្រជាធិបតេយ្យ រួមបញ្ចូលទាំងព័ត៌មានអំពី ខ្ញុំសូមដកស្រង់៖ “យើងអាចបែងចែកឱសថ ទៅមូលដ្ឋាន ដូចដែលមានចែងនៅក្នុងការណែនាំរបស់បក្ស។ រហូតមកដល់ពេលនេះ គឺមិនមានឱសថដែលខូចខាត ឬក៏បំផ្លាញដោយសារអគ្គីភ័យនោះឡើយ។ របបអាហារអាចដោះស្រាយដោយខ្លួនយើង ហើយយើងធ្វើ -- ហើយយើងត្បាញខោអាវសម្រាប់កងជាច្រើន។ នៅក្នុងខែឧសភា ឆ្នាំ៧៦ យើងមិនបានទៅយកត្រីពីក្រសួងពាណិជ្ជកម្មទេ យើងអាចគាំទ្រ -- យើងអាចរកបានដោយខ្លួនឯង”។ អង់គ្លេសមានលេខ 00183365, ខ្មែរមានលេខ 00017150 និងបារាំងមានលេខ 00296159។

[១០:៤០:១២]

ហើយការដកស្រង់បន្តគឺថា “យើងអាចផលិតថ្នាំគ្រុនចាញ់ ហើយនិងឱសថគ្រប់ប្រភេទ និងសេរ៉ូមផងដែរ។ ប៉ុន្តែយើងបានផ្អាកការផលិតថ្នាំមួយចំនួនដោយសារតែខ្វះវត្ថុធាតុដើម។ សមត្ថភាពក្នុងការផលិតឱសថ គឺស្របទៅនឹងអ្វីដែលអង្គការបានផែនការ”។ អង់គ្លេសមានលេខ 00183367, ខ្មែរមានលេខ 00017152, បារាំងមានលេខ 00296161។ ទោះបីថាខ្ញុំកត់សម្គាល់ឃើញផងដែរថាពាក្យ “អង្គការ” មិនមានបកប្រែនៅក្នុងភាសាបារាំង និងភាសាខ្មែរនោះឡើយ។ របាយការណ៍នេះបានបន្តរៀបរាប់ថា ពាក់ព័ន្ធទៅនឹងការផលិតឱសថ ខ្ញុំសូមដកស្រង់៖ “ក្នុងរយៈពេលមួយ ឬពីរខែកន្លងមក យើងបានទទួលការវិវឌ្ឍយ៉ាងច្រើន បទពិសោធន៍កាន់តែកើនឡើងក្នុងការផលិត និងការគ្រប់គ្រងគុណភាព ព្រមទាំងអ្នកដែលប្រតិបត្តិការម៉ាស៊ីនផលិតឱសថផងដែរ”។ អង់គ្លេសមានលេខ 00183 367, ខ្មែរមានលេខ 00017152 និងបារាំងមានលេខ 00296161។ ជាសង្ខេបឯកសារនេះ បានសន្និដ្ឋានថា បញ្ហាសុខភាពគឺត្រូវបានលុបបំបាត់ចោលយ៉ាងច្រើនប្រសិនបើធៀបទៅនឹងឆ្នាំមុន។ ប៉ុន្តែនៅតែមានកង្វះឱសថជាច្រើនសម្រាប់ប្រជាជន ហើយនិងជំងឺសត្វក្នុងស្រុក។ បន្ទាប់ពីសង្គ្រាម បន្ទាប់

ពីមានការបំពុលទៅលើជីវភាពប្រជាជន និងសត្វធ្វើឲ្យមានការគ្រោះថ្នាក់។ ឯកសារមានលេខ 00183369 ភាសាអង់គ្លេស, 0017155 ខ្មែរ និង 00296163 បារាំង។

[១០:៤២:០៨]

ឯកសារបន្តទៀតគឺឯកសារដែលមានលេខ E3/166 គឺជាទស្សនាវដ្តីទង់បដិវត្តលេខ២ និង ៣ ចុះខែកុម្ភៈ មីនា ឆ្នាំ៧៦។ អង់គ្លេសមានលេខ ERN 00517833 ដល់34, ខ្មែរមានលេខ 00063214 ដល់17 និងបារាំងមានលេខ 00492779 ដល់ 80។ ទស្សនាវដ្តីទង់បដិវត្តនេះបានរាយការណ៍ដូចតទៅនេះ ខ្ញុំសូមដកស្រង់ "ដោយសារតែឱសថសម័យមិនមានច្រើន ក្នុងតួនាទីជាថ្នាក់ដឹកនាំកម្មាភិបាល ត្រូវគិតអំពីបរិមាណគ្រប់គ្រាន់នៃឱសថបុរាណគ្រប់ប្រភេទឱសថ ដើម្បីព្យាបាល និងរក្សាសុខភាពប្រជាជនក្នុងពេលដែលប្រយុទ្ធ នៅពេលដែលតស៊ូដើម្បីបង្កើត ជីកទំនប់ លើកប្រឡាយ ក្នុងរដូវប្រាំង។ ហើយចំពោះការស្តុកទុក គឺថាប្រជាជនយើងក៏មាន ក៏បានពួតដៃគ្នាដើម្បីវាយប្រយុទ្ធក្នុងការដាំដុះក្នុងរដូវវស្សា។" មានការកត់សម្គាល់ផងដែរថា ក្រសួងសង្គមកិច្ចនិងសុខាភិបាលត្រូវគិតអំពីប្រទេសទាំងមូលផងដែរ។

លោកប្រធាន លោក លោកស្រីចៅក្រម ទាក់ទងទៅនឹងបញ្ហាឱសថនិងមន្ទីរពេទ្យគឺជាអាទិភាពរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយគឺថា មិនអាចមានការ -- ហើយមិនមានការបង្ហាញណាមួយថាប្រព័ន្ធគោលនយោបាយហ្នឹងបដិសេធមិនឲ្យប្រជាជនថ្មីទទួលឱសថ និងមន្ទីរពេទ្យនោះឡើយ។

ចំណុចបន្ត គឺខ្ញុំនិយាយអំពីគោលការណ៍ណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជាអំពីអាកប្បកិរិយាដែលមិនអាចទទួលយកបាន។ នេះគឺជាអាកប្បកិរិយាដែលអាចទទួលយកបាន និងមិនអាចទទួលយកបានរបស់ប្រជាជន និងកម្មាភិបាលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំសូមបង្ហាញឯកសារចំនួនបួននៅក្នុងប្រភេទនេះ។ ទី១ គឺឯកសារដែលរៀបរាប់អំពីទស្សនៈទូទៅរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាចំពោះប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន។ ឯកសារ E3/216 ជាកំណត់ត្រាគណៈអចិន្ត្រៃយ៍ចុះថ្ងៃ២៤ ខែសីហា ៧៥ អង់គ្លេសមានលេខ 00850976, ខ្មែរមានលេខ 00008489 និងបារាំងមានលេខ 00343377។ នៅក្នុងឯកសារនេះ មានការសរសេរថា ខ្ញុំសូមដកស្រង់៖ "យើងចង់និយាយអំពីភាគច្រើនលើសលប់នៃប្រជាជនថ្មី និងប្រជាជនមូលដ្ឋានដែលល្អ"។ សូមបញ្ចប់ការដកស្រង់។ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាក៏បានផ្តល់នូវគោលការណ៍ណែនាំយ៉ាងប្រុងប្រយ័ត្នក្នុងរបបកម្ពុជាប្រជាធិប-តេយ្យអំពីអាកប្បកិរិយាដែលមិនល្អ ដែលត្រូវកែប្រែ។

[១០:៤៥:១៧]

ឯកសារបន្ទាប់គឺ E3/10 ជាទស្សនាវដ្ដីទង់បដិវត្តចុះខែសីហា -- ខែកញ្ញា និងតុលា ឆ្នាំ៧៦។ អង់គ្លេសមានលេខ 00450530, ខ្មែរមានលេខ 00063061 និងបារាំងមានលេខ 00491892។ នៅក្នុងទស្សនាវដ្ដីនេះ "ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានសង្កត់ធ្ងន់ការប្រឆាំងគ្នាផ្ទៃក្នុង ដែលត្រូវតែដោះស្រាយ ដែលជាការទំនាស់ផ្ទៃក្នុង។ ពួកគេ គឺជាសាច់ឈាមរបស់យើង ពួកគេមិនមែនជាអ្នកប្រឆាំងបដិវត្តន៍នោះទេ។ ពួកគេមិនបានបង្កឲ្យមានការប្រឆាំងបដិវត្តន៍នោះឡើយ។ ការប្រឆាំងនេះ គឺដោយសារតែការយល់ខុស ដូច្នេះយើងត្រូវតែដោះស្រាយដោយការអប់រំជាបន្តបន្ទាប់"។ សូមបញ្ចប់ការដកស្រង់។ ថាតើយើងត្រូវដោះស្រាយយ៉ាងដូចម្ដេចនោះ ទស្សនាវដ្ដីទង់បដិវត្តបាននិយាយពន្យល់ដូចតទៅនេះ៖ វិធីសាស្ត្រមួយ គឺនឹងត្រូវអប់រំ ត្រូវធ្វើការងារនយោបាយ មនោគមវិជ្ជា និងអង្គការនៅក្នុងគោលការណ៍រួមដើម្បីកាត់បន្ថយ ឬក៏បញ្ឈប់ការប្រឆាំង ហើយមិនត្រូវឲ្យមានការប្រឆាំងមុតមាំនោះទេ។ នៅក្នុងឯកសារ E3/746 ជាឯកសារបន្ទាប់នោះ គឺជាទស្សនាវដ្ដីទង់បដិវត្ត ចុះខែកក្កដា ឆ្នាំ៧៨ ហើយខ្ញុំសូមអាន នៅត្រង់ភាសាអង់គ្លេសមានលេខ 00428305, ខ្មែរមានលេខ 006450 ខ្ញុំគិតថាលេខនេះខុសហើយ ខ្ញុំនឹងផ្ដល់លេខថ្មីនៅពេលបន្តិចទៀតនេះ និងភាសាបារាំងមានលេខ 00611 888។ មេដឹកនាំបក្សបានបញ្ជាថា ខ្ញុំសូមដកស្រង់ "ចាំបាច់ត្រូវប្រុងប្រយ័ត្នអំពីគោលជំហរ និងអាកប្បកិរិយាក្នុងការអនុវត្តការងារក្នុងចំណោមការិយាល័យអ្នកដឹកនាំ អាជ្ញាធរយោធា សេរីភាព និងឯកចិត្ត គឺជាបែបបទនៃការមិនទទួលខុសត្រូវអ្វីទាំងអស់ចំពោះបក្ស ចំពោះបដិវត្តន៍ និងចំពោះប្រជាជន"។ សូមបញ្ចប់ការដកស្រង់។

ហើយទស្សនាវដ្ដីទង់បដិវត្ត ខែកក្កដា ឆ្នាំ៧៦ គឺ E3/4 អង់គ្លេសមានលេខ 00268924 ហើយខ្ញុំសូមអភ័យទោសដោយសារតែភាសាខ្មែរមានតិចជាងគឺ 0062918 ហើយឯកសារមុនគឺ 006450 ហើយភាសាបារាំងនៃឯកសារ E3/4 គឺ 00349978។ ទស្សនាវដ្ដីមួយនេះ បានពន្យល់ថា ខ្ញុំសូមដកស្រង់៖ "ដើម្បីកសាងសាខាបក្សនៅក្នុងសហករណ៍ វាចាំបាច់ត្រូវលុបបំបាត់ចោលទស្សនៈឆ្វេងនិយម ឬក៏ស្ដាំនិយម។ ឆ្វេងនិយម មានន័យថា មិនជឿជាក់ទៅលើសមូហភាព មិនឲ្យតម្លៃទៅលើចលនាសមូហភាព ហើយឃើញថា សមូហភាពជាខ្លាំង។ ស្ដាំនិយម មានន័យថា បន្តធ្វើដោយមិនប្រុងប្រយ័ត្នដោយមិនផ្អែកទៅលើមូលដ្ឋាននៃលក្ខន្តិកៈបក្ស"។

[១០:៤៩:០៤]

*(សម្រាករយៈពេលខ្លី)*

*(គ្មានការបកប្រែ)*

[១០:៤៩:៥៧]

**ប្រធានអង្គជំនុំ៖**

ម្តងទៀតបញ្ជាក់លេខ ERN ម្តងៗ ទៀតអត់បានមានការបកប្រែភាសាខ្មែរទេ។

**លោក វ៉ិចទ័រ កូប៉េះ**

ខ្មែរ ERN នៃ E3/4741, 00064500 ហើយខ្មែរនៃ E3/4 នឹងផ្តល់នាពេលបន្តិចទៀតនេះ។ លោកប្រធាន លោក លោកស្រីចៅក្រមឯកសារចុងក្រោយដែលខ្ញុំចង់បង្ហាញនៅក្នុងផ្នែកទី២ នៃបទបង្ហាញនេះគឺចម្លើយសារភាពនៅមន្ទីរស-២១របស់ឈ្មោះ ជូ ជេត ដែលជាអតីតលេខាភូមិភាគបស្ចិម។ ខ្ញុំឃើញកាលពីម្សិលមិញព្រះរាជអាជ្ញា--

**ប្រធានអង្គជំនុំ៖**

ផ្អាកៗបន្តិចសិនលោក វ៉ិចទ័រ កូប៉េ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កូប៉េ តើការប្រើប្រាស់ឯកសារនេះមានគោលដៅអី? វាមិនពាក់ព័ន្ធទៅនឹងអ្វីដែលយើងកំពុងតែពិនិត្យទេ វាពាក់ព័ន្ធទៅនឹងស-២១។ អ៊ីចឹងសូមលោកបញ្ជាក់បន្តិចមើល មុននឹងលោកយោងទៅលើឯកសារនេះនោះ។

**លោក វ៉ិចទ័រ កូប៉េះ**

បាទ ប៉ុន្តែអ្វីដែលខ្ញុំចង់ដកស្រង់យកមកពេលនេះ គឺពាក់ព័ន្ធដោយផ្ទាល់ទៅនឹងតំបន់១៣ និងតំបន់១០៥។

[១០:៥១:៣៣]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កូប៉េ តើលោកចង់អានខ្លឹមសារនៃចម្លើយសារភាពរបស់ ជូ ជេត ដែលគាត់បានឆ្លើយនៅស-២១ ឬមួយក៏យ៉ាងម៉េច? តើលោកដឹងទេថា ឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្មនេះគឺជាចោទប្រកាន់ទៅលើជនជាប់ចោទ ហើយដែលវាស្ថិតនៅ -- វាពាក់ព័ន្ធនឹងទារុណកម្មដែលប្រព្រឹត្តនៅស-២១។

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំដឹងអំពីចំណុចទាំងអស់នេះ ប៉ុន្តែខ្ញុំចង់បង្ហាញដូចគ្នា គឺដូចនឹងអ្វីដែលព្រះរាជអាជ្ញាបានធ្វើកាលពីម្សិលមិញ គឺអាននូវផ្នែកសម្រង់តូចមួយនៃចម្លើយសារភាពរបស់អ្នកជាប់ឃុំ ហើយឃ្លានេះពាក់ព័ន្ធទៅនឹងស្រុកត្រាំកក់ និងតំបន់១៣។ ដូច្នេះ តាមជំហររបស់ខ្ញុំ គឺថាព្រះរាជអាជ្ញាគេអនុញ្ញាតឲ្យអានបាន គឺអាននូវចម្លើយសារភាពពីក្រាំងតាចាន់។ ដូច្នេះយើងក៏អាចធ្វើដូចគ្នា ហើយយើងក៏អាចអានពាក់ព័ន្ធទៅនឹងចម្លើយសារភាពស-២១ របស់ ជូ ជេត នៅពេលដែលគាត់និយាយអំពី សោម ដែលជាលេខាតំបន់១៣, តាគៀត, តាគារ, សោម អនុរបស់ សោម ផែន ហើយនិង តាគារ ជាសមាជិករបស់ស្រុកត្រាំកក់ជាដើម។ ដូច្នេះ ខ្ញុំចង់បញ្ជាក់ថា មិនមានអ្វីខុសគ្នារវាងព្រះរាជអាជ្ញាបានធ្វើ ដោយអាននូវសម្រង់នៃចម្លើយសារភាព ដើម្បីបង្ហាញពីអ្វីដែលគាត់ចង់និយាយ ហើយខ្ញុំៗអាននូវសម្រង់ចេញពីចម្លើយសារភាពរបស់ ជូ ជេត ដើម្បីបង្ហាញពីចំណុចរបស់យើង។

[១០:៥៣:១៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ គឺយើង -- គឺថាវាខុសគ្នាឆ្ងាយណាស់ រវាងអ្វីដែលខ្ញុំបានធ្វើ និងអ្វីដែលមេធាវី កូប៉េ ប្រុងនឹងធ្វើ។ ជាដំបូងគឺយើងអានអំពីសៀវភៅសួរចម្លើយដែលបញ្ជាក់ច្បាស់នៅក្នុងអ្វីដែលខ្ញុំអាននោះ។ នេះគឺជាចម្លើយសារភាពខុសគ្នា ដែលចុះហត្ថលេខាដោយអ្នកទោស។ ការកំណត់អត្តសញ្ញាណអ្នកទោស ក៏ដូចជាចម្លើយដែលៗថាអ្នកសួរចម្លើយគាត់ថា "ហេតុអ្វីបានជាគេចាប់ខ្លួន?" គឺជាភស្តុតាងអាចទទួលបាន។ ប៉ុន្តែអ្វីដែលលោក កូប៉េ ចង់ធ្វើគឺអាននូវចម្លើយសារភាពនៅក្នុងចំណុចកណ្តាលនៃសារភាពរបស់ ជូ ជេត ហើយធ្វើការអះអាងថា កម្មាភិបាលមួយចំនួនមកពីនិរតីគឺជាជនក្បត់។ គាត់ចង់ប្រើប្រាស់ ហើយខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់ផងដែរថា នួន ជា ដែលនៅក្នុងសាលសវនាការនេះគ្រាន់តែចង់ផ្តល់យុត្តិកម្មអំពីការសម្លាប់មនុស្ស ដោយផ្អែកទៅលើចម្លើយសារភាពជាចម្លើយសារភាពដែលទទួលបាននូវការធ្វើទារុណកម្មប៉ុណ្ណោះ។ គឺថាមិនមានអ្វីដែលអាចធ្វើទៅបានទេ អនុវត្តតាមអនុសញ្ញាអំពីការធ្វើទារុណកម្ម។ អនុសញ្ញាស្តីពីការធ្វើទារុណកម្ម គឺហាមឃាត់មិនឲ្យការ -- មិនឲ្យពឹងផ្អែកទៅលើចម្លើយសារភាពដែលទទួលបានដោយការធ្វើទារុណកម្មនោះឡើយ។ ដូច្នេះ ការដែលនិយាយថា យើងធ្វើដូចគ្នានោះ គឺជារឿងមិនត្រឹមត្រូវទាល់តែសោះ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន តើខ្ញុំអាចនិយាយបានទេ? យើងបានធ្វើបណ្ដឹងសាទុក្ខទៅលើមូលដ្ឋានតែមួយនេះ គឺការប្រើប្រាស់ចម្លើយសារភាពដោយសារទារុណកម្ម។ ប៉ុន្តែបញ្ហាគឺថា ៗតើធាតុផ្សំមួយចំនួនអាចចាត់ទុកថាជាឯកសារដែលទទួលបានដោយការធ្វើទារុណកម្ម ឬក៏អត់។ ហើយគោលដៅរបស់យើង ឥឡូវនេះ ត្រូវបានតវ៉ា កំពុងតែពិភាក្សាដោយអង្គជំនុំជម្រះតុលាការកំពូល ប៉ុន្តែខ្ញុំមិនឃើញថាហេតុអ្វីបានជាព្រះរាជអាជ្ញាត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ចម្លើយសារភាពពីក្រាំងតាចាន់ ចំណែកយើងបែរជាមិនអនុញ្ញាតឲ្យប្រើប្រាស់ចម្លើយសារភាពទៅវិញបាន។ ហេតុអ្វី?

[១០:៥៦:០៩]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៥៧:៣៣]

**ប្រធានអង្គជំនុំ៖**

សូមជម្រាបលោកមេធាវី វ៉ិចទ័រ កូប៉េ ថាបច្ចុប្បន្ននេះ នាពេលនេះ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកអាននូវផ្នែកខ្លឹមសារនៃកំណត់ហេតុដែលបានមកពីការធ្វើទារុណកម្មទេ។ បញ្ជាក់ថាកាលពីអង្គជំនុំជម្រះអនុញ្ញាតឲ្យព្រះរាជអាជ្ញាអាន គឺពាក់ព័ន្ធតែនឹងការកំណត់អត្តសញ្ញាណ និងអនុញ្ញាតឲ្យអានតែចំណារប៉ុណ្ណោះ គឺបញ្ជាក់ច្បាស់លាស់ហើយកាលពីម្សិលមិញ។ អ៊ីចឹងវាមានភាពខុសគ្នាឆ្ងាយរវាងគោលបំណងដែលលោកអានទៅលើខ្លឹមសារ គឺអង្គជំនុំជម្រះមិនអនុញ្ញាតទេ ព្រោះអាហ្នឹងគឺច្បាប់ហាមឃាត់មិនឲ្យប្រើប្រាស់នូវលទ្ធផល ដែលបានមកពីការធ្វើទារុណកម្មយកមកធ្វើជាមូលដ្ឋានក្នុងការសួរដេញដោលទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ដូច្នេះ ខ្ញុំត្រូវបន្តទៅមុខទៀតគឺថា ខ្ញុំមិនអាចប្រើប្រាស់នូវចម្លើយសារភាពដែលវាមិនចាំបាច់ពាក់ព័ន្ធទៅនឹងការធ្វើទារុណកម្មនោះ ប៉ុន្តែខ្ញុំនឹងបន្តទៅមុខទៀត។ បាទដើម្បីឲ្យបានទាន់ពេលវេលា លោកប្រធាន ខ្ញុំសូមចូលទៅឯកសារ E3/294 គឺឯកសារពាក់ព័ន្ធទៅនឹងក្រុមថៃហ្គឺរគ្រុបគឺ -- ក្រុមគោលដៅ ពាក់ព័ន្ធទៅនឹងមន្ត្រី និងទាហាននៃរបប លន់ នល់។ ហើយនៅក្នុងផ្នែកនៃសវនាការនេះ គឺថាតែងតែមានការពាក់ព័ន្ធទៅនឹងខ្មែរក្រោម ខ្ញុំក៏លើកឡើងនូវចំណុចនេះផងដែរ។ ដូចដែលបានលើកឡើងកាលពីម្សិលមិញ ថាតើខ្មែរក្រោមគឺជាក្រុមគោលដៅ ឬក៏អត់នៅក្នុងសំណុំរឿង០០២/០២។ ប៉ុន្តែ

ពាក់ព័ន្ធទៅនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះដែលត្រូវចេញនៅក្នុងពេលសមស្របនោះ ខ្ញុំសូមលើកនូវឯកសារពីរដែលពាក់ព័ន្ធគឺ E3/294 គឺសេវាផ្សាយព័ត៌មានអន្តរជាតិ – កម្រងសេវាព័ត៌មានអន្តរជាតិ ចុះខែតុលា ១៩៧៨ ដែលរាយការណ៍អំពីសេវាផ្សព្វផ្សាយពីទីក្រុងភ្នំពេញដែលស្ដីអំពីដំណើរទស្សនកិច្ចមិត្តភាពជប៉ុន សមាគមមិត្តភាពជប៉ុនមកកាន់តំបន់និរតីគឺ ERN ជាភាសាអង់គ្លេស 00170173 ហើយយើងមិនទាន់មានការបកប្រែជាភាសាខ្មែរ និងភាសាបារាំងនៅឡើយទេ។ ឯកសារ E3/294 និយាយលម្អិតថា តើប្រតិភូនេះបានធ្វើដំណើរទៅកាន់ខេត្តតាកែវ ហើយថាតើមានខ្មែរក្រោមដែលពាក់ព័ន្ធទៅនឹងការធ្វើទុក្ខបុកម្នេញពីសំណាក់ប្រទេសវៀតណាមឬក៏អត់នោះទេ។ សូមដកស្រង់ "គឺថាបានមកសុំការជ្រកកោននៅក្នុងស្រុកគិរីវង់។" របាយការណ៍បន្តទៅទៀតថា ដំណើរទស្សនកិច្ចមិត្តភាពជប៉ុននេះគឺមានការរន្ធត់ នៅពេលដែលដឹងរឿងរ៉ាវដែលត្រូវបានខ្មែរក្រោមរៀបរាប់ថា មានការសម្លាប់រង្គាល និងអំពើសម្លាប់សាហាវព្រៃផ្សៃពីសំណាក់វៀតណាម ក្នុងគោលបំណងបំបាត់ជាតិខ្មែរ ដែលជាការរើសអើង និងជាចរិតមួយសាហាវព្រៃផ្សៃ។ ដូចដែលសហព្រះរាជអាជ្ញាកាលពីម្សិលមិញ គឺរបាយការណ៍ចេញមកពីមេឃុំអង្គតាសោម ចុះថ្ងៃទី០៦ មេសា ៧៧ រាយការណ៍ទៅមន្ទីរស្រុកត្រាំកក់ ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តទៅដល់ក្រុមគ្រួសារខ្មែរវៀតណាម។ ERN ជាភាសាអង់គ្លេស 00322141, ខ្មែរ 0027 1001 និងបារាំង 00612225។ សំណើសុំនេះនិយាយលម្អិតអំពីស្ថានភាពនៃប្ដីប្រពន្ធខ្មែរវៀតណាមដែលបានស្នើសុំការអនុញ្ញាតត្រឡប់ទៅប្រទេសវៀតណាម។ មានការកត់សម្គាល់ថា ប្ដីប្រពន្ធខ្មែរដែលរៀបការជាមួយប្ដីប្រពន្ធ ហើយនិងប្រពន្ធយួនរៀបការជាមួយនឹងប្ដីខ្មែរ គឺថានឹងបញ្ជូនទៅអង្គការស្នើសុំចង់ដឹងថា "តើប្រសិនណាដូច្នេះ តើអង្គការត្រូវសម្រេចដូចម្ដេច សូមផ្ដល់មតិមកដល់យើងខ្ញុំ"។ បញ្ចប់ការដកស្រង់។

[១១:០២:០៥]

ផ្នែកទី២ ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តមកលើពុទ្ធសាសនិកជន។ មានឯកសារពីរ ហើយយើងមានឯកសារមួយ និងវីដេអូឃ្លីបមួយពាក់ព័ន្ធទៅនឹងការប្រព្រឹត្តមកលើពុទ្ធសាសនិកជន ដែលខ្ញុំត្រូវបង្ហាញ។ ខ្ញុំសូមចាប់ផ្ដើមជាមួយនឹងខ្សែវីដេអូ ដែលជាវីដេអូ E3/3201R។ វីដេអូនេះនិយាយអំពីដំណើរទស្សនកិច្ចរបស់មេដឹកនាំជាន់ខ្ពស់វៀតណាមមកកាន់កម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ១៩៧៥។ ដូចដែលបង្ហាញនៅក្នុងខ្សែវីដេអូ គឺប្រតិភូមានការពេញចិត្តនូវព្រះបរមរាជវាំង និងរូបសំណាកព្រះពុទ្ធដែលមាននិយាយរៀបរាប់បង្ហាញថា ថ្នាក់ដឹកនាំសំខាន់ៗបក្សកុម្មុយនីស្តកម្ពុជាក៏បានចូលរួម ក្នុងនោះមាន នួន ជា, ប៉ុល

ពត ហើយនិងសមាជិកនៃគណៈអចិន្ត្រៃយ៍ សមាជិកដទៃទៀតនៃគណៈអចិន្ត្រៃយ៍។ ហើយខ្ញុំសូមលើកឡើងអំពីការអត្ថាធិប្បាយនេះ បញ្ជាក់អំពីថា ប្រជាជនកម្ពុជាភាគច្រើនគឺជាពុទ្ធសាសនិកជន។ លោកប្រធានខ្ញុំសូមស្នើសុំអង្គជំនុំជម្រះ និងអង្គភាព អេ.វី មេត្តាចាក់ខ្សែវីដេអូចាប់ផ្ដើមនៅនាទី ០៦:៣០ ដល់ ០៨:៥៥ ២នាទីកន្លះ ហើយបើសិនជាចាប់ផ្ដើមនោះ គឺថាយើងហៅថាវាជាឯកសារមួយដែលស្ថិតនៅក្នុងវីដេអូឃ្លីបទី១។

[១១:០៤:១៧]

*(ការបង្ហាញឯកសាររូបភាព-សំឡេង)*

*"ប្រជាជនកម្ពុជាភាគច្រើនកាន់ព្រះពុទ្ធសាសនា និងមានជំនឿយ៉ាងមាំទៅលើវណ្ណសិរ្សរួបរួមជាតិក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្ត ប្រជាជនកម្ពុជាបានដំណើរការតស៊ូដ៏ក្លាហានមោះមុត បានកាប់បំបាក់ការវាយសម្រុកឈ្លានពានរបស់កងទ័ពអាមេរិកាំង១០ម៉ឺនក្បាល រួមទាំងបរិវារវាតាំងពីឆ្នាំ១៩៧០។ តទល់នឹងរាល់យុទ្ធនាការទម្លាក់គ្រាប់បែក យ៉ាងគគ្រឹកគគ្រេងរបស់ អាបេ៥២ ជាកម្លាំងអាកាសរបស់ចក្រពត្តិអាមេរិក ធ្វើឲ្យបរាជ័យនូវផែនការក្នុងខ្មែរូបនីយកម្មរបស់ចក្រពត្តិអាមេរិក។ ហើយនៅទីបំផុត ក្រោយរយៈកាលជាង១០០ថ្ងៃ ដែលធ្វើការវាយសម្រុកយ៉ាងខ្លាំងក្លាដូចព្យុះសង្ឃរាមកបណ្ដាកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជាបានកម្ទេចកងទ័ពអាយ៉ងបានរាប់សែនក្បាល រំដោះទឹកដីកម្ពុជាបានទាំងស្រុងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នាំមកនូវសុខសន្តិភាពជូនមាតុភូមិ។*

*ទស្សនកិច្ចជាមិត្តភាពនៅកម្ពុជារបស់គណៈប្រតិភូបក្សពលករវៀតណាមក្នុងលើកនេះ មានអត្ថន័យសំខាន់ពិសេសបំផុត វាបានប្រព្រឹត្តទៅក្នុងពេលដែលសភាពការណ៍នៅវៀតណាម កម្ពុជា និងលាវ មានការប្រែប្រួលជាសារវន្ត។ ការតស៊ូរបស់ប្រជាជនទាំងបីប្រទេសបានដណ្ដើមយកបានជ័យជម្នះយ៉ាងធំសម្បើម។ បុព្វហេតុបដិវត្តន៍របស់ប្រជាជនទាំងបីប្រទេសនៅឥណ្ឌូចិន បានឈានចូលក្នុងដំណាក់កាលមួយថ្មីព្រមជាមួយនឹងសេចក្ដីសង្ឃឹម ចំពោះអនាគតយ៉ាងភ្លឺចិញ្ចែង ពុំធ្លាប់ដែលមានក្នុងប្រវត្តិសាស្ត្រ។*

*ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាដោយមានសមមិត្តអគ្គលេខា សាឡុត ស ជាប្រមុខក្នុង៣ខែកន្លងមក ប្រជាជនកម្ពុជាជាង..."។*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១១:០៦:៥០]

**លោក វ៉ិចទ័រ កូប៉េះ**

ឯកសារបន្ទាប់មកទៀតដែលខ្ញុំសូមបង្ហាញផងដែរគឺ ឯកសារ E3/2818 ជាសៀវភៅមកពី អៀន ហារីស និយាយអំពីព្រះពុទ្ធសាសនានៅក្រោមរបប ប៉ុល ពត។ ERN ជាភាសាអង់គ្លេស 00704011 បាទ 00704011 ដល់ 033 ដល់, 5318 ដល់ 21, 083 ដល់ 4, ដល់ 9892 ដល់ 996 និង ១៧ ហើយសៀវភៅនេះ ជាភាសាខ្មែរបកប្រែបានតែមួយផ្នែកតូចតែប៉ុណ្ណោះ។ ដូច្នេះខ្ញុំលើកឡើងនៅត្រង់ចំណុចដែលបានបកប្រែនេះ។ អៀន ហារីស បានលើកឡើងអំពីបញ្ហាការប្រព្រឹត្តមកលើព្រះពុទ្ធសាសនិកជន ដូចជា ការទម្លាប់គ្រាប់បែករបស់សហរដ្ឋអាមេរិក មកលើវត្តអារាមផ្សេងៗ ហើយលោកសង្ឃក៏ត្រូវបានគេប្រើប្រាស់ជាគិញនៅក្នុងរបបសាធារណរដ្ឋខ្មែរ។ ហារីស បានកត់សម្គាល់ថាក្នុងអំឡុងសង្គ្រាមស៊ីវិល មួយភាគបីនៃវត្ត គឺត្រូវបានបំផ្លិចបំផ្លាញដោយការទម្លាក់គ្រាប់បែករបស់អាមេរិកាំង។ ERN ភាសាអង់គ្លេស 00704015 ដល់ 7, ខ្មែរ 00791318 ដល់ 21 ដែលជាក្រុមគោលដៅសម្រាប់គោលបំណងជាក់លាក់ណាមួយនោះ គឺមាន ERN ជាភាសាអង់គ្លេស 00704083។ អៀន ហារីស ក៏បានសរសេរផងដែរ ថាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានទីតាំងដែលប្រជាជនត្រូវបានអនុញ្ញាតឲ្យគោរពបូជាព្រះពុទ្ធ គោរពព្រះពុទ្ធសាសនានៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ។ ERN ភាសាអង់គ្លេស 00704011 និង ERN 00704033 ដល់ 5។ ERN ក៏លើកឡើងផងដែរថាក្រៅពីការបាត់បង់ដ៏ធំធេងរបស់ប្រជាជនយើង គឺថាមិនមានគោលបំណងរបបកម្ពុជាប្រជាធិបតេយ្យណាមួយដើម្បីធ្វើបាបមកលើព្រះពុទ្ធសាសនា របបកម្ពុជាប្រជាធិបតេយ្យទេ។ ហើយ ERN ជាភាសាអង់គ្លេស 00704083។

[១១:០៩:២៨]

ហើយលើសពីនេះទៅ អៀន ហារីស បានកត់សម្គាល់ថា កាលដែលរបបសារធារណរដ្ឋខ្មែរបានប្រើប្រាស់ព្រះសង្ឃជាគិញៗ គឺត្រូវបានចាប់ខ្លួន និងសម្លាប់ដោយសារតែពួកព្រះសង្ឃទាំងនោះជាគិញ។ អាចរកបានចំណុចនេះត្រង់ ERN 00703892 និង 00703996 ដល់ 7។ នៅពេលដែលលោកសង្ឃត្រូវបានគេធ្វើគុត ហារីស បាននិយាយ សូមដកស្រង់៖ “មិនមែនជាចម្បងនោះទេ ដោយសារតែគេបានបូជាទៅនឹងពាក់ព័ន្ធនឹងព្រះពុទ្ធសាសនា ប៉ុន្តែទាក់ទងទៅនឹងអ្វីដែលគឺថាត្រូវលោកសង្ឃទាំងនោះត្រូវបានគេចាត់ទុកថាជាខ្មាំង ដោយពាក់ព័ន្ធទៅនឹងរបបចាស់” គឺ ERN ភាសាអង់គ្លេស 00704084។

ហើយចុងក្រោយលោកប្រធាន អៀន ហារីស សៀវភៅ អៀន ហារីស នេះ ក៏សរសេរថា ២ឆ្នាំ

នៃការសិក្សាស្រាវជ្រាវបញ្ជាក់ថា "ចៅអធិការ ហើយនិងលោកសង្ឃត្រូវបានកម្រ មិនងាយនឹងត្រូវបានធ្វើគុតនោះទេ" មាននៅ ERN 00704084។ ដើម្បីបញ្ចប់ការបង្ហាញឯកសាររបស់ខ្ញុំ ខ្ញុំសូមបង្ហាញនូវខ្សែវីដេអូមួយទៀត លោកប្រធាន គឺពាក់ព័ន្ធទៅនឹងទាហាន និងមន្ត្រីរដ្ឋការនៃរបប លន់ នល់ នៅក្នុងពេលនៃសង្គ្រាម គឺឯកសារ E3/3116R។ អ្វីដែលខ្ញុំចង់លើកយកមកបង្ហាញនៅពេលនេះ គឺជាសម្រង់របស់អ្នកកាសែតអូស្ត្រាលីមួយ គឺខ្សែភាពយន្តឯកសារហៅថា *"ឌឺ ប្លាដឌីស ដូមីណូ"* ហើយសម្រង់ពាក់ព័ន្ធនេះ គឺថាចាប់ផ្តើមពីនាទី២២:២២ ដល់នាទី២៤:១១។ ហើយខ្សែភាពយន្តឯកសារនេះ និយាយអំពីការស៊ីថ្លើមខ្មាំង គឺថាវាជាទំនៀមទម្លាប់នៅក្នុងពេលសង្គ្រាមទៅហើយ នៅក្នុងប្រទេសកម្ពុជា ហើយការធ្វើបែបនេះ ក៏បានឃើញថា ជាការអនុវត្តមួយដែលត្រូវបានប្រព្រឹត្តឡើងដោយទាហាន លន់ នល់ នោះផងដែរ។ ដូច្នេះលោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្គាប់ឲ្យ អេ.វី យូនីត។

[១១:១១:៥០]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមឲ្យបង្ហាញភាពពាក់ព័ន្ធនៃខ្សែភាពយន្តឯកសារនេះផងលោកមេធាវី។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមានចំណុចដែលត្រូវលើកឡើង ក្រោយពេលពីការបញ្ចាំងខ្សែវីដេអូនេះរួចហើយ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមមេត្តាបង្ហាញភាពពាក់ព័ន្ធមុននឹងការចាក់បង្ហាញ ដើម្បីឲ្យងាយស្រួលក្នុងការសម្រេច។

**លោក វ៉ិចទ័រ កូប៉េ៖**

មន្ត្រីរដ្ឋការ និងទាហាន លន់ នល់ ក៏ត្រូវបានគេចោទប្រកាន់ថា អ្នកដែលមានការជួយដល់ព្រះពុទ្ធសាសនាតិចតួចបំផុត។ ខ្សែវីដេអូនេះនិយាយអំពីការអនុវត្តដោយចេតនាដ៏អាក្រក់ ដែលជាការប្រឆាំងនឹងមនុស្សធម៌។ ហើយនៅសាកលវិទ្យាល័យ *(ឮមិនច្បាស់)* គឺថាមានអនុវត្តដោយទាហាន លន់ នល់ ជាច្រើន ហើយយើងមានឯកសារខ្សែភាពយន្តនេះ ដើម្បីបង្ហាញជូនផងដែរ។ ហើយតាមការយល់ឃើញរបស់យើងខ្ញុំគឺថា យើងសូមបង្ហាញនៅក្នុងសវនាការនេះ ហើយយើងមិនចង់និយាយអំពីដំណើររឿងរ៉ាវអ្វីដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ។ ហើយយើងយកមកនៅក្នុងសវនាការនេះ គឺថាយើងត្រូវតែនិយាយបើកចំហពាក់ព័ន្ធនឹងខ្សែវីដេអូនេះ ដោយសារវាពាក់ព័ន្ធ ជាពិសេសទៅនឹងសក្ខីកម្មរបស់ សយ សែន។ ហើយដូច្នេះយើងខ្ញុំព្យាយាមបង្ហាញខ្សែវីដេអូនេះ ពីខាងដើមដែរ ហើយខ្ញុំ

ចាំថា អង្គជំនុំជម្រះបានបញ្ជាក់ថា មិនអាចយកមកបង្ហាញនៅពេលនោះបានទេ គឺបង្ហាញនៅពេលការជជែកអំពីឯកសារនេះ។ ការអនុវត្តនៃការស៊ីថ្នើមខ្មោច គឺត្រូវបានទាហាន លន់ នល់ ប្រព្រឹត្តឡើងជាញឹកញាប់។ យើងយកការអនុវត្តនេះ គឺថាយកមកប្រើប្រាស់នៅក្នុងបរិបទដែលពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់ សយ សែន។

ដូច្នេះខ្ញុំយល់ថា ទោះបីជាខ្សែវីដេអូនេះបង្ហាញនូវព្រឹត្តិការណ៍មុនឆ្នាំ១៩៧៥ក្តី ក៏ប៉ុន្តែវាមានភាពពាក់ព័ន្ធ ហើយវាមាននៅក្នុងសំណុំរឿងជាយូរមកហើយផងដែរ។ ដូច្នេះ យើងខ្ញុំយល់ឃើញថា យើងខ្ញុំត្រូវបាន គួរតែត្រូវបានអនុញ្ញាតឲ្យបង្ហាញចំណុចនេះ។

[១១:១៤:០៩]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:១៥:៥៤]

**ប្រធានអង្គជំនុំ៖**

ផ្តល់ភារៈជូនទៅលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ ដែលលើសំណើសុំរបស់មេធាវី វ៉ិចទ័រ កូប៉េ ចុងក្រោយនេះ។ សូមអញ្ជើញលោកស្រី ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អង្គជំនុំជម្រះរំពឹងថា គឺថាគំនិតយោបល់គឺវាមានគាំទ្រទៅដល់ទឡ្ហីករណ៍ ដើម្បីនិយាយពាក់ព័ន្ធបង្ហាញមូលហេតុនៃការសម្លាប់នេះ។ បើនិយាយអំពីការអនុវត្តជាក់ស្តែងនៃការហូបគ្រឿងក្នុងរបស់មនុស្សនោះគឺវាត្រូវពាក់ព័ន្ធនៅក្នុងបរិបទ។ ដូច្នេះយើងអនុញ្ញាតឲ្យបង្ហាញនូវផ្នែកដែលពាក់ព័ន្ធ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកស្រីចៅក្រម ហ្វេនស៍។ គឺសូម -- ដូច្នេះសូមឲ្យ អេ.វី ចាក់វីដេអូឃ្លីបផ្នែកពាក់ព័ន្ធនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ ផ្នែកខាងសោតទស្សន៍ចាក់នូវវីដេអូឃ្លីបទី២ ដែលតាមសំណើសុំរបស់លោកមេធាវី វ៉ិចទ័រ កូប៉េ មេធាវីការពារក្តីលោក នួន ជា។

[១១:១៧:១៦]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*"គឺថា គេបានស៊ីថ្លើមរបស់ខ្មាំងដែលមាន (ឮមិនច្បាស់) នៅក្នុងការធានាទៅដល់ភាពច្របូកច្របល់នេះ មានការសម្លាប់រង្គាលដែលត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងវៀតណាមដែលបានរស់នៅក្នុងប្រទេសកម្ពុជាអស់រាប់ជំនាន់មកហើយ។ នៅពេលដែលប្រជាជនវៀតណាម (ឮមិនច្បាស់) ជាច្រើនពាន់នាក់ត្រូវបានសម្លាប់ ប្រពៃណីទំនៀមទម្លាប់ក្នុងពេលសង្គ្រាម គឺបានបញ្ជាក់អំពីជោគវាសនារបស់ទាហាន។ និយាយទៅតាមវប្បធម៌វាមានចន្លោះប្រហោងខុសគ្នារវាងទស្សនៈលោកខាងលិច ហើយនិងគំនិតយោបល់ប្រទេសកម្ពុជានៅពេលនិយាយអំពីការវះ ការអារកាត់រាងកាយ ដើម្បីយកថ្លើមយកមកស៊ី។ នេះគឺជាទំនៀមទម្លាប់មួយ គឺថាកាលណាធ្វើបែបនេះ គឺមានន័យថា គេមានស្មារតី និងមានស្មារតីលើសលប់ទៅលើខ្មាំងរបស់ខ្លួន។ ហើយពេលខ្លះគេនឹងអញ្ជើញអ្នកឲ្យចូលទៅហូបថ្លើមរបស់ខ្មោចដែលគេបានសម្លាប់។ មានពេលមួយនោះគឺថា ខ្ញុំបានហូប មានអាហារមួយនោះជាមួយអភិបាលខេត្តម្នាក់គេមានខ្មោចរបស់វៀតកុង ខ្មោចវៀតកុងទាំងអស់នោះ គឺត្រូវបានគេវះយកស្លួត ថ្លើម--"។*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១១:១៩:១២]

**លោក វ៉ិចទ័រ កូប៉េ៖**

ហើយជាមួយវីដេអូឃ្លីបនេះផងដែរ គឺថាខ្ញុំក៏សុំបញ្ចប់តែត្រឹមនេះហើយលោកប្រធាន។ ខ្ញុំអស់ហើយ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសមស្របសម្រាកដែរហើយ។ បាទ អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាកថ្ងៃត្រង់ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:២០ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:០២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តទៅនេះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសដាក់បង្ហាញឯកសារគន្លឹះពាក់ព័ន្ធជាមួយនឹងអង្គហេតុសហករណ៍ត្រាំកក់ និងក្រាំងតាចាន់។

**លោក អាកទួរ វ៉េកកែន៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំនឹងធ្វើបទបង្ហាញជាច្រើនផ្នែក។ ជាបឋមខ្ញុំចាប់ផ្តើមតាមរយៈការអានសីលធម៌ទាំង១២ប្រការរបស់ខ្មែរក្រហមគឺនៅមុនឆ្នាំ១៩៧៥។ បន្ទាប់មកទៀត ខ្ញុំនឹងនិយាយអំពីបញ្ហាសហករណ៍ ដោយលើកឡើងអំពីឯកសារស្តីអំពីអំណាចខ្មែរក្រហម និងការ -- និងប្រវត្តិនៃការបង្កើតសហករណ៍។ នៅក្នុងផ្នែកទី៣ ខ្ញុំនឹងលើកឡើងអំពីឯកសារពាក់ព័ន្ធទៅនឹងការសន្និដ្ឋានអំពីចំនួនមនុស្សស្លាប់នៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ។ បន្ទាប់មកទៀត ខ្ញុំបើមានពេលខ្ញុំនឹងបញ្ចប់ការលើកឡើងអំពីបញ្ហាពាក់ព័ន្ធទៅនឹងរឿងរ៉ាវនៃកម្មាភិបាលមូលដ្ឋាន។

ពាក់ព័ន្ធទៅនឹងសីលធម៌១២ប្រការ វាជាការបង្ហាញនូវការប្តេជ្ញាចិត្តចំពោះ -- របស់ខ្មែរក្រហមចំពោះប្រជាជន គឺគ្រប់ប្រជាជន។ ដូច្នេះ គឺថាឃើញយើងឃើញថាមានការគោរពជីវិតមនុស្ស។ ខ្ញុំសូមយោងទៅលើបញ្ជីដែលធ្វើឡើងដោយលោក ហ្វ្រង់ស្វ័រ ប៉ុងសូដ៍ នៅក្នុងសៀវភៅរបស់គាត់គឺ "កម្ពុជាឆ្នាំសូន្យ" ដែលមានលេខ E243.1 ERN ជាភាសាបារាំង 00862201, ជាភាសាខ្មែរគឺ 00862433 ដល់ 34, ជាភាសាអង់គ្លេស 00862085 ដល់ 86។

[១៣:៣៥:០៣]

ខ្ញុំសូមដកស្រង់នូវបទអត្ថាធិប្បាយតូចមួយរបស់ ហ្វ្រង់ស្វ័រ ប៉ុងសូដ៍ ដែលគាត់សរសេរថា "ប្រជាជនប្តេជ្ញាដាច់ខាតជាឯកច្ឆន្ទយ៉ាងនេះ ដោយសម្អាងលើការប្រតិបត្តិតាមបញ្ញត្តិរបស់អង្គការ។ វិទ្យុក៏មានរៀបរាប់ពីបញ្ញត្តិទាំង១២ខដែរ។ ជនភៀសខ្លួនដែលរត់ចេញពីតំបន់រំដោះឆ្នាំ១៩៧៣ ធ្លាប់សូត្របញ្ញត្តិទាំងនេះ។ យោធាខ្មែរក្រហមដែលយាមស្ពានទូតបារាំងបន្ទាប់ពីរំដោះទីក្រុងភ្នំពេញក៏ធ្លាប់

សូត្របញ្ញត្តិទាំងនេះរៀងរាល់ព្រឹកដែរ។ ទី១) ត្រូវស្រឡាញ់ គោរព និងបម្រើប្រជាជន កម្មករ កសិករ។ ២) ទៅណាមកណាត្រូវបម្រើប្រជាជនឲ្យអស់ពីចិត្តពីថ្លើម។ ៣) ត្រូវគោរពប្រជាជន មិនធ្វើអ្វីឲ្យប៉ះពាល់ដល់ប្រយោជន៍ ដល់ទ្រព្យសម្បត្តិ ផលដំណាំប្រជាជនសូម្បីតែម្ទេសមួយផ្លែក៏មិនត្រូវយក។ ៤) ធ្វើអ្វីខុសត្រូវសូមទោសប្រជាជន។ ៥) និយាយស្តី ដេក ដើរ ឈរ អង្គុយ ស៊ីចុក លេងសើចត្រូវគោរពប្រជាជនជានិច្ច។ ៦) មិនត្រូវប្រព្រឹត្តអំពើល្មើសចំពោះស្ត្រី។ ៧) មិនត្រូវហូបអ្វីដែលមានលក្ខណៈពាលាអាវ៉ាសែមិនបដិវត្តន៍។ ៨) មិនត្រូវលេងល្បែងស៊ីសង។ ៩) មិនត្រូវប៉ះពាល់លុយកាក់ ទ្រព្យសម្បត្តិរបស់ប្រជាជន ឬរបស់អង្គការ មិនត្រូវបន្លំលួចទ្រព្យសម្បត្តិសមូហភាពរដ្ឋ មន្ទីរ សូម្បីតែអង្ករមួយកំប៉ុង ឬថ្នាំមួយគ្រាប់ក៏ដោយ។ ១០) ត្រូវមានចិត្តសុភាពរាបសារចំពោះប្រជាជន កម្មករ កសិករ ត្រូវតែចងកំហឹងឆាបឆេះចំពោះខ្មាំងចក្រពត្តិអាមេរិក និងបរិវារវាដោយប្រុងប្រយ័ត្នជានិច្ច។ ១១) ត្រូវធ្វើពលកម្មបង្កបង្កើនផលរួមជាមួយប្រជាជន។ ១២) ត្រូវប្រយុទ្ធដាច់ខាតនឹងខ្មាំង ប្តេជ្ញាវាយសម្រុកគ្រប់ឧបសគ្គដោយក្លាហាន ប្តេជ្ញាបូជាជីវិតសម្រាប់ប្រជាជន កម្មករ កសិករ និងអង្គការបដិវត្តន៍ដោយគ្មានរួញរា។" សូមបញ្ចប់ការដកស្រង់។

[១៣:៣៨:២១]

ឥឡូវនេះ ខ្ញុំនឹងនិយាយអំពីបញ្ហាពាក់ព័ន្ធទៅនឹងសហករណ៍។ នេះជាការបន្តពីអ្វីដែលខ្ញុំទើបតែអានអម្បាញ់មិញនេះ គឺសីលធម៌១២ប្រការ។ ខ្ញុំនឹងនិយាយពាក់ព័ន្ធទៅនឹងការបង្កើតអំណាចខ្មែរក្រហមទៅលើសហករណ៍ ហើយនិងគោលដៅនៃអំណាចនៅក្នុងក្របខ័ណ្ឌនេះនៅក្នុងអំឡុងរបបនេះទាំងមូល។ ខ្ញុំនឹងដកស្រង់ទង់បដិវត្តបីច្បាប់ មួយឆ្នាំ៧៥, មួយឆ្នាំ៧៦ និងមួយទៀតគឺឆ្នាំ៧៧។

ឯកសារទី១ គឺទស្សនាវដ្តីទង់បដិវត្តចុះខែតុលា, វិច្ឆិកា ឆ្នាំ១៩៧៥ ដែលមានលេខ E3/748។ ជាដំបូង ខ្ញុំនឹងបញ្ជាក់ ERN ជាភាសាបារាំងគឺ 00499693, ជាភាសាអង់គ្លេស 00495810, ជាខ្មែរ 00063248។ ខ្ញុំសូមដកស្រង់ នេះជាកថាខណ្ឌដែលមានចំណងជើងថា "បញ្ហាមួយចំនួនដែលទាក់ទងដល់ការកសាងសេដ្ឋកិច្ចកសិកម្ម និងឧស្សាហកម្មរបស់បក្ស"។ នៅកថាខណ្ឌទី៥ អំពីថ្នាំនិងសុខភាពរបស់ប្រជាជន "ដើម្បីប្រជាជនមានសុខភាពល្អ មានកម្លាំងពលកម្មត្រូវមានថ្នាំរក្សាជំងឺ។ សុខាភិបាលត្រូវវាយសម្រុកបីបញ្ហា គឺ១) កម្ចាត់ប្រភពគ្រុនចាញ់ឲ្យអស់ក្នុង៣ឆ្នាំ គឺឆ្នាំ១៩៧៦ រហូតដល់ឆ្នាំ១៩៧៨។ ២) កម្ចាត់គ្រុនចាញ់ដែលមានហើយដោយថ្នាំសង្កូវ។ ៣) កែរោគផ្សេងៗ មានអាសន្នរោគ អុតតូច អុតធំ ។ល។ ជាបន្តបន្ទាប់។"

ខ្ញុំសូមចូលទៅទំព័រផ្សេងទៀតនៃទស្សនាវដ្តីដដែលនេះដែលមានលេខ ERN ជាភាសាបារាំង 00499701, ជាភាសាខ្មែរ 00063258, អង់គ្លេស 00495818។ ក្រោមចំណងជើងថា "គោលជំហរ និងទស្សនៈអំពីការដោះស្រាយជីវភាពប្រជាជន" ខ្ញុំសូមដកស្រង់៖ "ថ្ងៃនេះថ្ងៃស្អែកជារៀងរហូតទៅ បក្ខជនម្នាក់ៗត្រូវមានសតិអារម្មណ៍ជាប្រចាំ ក្នុងការគិតគូរចាត់ចែងដោះស្រាយជីវភាពជូនប្រជាជន មានការដោះស្រាយខាងការស៊ីចុក ស្លៀកពាក់ ផ្ទះសម្បែង ថ្នាំសង្កូវ រហូតដល់ការរៀនសូត្រ ការរីករាយកម្សាន្តរបស់ប្រជាជនថែមទៀត ភារកិច្ចនេះ សតិអារម្មណ៍នេះជាសីលធម៌មួយដ៏ខ្ពង់ខ្ពស់របស់ជនកុម្មុយនីស្តគ្រប់រូប"។

[១៣:៤២:០៥]

នៅទំព័របន្ទាប់មកទៀត ERN ជាភាសាបារាំង 00499702, ជាភាសាអង់គ្លេស 00495819, ជាភាសាខ្មែរ 00063259។ ក្រោមចំណងជើងថា "ការដោះស្រាយជីវភាពប្រជាជនពាក់ព័ន្ធដល់មាគ៌ាគ្រប់បក្សរបស់បក្ស"។ ខ្ញុំសូមដកស្រង់ "ការដោះស្រាយជីវភាពប្រជាជនមិនមែនជាភារកិច្ចដាច់ដោយឡែកទេ វាពាក់ព័ន្ធយ៉ាងជិតស្និតដល់មាគ៌ានយោបាយគ្រប់បក្ស -- គ្រប់ផ្នែករបស់បក្ស ជាពិសេសវាជាគន្លឹះមួយដ៏សំខាន់ក្នុងការការពារប្រទេស និងកសាងប្រទេសតាមលក្ខណៈសមូហភាពវូបណីយកម្មរបស់បក្ស។ ន័យខាងនយោបាយ៖ ជាក់ស្តែងបើយើងដោះស្រាយជីវភាពជូនប្រជាជនបាន កម្លាំងប្រជាជន សុខភាពប្រជាជននឹងកើនឡើងជាលំដាប់។ ប្រជាជនរីករាយនឹងឧបត្ថម្ភរដ្ឋអំណាចបដិវត្ត ឧបត្ថម្ភបក្សបានសេចក្តីថា បើប្រជាជនមានស៊ីចុក មានស្លៀកពាក់ បានសុខដុមរមនានោះ រដ្ឋអំណាចបដិវត្តក៏កាន់តែរឹងមាំ ខ្មាំងចង់បំបែកយ៉ាងម៉េចក៏មិនបាន។ ដូច្នេះការគ្រប់គ្រងប្រជាជនព្រមគ្នាជាមួយគិតគូរខាងនយោបាយ សតិអារម្មណ៍នឹងចាត់តាំងហើយ ត្រូវគិតគូរដោះស្រាយជីវភាពរបស់គេគ្រប់បែបយ៉ាងទាំងអស់"។

ខ្ញុំសូមរំលងមួយកថាខណ្ឌ ដើម្បីចូលទៅនិយាយអំពីចំណុចមួយ ដែលមានចំណងជើងថា "ន័យខាងសេដ្ឋកិច្ច"។ "ន័យនយោបាយមិនអាចចែកដាច់ពីន័យសេដ្ឋកិច្ចទេ បើប្រជាជនបានហូប បានស្លៀកបានពាក់ នោះកម្លាំងពលកម្មនឹងកើនឡើង ការធ្វើស្រែចម្ការ និងការធ្វើការងារក្នុងរោងចក្រ ក៏នឹងបានចម្រើនឡើង ស្រូវក៏ធ្វើបាន សំពត់ក៏ត្បាញបាន"។ នេះជាការដកស្រង់ទស្សនាវដ្តីទង់បដិវត្តទី១ គឺនៅឆ្នាំ ១៩៧៥--

[១៣:៤៤:៤៤]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីលោកផ្អាកបន្តិចសិន។ មេធាវីការពារ -- នាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមអញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ មិនមែនជាការជំទាស់ទេ យើងមានអារម្មណ៍ថា យើងបានបង្ហាញឯកសារអំពីគោលនយោបាយសហករណ៍ យើងបានទទួលដំណឹងពីមន្ត្រីច្បាប់ជាន់ខ្ពស់ថា គេមិនចង់ឱ្យយើងបង្ហាញឯកសារពាក់ព័ន្ធទៅនឹងគោលនយោបាយទូទៅនៃសហករណ៍នោះទេ។ ដូច្នេះ យើងក៏បានរៀបចំរបស់យើង ការងាររបស់យើង ដោយយើងកម្រិតឯកសារ។ ខ្ញុំមិនចង់ជំទាស់ទៅលើការបង្ហាញឯកសារពាក់ព័ន្ធនឹងគោលនយោបាយរបស់មេធាវីការពារក្តីទេ ក៏ប៉ុន្តែយើងត្រូវតែយល់ថា នៅក្នុងសវនាការនេះ គឺថាយើងមិនត្រូវបង្ហាញឯកសារអំពីគោលនយោបាយទេ។ ហើយការបង្ហាញរបស់យើងនោះ ក៏ផ្សេងពីអ្វីដែលយើងបង្ហាញដែរ បើសិនជាធ្វើដូចខាងមេធាវីការពារក្តីគាត់ធ្វើនោះ។

[១៣:៤៥:៥៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤៧:១១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

អង្គជំនុំជម្រះចង់ឱ្យមេធាវីការពារក្តីផ្តោតទៅលើបញ្ហាពាក់ព័ន្ធដោយផ្ទាល់ទៅនឹងស្រុកត្រាំកក់ចំពោះគោលនយោបាយ ជាពិសេសគោលនយោបាយនៅទូទាំងប្រទេសនោះ យើងនឹងមានឱកាសផ្សេងទៀតនៅពេលខាងមុខក្នុងការលើកឡើង ជាពិសេសគឺនៅពេលដែលផ្នែកផ្សេងទៀតនៃសវនាការយើង។ ដូច្នេះ អង្គជំនុំជម្រះមិនចង់ឱ្យខាងមេធាវីការពារក្តីបង្ហាញឯកសារបែបនេះទេ។

**លោក អាកទូរ វែកកែន៖**

ខ្ញុំសូមជំទាស់ការសម្រេចរបស់អង្គជំនុំជម្រះ ខ្ញុំគ្រាន់តែការពារកូនក្តីរបស់ខ្ញុំ គឺលោក ខៀវ សំផន។ គាត់មិនមែនជាប់ឃុំនៅគុកក្រាំងតាចាន់ទេ គាត់មិននៅស្រុកត្រាំកក់ទេ គាត់មិននៅតាកែវទេ។ ដូច្នេះការលើកឡើងអំពីសហករណ៍ ដោយមិននិយាយអំពីគោលនយោបាយទូទៅក្នុងគោលដៅដើម្បី

ការពារកូនក្តីនោះ ខ្ញុំមើលឃើញថា ខ្ញុំពិបាកនឹងធ្វើអ្វីផ្សេងពីនេះណាស់។ ខ្ញុំមិនដឹងថា បង្ហាញឯកសារយ៉ាងម៉េច។ វាពាក់ព័ន្ធទៅនឹងទស្សនទាននៃអំណាចរបស់ខ្មែរក្រហម គឺយើងបង្ហាញឲ្យឃើញថា គេគោរពប្រជាជន គេដោះស្រាយជីវភាពប្រជាជន និងបន្ទាប់មកទៀត ខ្ញុំនឹងបង្ហាញអំពីបញ្ហាពាក់ព័ន្ធទៅនឹងប្រវត្តិនៃការបង្កើតសហករណ៍ទាំងអស់នេះ និងបញ្ហាដែលពាក់ព័ន្ធ។

[១៣:៤៨:៥៥]

អស់លោក លោកស្រីចៅក្រម បានស្តាប់អម្បាញ់មិញហើយនូវការលើកឡើងរបស់ខ្ញុំអម្បាញ់មិញនេះ ខ្ញុំលើកឡើងអំពីចំណុចដែលពាក់ព័ន្ធទៅនឹងបញ្ហាការកំណត់ចំនួនអ្នកស្លាប់នៅក្នុងតំបន់នេះ។ ក៏ប៉ុន្តែខ្ញុំគិតថា ខ្ញុំធ្វើតាមប្រធានបទហើយ ខ្ញុំមានបេសកកម្មរបស់ខ្ញុំ គឺការពារក្តីកូនក្តីរបស់ខ្ញុំ គឺលោក ខៀវ សំផន។ ខ្ញុំមិនអាចអ្វីផ្សេងទេ ប្រសិនបើអង្គជំនុំជម្រះហាមឃាត់ខ្ញុំនៅក្នុងសវនាការនេះ មិនឲ្យបង្ហាញនោះ យើងដឹងហើយថាកាលពីវគ្គ -- សំណុំរឿងវគ្គទី១នោះ យើងពិបាកក្នុងការទទួលយកសវនាការណាស់។ កាលនុ៎ងគឺ ដំបូងគឺថាសម្រាប់តែជម្រាបជូនដល់សាធារណជន និងអ្នកសារព័ត៌មានហើយថ្ងៃនេះ យើងសម្រេចចិត្តចូលរួមក្នុងសវនាការនេះ ក៏ព្រោះតែអង្គជំនុំជម្រះសម្រេចផ្ទុយពីហ្នឹងគឺថាអាចឲ្យមានការឆ្លើយតប អាចឲ្យមានការជំទាស់ទៅលើឯកសារ។ អ៊ីចឹងហើយ បានជាយើងចូលរួមនៅក្នុងការបង្ហាញនេះ គឺយើងខ្ញុំព្យាយាមធ្វើតាមសហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី គឺធ្វើយ៉ាងម៉េច មិនឲ្យជជែកតវ៉ាក្តីទេ។ ក៏ប៉ុន្តែបើសិនជាអង្គជំនុំជម្រះហាមមិនឲ្យខ្ញុំដកស្រង់ទស្សនាវដ្តីទង់បដិវត្ត ពាក់ព័ន្ធទៅនឹងសហករណ៍ ហើយនិងការបង្កើតសហករណ៍ ដែលធ្វើឡើងដោយរដ្ឋអំណាចខ្មែរក្រហមនោះ។ ខ្ញុំគិតថា ខ្ញុំគឺមានតែអង្គុយចុះ ហើយឱបដៃមើលទេ ខ្ញុំមិនបង្ហាញអីទៀតទេ បើសិនជាហាមឃាត់ អ៊ីចឹងបែបនេះនោះ។

[១៣:៥០:៣០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី វែកគែន យើងមិនចង់ជំទាស់សិទ្ធិរបស់លោកក្នុងការការពារក្តីលោក ខៀវ សំផនទេ។ អង្គជំនុំជម្រះគ្រាន់តែចង់ទាញចំណាប់អារម្មណ៍លោកថា សវនាការនេះមានផ្នែកច្រើន មានវគ្គច្រើន ហើយវគ្គមួយនោះគឺពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទ និងគោលនយោបាយដែលអនុវត្តនៅ

ក្នុងក្របខ័ណ្ឌដែលត្រូវបានចោទប្រកាន់ថាជាសហឧក្រិដ្ឋកម្មរួម។ ហើយក្នុងនេះពេលនេះ គឺយើងនិយាយអំពីសហករណ៍ អ្វីដែលអង្គជំនុំជម្រះចង់ប្រាប់លោកនោះគឺថា ថ្ងៃនេះគឺមិនមែនជាពេលសមស្របក្នុងការបង្ហាញឯកសារដែលយោងទៅលើវគ្គបន្តបន្ទាប់ទៀតនៃសវនាការនេះទេ។

**លោក អាកឡូវ វែកកែន៖**

ក៏ប៉ុន្តែខ្ញុំគិតថា សហករណ៍វាមិនមែនជាផ្នែកផ្សេងនៃសវនាការនេះទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ស្តាប់ខ្ញុំ ថ្ងៃនេះយើងនិយាយអំពីត្រាំកក់ និងក្រាំងតាចាន់។ យើងមិននិយាយអំពីសហករណ៍នៅទូទាំងប្រទេសទេលោកមេធាវី។

[១៣:៥១:៤២]

**លោក អាកឡូវ វែកកែន៖**

បាទ បើអ៊ីចឹងខ្ញុំសូមជម្រាបលាហើយ អង្គុយចុះហើយ ខ្ញុំមិនអាចបង្ហាញអីបានទេ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីជាតិមានអីត្រូវបង្ហាញទេ?

**លោក គង់ សំអុន៖**

ខ្ញុំអត់មានអីត្រូវបង្ហាញទេ ប៉ុន្តែខ្ញុំសូមជូនយោបល់ទាក់ទងទៅនឹងការជជែកអម្បាញ់មិញនេះ។ ខ្ញុំយល់ឃើញថា ថ្វីត្បិតតែពេលនេះយើងជជែកអំពីក្រាំងតាចាន់ និងសហករណ៍ត្រាំកក់ក៏ដោយ ក៏ប៉ុន្តែនៅក្នុងក្រាំងតាចាន់ក្តី នៅក្នុងត្រាំកក់ក្តី វាមានភាពពាក់ព័ន្ធគ្នាជាលក្ខណៈទូទៅទូទាំងប្រទេស។ បាទ ដូច្នេះបើសិនជាយើងនិយាយអំពីសហករណ៍ត្រាំកក់ ក៏យើងអាចមានភាពពាក់ព័ន្ធទៅនឹងសហករណ៍ដែលជាលក្ខណៈគោលការណ៍ ដែលបានបង្កើតឡើងទូទាំងប្រទេសផងដែរ។ ដូច្នេះយើងមិនអាចចែកឲ្យដាច់ថា គោលការណ៍ណាដែលអនុវត្តដោយឡែកចំពោះតែត្រាំកក់ ហើយគោលការណ៍ណាដែលត្រូវអនុវត្តដោយឡែកនៅទូទាំងប្រទេសនោះទេ។ ហើយតំណាងសហព្រះរាជអាជ្ញាក្តីក៏មិនបានបង្ហាញពីភាពខុសគ្នារវាងការអនុវត្តនៅសហករណ៍ត្រាំកក់ និងសហករណ៍ដទៃទៀតនៅទូទាំងប្រទេសដែរ។ បាទ ដូច្នេះខ្ញុំយល់ឃើញថា ការចែកពីភាពពាក់ព័ន្ធនេះគ្នា ប្រហែលជាមិនទំនងជាអាចធ្វើឲ្យក្រុមយើងអនុវត្តបានបែងចែកបាននោះទេ លុះណាតែតំណាងសហព្រះរាជអាជ្ញាធ្វើការបែងចែកចំណុចនេះឲ្យដាច់ពីគ្នា រវាងការអនុវត្តនៅសហករណ៍ត្រាំកក់ និងការអនុវត្តនៅសហករណ៍ទូទាំងប្រទេស។

បាទ សូមអរគុណ។

[១៣:៥៣:៤០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥៤:៣៧]

**លោក អាកទួរ វែកកែន៖**

លោកប្រធាន លោក ខៀវ សំផន គាត់ចង់មានសូមមានមតិបន្តិចលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

កុំអាល! អង្គជំនុំជម្រះកំពុងពិចារណា។

សូមអញ្ជើញលោក ខៀវ សំផន!

**លោក ខៀវ សំផន៖**

បាទ សូមជម្រាបអរគុណលោកប្រធានអង្គជំនុំជម្រះ។ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមិនដឹងរឿងអីជាក់ស្តែងកើតឡើងនៅត្រាំកក់ ឬនៅក្រាំងតាចាន់អីឯណានោះទេ។ ខ្ញុំមកគាំទ្រនយោបាយបក្សកុម្មុយនីស្តកម្ពុជាតាមខ្លឹមសារឯកសារដែលមេធាវីខ្ញុំសូមលើកនេះ។ ខ្ញុំសូមជម្រាបតែប៉ុណ្ណឹងទេ។ ខ្ញុំដែលមកចូលរួមក្នុងកម្ពុជាប្រជាធិបតេយ្យ ខ្ញុំតាមឯកសារហ្នឹង តាមនយោបាយហ្នឹង។ ហើយមកចោទខ្ញុំថា ខ្ញុំបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម បើខ្ញុំអត់ដឹងរឿងស្អីណានោះ ខ្ញុំដឹងតែរឿងប៉ុណ្ណឹង ហើយមកចោទខ្ញុំអ៊ីចឹងដែរ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១៣:៥៦:០៩]

**លោក ឌេល លីសាក់៖**

ខ្ញុំមានចំណុចមួយចំនួន ដំបូងគឺអ្វីដែលបានស្នើសុំដោយមេធាវីការពារក្តី ដែលថាយើងបានបង្ហាញនូវគោលនយោបាយទូទៅ ពាក់ព័ន្ធនឹងសហករណ៍។ ខ្ញុំចង់ដឹងថា តើគាត់កំពុងតែយោងទៅឯកសារមួយណា? គឺឯកសារដែលពាក់ព័ន្ធទៅនឹងស្រុកត្រាំកក់ ដូចដែលអង្គជំនុំជម្រះបានជ្រាបរួចហើយ គឺថាដើមបណ្តឹងរដ្ឋប្បវេណីក៏មាននិយាយដូចអ្វីដែលមេធាវីការពារក្តីកំពុងតែលើកឡើងនេះដែរ។ ចំណុចទី២ ពាក់ព័ន្ធទៅនឹងការអះអាងរបស់លោក ខៀវ សំផន ខ្ញុំចង់ដឹងថា តើគាត់លះបង់សិទ្ធិដើម្បី

រក្សាភាពនៅស្ងៀមស្ងាត់ ឬក៏យ៉ាងម៉េច? ឬក៏ថាគាត់បានដឹងអ្វីខ្លះដែរ អំពីស្រុកត្រាំកក់ ឬក៏ដឹងអំពីគោលនយោបាយនេះ ពាក់ព័ន្ធទៅនឹងស្រុកត្រាំកក់?

និងទី៣ ខ្ញុំសូមរំឭកដល់មេធាវីការពារក្តីថា មេធាវីការពារក្តីបានជំទាស់ម្តងហើយម្តងទៀតចំពោះសហព្រះរាជអាជ្ញា ជាពិសេសពាក់ព័ន្ធទៅនឹងប្រធានបទទៅនៅស្រុកត្រាំកក់ និងជាពិសេសគឺនៅអង្គរកា និងចំពោះខ្មែរក្រោម។ គឺថាឥឡូវនេះ គាត់ថាគាត់មិនដែលចង់និយាយចំណុចនេះ ប៉ុន្តែឥឡូវនេះគាត់ចង់និយាយពីសហករណ៍នេះ នៅទូទាំងប្រទេសតែម្តង។

[១៣:៥៧:៣១]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ប្រហែលជាវាអាច -- ទី១ គឺថាយើងខ្ញុំចង់ឲ្យបញ្ជាក់សម្រាប់សាធារណជន ហើយជាពិសេសសម្រាប់មេធាវីការពារក្តី និងលោក ខៀវ សំផន។ តើលោកត្រូវបង្ហាញនូវឯកសារណាមួយ ហើយឯកសារត្រូវធ្វើនៅពេលណា? ប្រសិនបើយ៉ាងដូច្នេះមែន គឺវាពាក់ព័ន្ធនឹងអង្គការ។ ទី១ គឺថាយើងត្រូវស្តាប់ឯកសារទាំងអស់នេះនៅពេលណា។ ហើយបើវាដល់ពេលនោះ ថាតើមេធាវីការពារក្តីមានបានអានអ៊ីម៉ែលមួយ ដែលយើងបានផ្ញើទៅសហមេធាវីនាំមុខដែរឬក៏អត់? ដែលក្នុងអ៊ីម៉ែលនោះ គឺថាអង្គជំនុំជម្រះពេញចិត្តនៅក្នុងពេលនេះ បើមេធាវីការពារក្តីផ្តោតតែទៅលើឯកសារទាក់ទងទៅនឹងគុកក្រាំងតាចាន់ ក៏ដូចជាពាក់ព័ន្ធទៅនឹងគោលនយោបាយ។ ពេលនោះ គឺថាមេធាវីការពារក្តី គឺថាមានឱកាសត្រូវធ្វើបែបនេះ។ សំណួររបស់ខ្ញុំ គឺថាបើតាមយើងយល់មិនច្រឡំ គឺយើងត្រូវតែបញ្ជាក់ឲ្យបានច្បាស់ ចំពោះការយល់ច្រឡំទៅវិញទៅមកបែបនេះ។

[១៣:៥៩:១៤]

**លោក អាកទួរ វែកគែន៖**

ចំណុចទី១ គឺថាកាលពីសវនាការរៀបចំ -- កាលពីការកិច្ចប្រជុំរៀបចំសវនាការនុ៎ង យើងក៏បាននិយាយអំពីចំណុចហ្នឹងម្តងហើយ ហើយយើងក៏បាន -- នៅទីនេះក៏យើងបាននិយាយជាច្រើនដងហើយ។ គេបានបំបែកការជំនុំជម្រះក្តីនេះ ជាវគ្គតូចៗផ្សេងៗគ្នា ពីព្រោះថាមានហានិភ័យដែលថាជនជាប់ចោទមិនអាចនៅរហូតដល់ចប់សវនាការបាន។ នេះជាចំណុចទី១។

ចំណុចទី២ ដើម្បីឆ្លើយទៅនឹងសហព្រះរាជអាជ្ញា ខ្ញុំសូមបញ្ជាក់ថា អង្គរកា និងខ្មែរក្រោម មិននៅក្នុងដីកាដំណោះស្រាយទេ។ អ៊ីចឹងខ្ញុំមិនមើលឃើញថាតើនៅក្នុង -- តើអ្នកណាជាអ្នកចេញពីវិសាលភាពនៃសវនាការទេ? ខ្ញុំឃើញថា ដូចជាសហព្រះរាជអាជ្ញាទេ ជាអ្នកអនុវត្តដែលធ្វើបែបនេះនោះ។ ហើយអ្វីដែលលោកស្រីចៅក្រម ហ្វេនស៍ ទើបតែនិយាយនេះគឺថា លោកស្រីបានរំឭកអំពីការលំបាកនៅពេលដែលនិយាយអំពីការលំបាកនៃសវនាការលើឯកសារគន្លឹះ។

កាលពីព្រឹកមិញនេះ នៅពេលដែលឆ្លើយតបទៅនឹងការជំទាស់ ខ្ញុំសូមអភ័យទោសអំមិញនេះខ្ញុំនិយាយលឿនពេក។ កាលពីព្រឹកមិញនេះ អង្គជំនុំជម្រះបានរំឭកអំពីការលំបាកនៃសវនាការនេះ ហើយខ្ញុំសូមបញ្ជាក់ថា សវនាការនេះ គឺថាមិនអាចទទួលយកបានទេនៅក្នុងវគ្គសំណុំរឿង ០០២/០១ នោះ។ ថ្ងៃនេះក៏អ៊ីចឹងដែរ។ ឯកសារដែលខ្ញុំដកស្រង់នោះ គឺជាឯកសារចេញពីទស្សនាវដ្ដីទង់បដិវត្ត ខ្ញុំមិនមែនយកឯកសារថ្មី យកមកដកស្រង់ទេ។ ខ្ញុំលើកអំពីបញ្ហាពាក់ព័ន្ធទៅនឹងការការពារកូនក្ដីរបស់ខ្ញុំគឺលោក ខៀវ សំផន។ បញ្ហាដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់គាត់។ អ៊ីចឹងហើយ ឥឡូវនេះ គេមិនចង់ឲ្យខ្ញុំលើកអំពីចំណុចទាំងអស់ហ្នឹង ខ្ញុំមិនលើកទេ។ អ៊ីចឹងការលើកឡើងរបស់ខ្ញុំហ្នឹងគឺថា វាជាចំណុចរួមមួយវាពាក់ព័ន្ធគ្នា ហើយបើមិនឲ្យខ្ញុំនិយាយ ខ្ញុំមានតែខ្ញុំឈប់ទេ។ អ៊ីចឹងនៅថ្ងៃក្រោយទៀតនោះ ខ្ញុំក៏នៅតែបន្តលើកពីចំណុចហ្នឹងដដែលនៅចំពោះមុខអង្គជំនុំជម្រះ បើមិនឲ្យខ្ញុំលើកនៅថ្ងៃនេះនោះ។

[១៤:០២:១០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០៦:០២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះចង់បញ្ជាក់ដូចតទៅ៖ យើង -- អ្វីដែលយើងធ្វើ គឺដើម្បីធានានូវសមភាពរវាងភាគីទាំងអស់ ជាពិសេសពាក់ព័ន្ធទៅនឹងការត្រៀមរៀបចំសម្រាប់សវនាការស្ដីពីការបង្ហាញឯកសារគន្លឹះ។ ក្នុងក្របខ័ណ្ឌនៃការរៀបចំខ្លួន មានសំណើមួយពីសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសុំឲ្យមានការបំភ្លឺថា តើឯកសារណាខ្លះដែលអាចត្រូវយកមកបង្ហាញបាន? ពេលនោះអង្គជំនុំជម្រះបានឆ្លើយតបទៅនឹងលោកស្រីមេធាវី ហ្គីរ៉ូដ៍ ហើយចម្លើយនេះ ត្រូវបាន

ផ្តល់ -- ត្រូវបានផ្ញើជូនទៅឲ្យភាគីទាំងអស់ រួមទាំងមេធាវី ហ្គិសសេ មេធាវី វែកគែន ហើយនិងជំនួយការដែលធ្វើការនៅក្នុងក្រុមមេធាវីការពារក្តី។

ដូច្នេះថ្ងៃនេះ អ្វីដែលធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលនោះ គឺមេធាវីការពារក្តីគាត់ភ្ញាក់ផ្អើលអំពីឥរិយាបថរបស់អង្គជំនុំជម្រះ ពីព្រោះថាការបង្ហាញឯកសារហ្នឹង គឺថាយើងដឹងមុនបាត់ទៅហើយ មុនពេលសវនាការនេះទៅទៀតថា ខ្លួនត្រូវបង្ហាញអ្វីខ្លះនោះ។ លើកលែងតែមេធាវីការពារក្តីចង់បង្ហាញឯកសារដែលពាក់ព័ន្ធជាក់លាក់តែម្តងទៅនឹងស្រុកត្រាំកក់ និង/ឬ ក្រាំងតាចាន់ បើមិនអ៊ីចឹងទេ យើងនឹងបញ្ចប់សវនាការស្តីពីការបង្ហាញឯកសារដោយក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

[១៤:០៧:៥៤]

**លោក អាកឡូរ វែកកែន៖**

ខ្ញុំសូមបញ្ជាក់ថា តាមយើងយល់ ឯកសារដែលខ្ញុំទើបតែចង់បង្ហាញនុ៎ង ហើយពេលនោះសហមេធាវីការពារ -- មេធាវីដើមបណ្តឹងគាត់ជំទាស់។ ឯកសារហ្នឹង គឺជាឯកសារគន្លឹះសម្រាប់ការពារលោក ខៀវ សំផន។ ដូច្នេះពួកយើង គឺថាសុទ្ធតែជាឯកសារគន្លឹះទាំងអស់។ នេះជាការយល់ពាក់ព័ន្ធទៅនឹងការវាយតម្លៃទៅលើការទទួលខុសត្រូវព្រហ្មទណ្ឌនៃកូនក្តីរបស់យើង នៅក្នុងប្រធានបទដែលពាក់ព័ន្ធនឹងយើងនៅថ្ងៃនេះ ក្នុងក្របខ័ណ្ឌនៃសវនាការស្តីអំពីឯកសារគន្លឹះ។ អ៊ីចឹងប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា មិនអ៊ីចឹង មិនដូចអ្វីដែលយើងគិតទេ យើងគឺថាមិនមានអ្វីដែលត្រូវចូលរួមបន្តទៀតទេ ពីព្រោះថាមានការហាមឃាត់យើងបែបនេះទៅហើយនោះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោក វែកកែន លោកបំប្លែងសម្តីរបស់អង្គជំនុំជម្រះហើយ យើងមិនបាននិយាយថា មិនមែនជាឯកសារគន្លឹះសម្រាប់ការពារក្តីលោក ខៀវ សំផន ទេ គឺនិយាយអំពីបញ្ហាពេលវេលា និងការរៀបចំ។ ខ្ញុំចង់ដឹងថា តើលោកទទួលបានសាររបស់អង្គជំនុំជម្រះចំពោះការឆ្លើយតបទៅនឹងការស្នើរបស់មេធាវី ហ្គីរ៉ូដ៍ ឬក៏អត់? ហើយប្រសិនបើនោះ លោកមានបានអានទេ? បើលោកអាន លោកអត់មានបានធ្វើប្រតិកម្មតបអីទេ ពេលនុ៎ង។ អ៊ីចឹងលោកធ្វើអ៊ីចឹង គឺវាមិនសមរម្យទេ។

[១៤:០៩:៣៣]

**លោក អាកឡូរ វែកកែន៖**

ខ្ញុំសូមអានអត្ថបទឡើងវិញនៃចម្លើយរបស់អង្គជំនុំជម្រះ ជាភាសាអង់គ្លេស សូមអភ័យទោស

ចំពោះសួរសៀងជាភាសាអង់គ្លេសរបស់ខ្ញុំ។ "ភាគីគួរតែគិតពិចារណាអំពីពេលវេលាដែលត្រូវបែងចែកក្នុងការធ្វើបទបង្ហាញទៅលើឯកសារគន្លឹះ។ នៅក្នុងដំណាក់កាលនេះ អង្គជំនុំជម្រះសាលាដំបូងអាចទទួលបានការជួយយ៉ាងប្រសើរប្រសិនបើមានការបទបង្ហាញអំពីឯកសារនៅត្រាំកក់ ក៏ដូចជាឯកសារទាក់ទងទៅនឹងហេតុការណ៍ដែលកើតឡើងនៅទីកន្លែងផ្សេងដែលអាចថា មិនពាក់ព័ន្ធដោយផ្ទាល់ ឬក៏អាចមិនកើតឡើងនៅក្នុងពេលវេលាជាក់ស្តែង"។

ដូច្នេះ គឺខ្ញុំបានអានអ៊ីម៉ែលហ្នឹងច្បាស់ហើយលោកចៅក្រម ហើយខ្ញុំយល់ឃើញថាដូចជាក្នុងចម្លើយហ្នឹងគឺមិនអាចមិនហាមឃាត់ខ្ញុំមិនឱ្យលើកឡើងដូចអ្វីដែលខ្ញុំចង់ទេ។ អ៊ីចឹងយើងចង់បង្ហាញថាតើទស្សនៈនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ហ្នឹងយ៉ាងម៉េច? គាត់ពិតជាបានចូលរួមនៅក្នុងរបបមួយដែលពាក់ព័ន្ធទៅនឹងការបង្កើតសហករណ៍ ដូចនៅក្នុងតំបន់ដូចដែលជាប្រធានបទរបស់យើងនុ៎ងក៏អត់?

[១៤:១១:០៧]

អ៊ីចឹង អង្គជំនុំជម្រះគិតថា អ៊ីម៉ែលហ្នឹងច្បាស់ហើយ គឺថាបើសិនជាការហាមឃាត់ដល់មេធាវីការពារក្តីក្នុងការប្រើប្រាស់ឯកសារស្តីអំពីគោលនយោបាយដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងលោក ខៀវ សំផន នោះ យើងៗយល់ឃើញថា វាជាការសំខាន់ក្នុងការការពារក្តីៗកូនក្តីរបស់យើងដែលពាក់ព័ន្ធទៅនឹងសហករណ៍ ហើយនិងកន្លែងសម្លាប់មនុស្សនោះ។ អ៊ីចឹង ខ្ញុំមិនយល់ស្របតាមការឯកភាព -- តាមការវិភាគរបស់អង្គជំនុំជម្រះចេញពីអ៊ីម៉ែលហ្នឹងទេ។ ខ្ញុំគិតថា វាជារឿងមិនប្រក្រតីទេ ដែលហាមមិន -- ដូច្នេះមិនគួរណាហាមមេធាវីការពារក្តីមិនឱ្យបង្ហាញឯកសារហ្នឹងទេ។

**ចៅក្រម គ្លូឌា ហ្វេនស៍៖**

គឺថា មិនដឹងថាតើក្រុមមេធាវីការពារក្តី ខៀវ សំផន បានយល់អំពីអ៊ីម៉ែលនេះទេ -- បានយល់អំពីអ៊ីម៉ែល ឬក៏អត់ទេ? ភាសានេះគឺជាភាសាមួយដែលមានការគួរសមមែនទែន។ ហើយ -- ទោះជាយ៉ាងណាក៏ដោយភាគីដទៃទៀត គឺថាបានយល់អំពីអ៊ីម៉ែលនេះយ៉ាងច្បាស់ លើកលែងតែមេធាវីការពារក្តីក្រុម ខៀវ សំផន។ ដើម្បីជៀសវាងកុំឱ្យមានការយល់ច្រឡំ ប្រសិនជាលោកត្រូវបានអនុញ្ញាតឱ្យបង្ហាញឯកសារជាក់លាក់ណាមួយនោះ ជាពិសេសគឺពាក់ព័ន្ធទៅនឹងពេលវេលាថា តើពេលវេលាដែលត្រូវដាក់បង្ហាញនៅពេលណា? ថាតើវាជាការធ្វេសប្រហែសរបស់លោកនៅក្នុងការការពារកូនក្តី ឬក៏អង្គជំនុំជម្រះ? គឺថាភាគីទាំងអស់មានសិទ្ធិស្មើៗគ្នាទេ។ ហើយសំណួរចុងក្រោយដែលខ្ញុំត្រូវសួរ គឺថា

ក្នុងការសួរបញ្ជាក់អំពីថាតើការយល់បានច្បាស់ -- មានការយល់បានច្បាស់ទេចំពោះអ៊ីម៉ែលនេះ? តើលោកមានឯកសារពាក់ព័ន្ធទៅនឹងក្រាំងតាចាន់ដែរឬទេ ដើម្បីធ្វើការបង្ហាញនៅក្នុងថ្ងៃនេះ?

*(សម្រាករយៈពេលខ្លី)*

[១៤:១៤:៥៣]

តើមេធាវីការពារក្តីត្រូវការពេលសម្រាកសិន ដើម្បីពិនិត្យមើលឯកសារទាំងអស់នេះ ឬយ៉ាងម៉េច? ត្រូវការរយៈពេលប៉ុន្មានដែរ?

**លោក អាកទូរ វែកគែន៖**

បាទ ខ្ញុំត្រូវការរយៈពេល៥នាទី ដើម្បីពិភាក្សាជាមួយកូនក្តីខ្ញុំលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងពីរសាមសិបនាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ដោយពេលសម្រាកនេះទុកលទ្ធភាពជូនមេធាវីការពារក្តី ខៀវ សំផន ដើម្បីពិគ្រោះពិភាក្សាជាមួយនឹងកូនក្តីរបស់លោកឲ្យបានហ្មត់ចត់លើបញ្ហានេះផង។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:១៦ នាទី ដល់ម៉ោង ១៤:៣០ នាទី)*

[១៤:៣០:៥២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសដាក់បង្ហាញឯកសារគន្លឹះពាក់ព័ន្ធជាមួយនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់។

**លោក អាកទូរ វែកគែន៖**

បាទ សូមអរគុណលោកប្រធាន។ ដើម្បីឆ្លើយតបទៅនឹងសំណួរចុងក្រោយអម្បាញ់មិញនេះ មុនពេលសម្រាកនេះ។ បាទ លោក ខៀវ សំផន ហើយនិងមេធាវីរបស់គាត់យល់ឃើញថា ទស្សនាវដ្តីទង់បដិវត្តទាំងបីដែលខ្ញុំត្រៀមនឹងមកបង្ហាញដោយសង្ខេបមុនហ្នឹងអម្បាញ់មិញនេះ ហើយនិងឯកសារមួយ

ចំនួនដែលខ្ញុំត្រៀមនឹងបង្ហាញដែរនោះ។ ពីព្រោះថា វាជាកម្មវត្ថុនៃសវនាការនេះ សម្រាប់ភាគីផ្សេងទៀត ក៏ដូចជាសាធារណជន ហើយនិងអ្នកកាសែតផងដែរ។ វាទាក់ទងទៅនឹងគោលជំហររបស់គាត់ គឺថាទាក់ទងទៅនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់។ លោក ខៀវ សំផន គិតថា បើសិនជាអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យមេធាវីរបស់គាត់ដកស្រង់ឯកសារ ដែលស្ថិតនៅ ដែលជាបន្ទាត់ការពាររបស់គាត់ទេ គាត់សន្និដ្ឋានថា មិនចាំបាច់បន្តទៀតទេ មិនចាំបាច់បង្ហាញឯកសារបន្តទៀតទេ។ នេះគឺជាគោលជំហររបស់គាត់ ទាល់តែអនុញ្ញាតឲ្យមេធាវីគាត់បង្ហាញឯកសារប៉ុន្មានហ្នឹង បានគាត់ -- យើងបន្តទៀត។ នេះជាគោលជំហររបស់គាត់ លោកប្រធាន។

[១៤:៣២:៤៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន យើងបំភ្លឺគោលជំហររបស់យើង។ សហភាគាតរបស់ខ្ញុំយល់គោលជំហរខ្ញុំអម្បាញ់មិញនោះ ខ្ញុំមិនបានជំទាស់ទេ ខ្ញុំគ្រាន់តែចង់ឲ្យកត់ចូលប្រតិចារឹកតែប៉ុណ្ណឹងទេ។ ជាទូទៅហ្នឹងគឺថាយើងធ្វើយ៉ាងណា ដើម្បីឲ្យយើងអាចប្រើប្រាស់ប្រតិចារឹកនៅពេលក្រោយបាន។ ខ្ញុំមិនមែនជំទាស់ទេ មុនអម្បាញ់មិញនេះ ខ្ញុំគ្រាន់តែចង់ទាញចំណាប់អារម្មណ៍អង្គជំនុំជម្រះឲ្យយល់ឃើញថា យើងយល់ឃើញថាអ៊ីម៉ែលនោះរារាំងមិនឲ្យយើងបង្ហាញឯកសារមួយចំនួនបាន។ ដូច្នេះ ខ្ញុំក្រោកឡើងអម្បាញ់មិញនេះ គឺគ្រាន់តែជម្រាបជូនអង្គជំនុំជម្រះយ៉ាងដូច្នេះទេ ពីព្រោះថាយើងមានឯកសារមួយដែលយើងបង្ខំចិត្តមិនបង្ហាញ។

[១៤:៣៣:៤៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៥:១៧]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវី ឥឡូវនិយាយពីទូទៅមកភាពជាក់លាក់។ តើលោកចង់និយាយថាឯកសារទាំងអស់នេះ គឺពាក់ព័ន្ធទៅនឹងក្រាំងតាចាន់ ហើយឬក៏ពាក់ព័ន្ធទៅនឹងវិសាលភាពដែលយើងមានចែងនៅក្នុងអ៊ីម៉ែលឬក៏អត់? ប្រសិនបើលោកឆ្លើយថា "បាទ" អាហ្នឹង គឺលោកអាចធ្វើការបង្ហាញឯកសារហ្នឹងតែ

ម្តងទៅ មិនមែនខ្ញុំនិយាយខុសដែលថាសួរ មិនមែនទេ គឺថាលោកធ្វើតែម្តងទៅ។ ដូច្នេះ ដំបូងបំផុត គឺលោកជាអ្នកវាយតម្លៃខ្លួនឯងថាតើវាពាក់ព័ន្ធអត់?

**លោក អាកទួរ វែកគែន៖**

បាទ គឺជាឯកសារទាក់ទងនឹងឯកសារគន្លឹះនៅសហករណ៍ត្រាំកក់ ហើយនិងមន្ទីរសន្តិសុខក្រាំងតាចាន់។ បាទ ខ្ញុំយល់យើងជាក្រុមការងាររបស់លោក ខៀវ សំផន យើងមកទីនេះ ដើម្បីការពារលោក ខៀវ សំផន យើងមិនមែនមកទីនេះ ដើម្បីធ្វើអ្វីផ្សេងទៀតទេ។ ហើយគឺយើងមកត្រឹមតែការពារលោក ខៀវ សំផន តែប៉ុណ្ណោះ។ ហើយអស់លោក លោកស្រីចៅក្រមឱ្យយើងបង្ហាញឯកសារគន្លឹះ មិនមែនឯកសារគន្លឹះសម្រាប់ប្រវត្តិសាស្ត្រអ្វីនោះទេ គឺឯកសារគន្លឹះសម្រាប់ការពារលោក ខៀវ សំផន នៅក្នុងក្របខ័ណ្ឌសហករណ៍ ហើយនិងក្រាំងតាចាន់។ ហើយការដែលលោក ខៀវ សំផន យល់ទាក់ទងនឹងសហករណ៍ ហើយនិងមន្ទីរសន្តិសុខមួយនៅក្នុងប្រទេសកម្ពុជាចន្លោះឆ្នាំ៧៥-៧៩។ អ៊ីចឹងយើង ជ្រើសរើសឯកសារគន្លឹះមួយចំនួនដែលយើងយល់ឃើញថា វាអាចចេញពីមុខតំណែង ពីកន្លែងដែល ឬក៏កម្រិតដែលលោក ខៀវ សំផន ធ្វើការសម័យនោះ គឺវាចេញពីហ្នឹងរហូតទៅដល់ព័ត៌មានលម្អិត។ អ៊ីចឹងមានបញ្ហាមួយចំនួនទៀត ដែលវាមានចោទឡើងក្នុងការជម្រះសេចក្តីនេះ ដែលថាអ្នកដែលត្រូវបានគេកាត់ក្តីជម្រះសេចក្តីនេះ សុទ្ធតែជាអ្នកដែលមិនបានដឹងពីរឿងនៅតាមមូលដ្ឋានទេ គឺថាមានអំពើឧក្រិដ្ឋដែលកើតនៅក្នុងស្រុក ឬក៏នៅក្រាំងតាចាន់ ហើយម្ខាងទៀតនោះ លោក ខៀវ សំផន នោះ កាលសម័យនោះជាទូទៅគាត់នៅភ្នំពេញឯណោះទេ។ អ៊ីចឹងហើយតើអង្គជំនុំជម្រះចង់បានអ្វី? ចង់ឱ្យយើងចូលសវនាការនិយាយអំពីឯកសារគន្លឹះ ពីមុនមកយើងជំទាស់ហើយ ព្រោះវាអត់មានលក្ខណៈជាក់លាក់។ ឥឡូវនេះ យើងយល់ព្រមធ្វើហើយៗស្រាប់តែបែរជាមកប្រាប់យើងវិញផ្ទុយពីហ្នឹង ប្រាប់ថាឯកសារដែលយើងចង់បង្ហាញនេះ មិនទាក់ទងនឹងកម្មវត្ថុនៃសវនាការនេះទេ។

[១៤:៣៨:០៥]

អ៊ីចឹងយើងគ្រាន់តែកត់សម្គាល់ការយល់ឃើញរបស់អង្គជំនុំជម្រះតែប៉ុណ្ណឹងទេ។ ក៏ប៉ុន្តែខ្ញុំគិតថាអ៊ីម៉ែលដែលផ្ញើមកយើងតែជាភាសាអង់គ្លេសនេះ មិនជួយសម្រួលដល់ការងារនៃក្រុមរបស់យើងទេ ព្រោះយើងសុទ្ធតែជាអ្នកនិយាយភាសាបារាំងទាំងអស់។ ហើយអ៊ីម៉ែលនេះ ខ្ញុំយល់ឃើញថា វាច្បាស់លាស់ហើយ ព្រោះថាទុកឱ្យយើងទាំងអស់គ្នានោះយល់អ៊ីម៉ែលហ្នឹងហើយ បកស្រាយតាមការយល់ឃើញរបស់ខ្លួន។ ហើយបើអ៊ីចឹង យើងយល់ឃើញថាឯកសារដែលយើងចង់បង្ហាញនេះ វាស្ថិតនៅក្នុង

វិសាលភាពនៃសវនាការនេះ។ ក៏ប៉ុន្តែបើតាមមើលទៅអង្គជំនុំជម្រះមិនមានគោលជំហរដូចយើង មិនយល់ឃើញដូចយើងនេះទេ។

អ៊ីចឹងអង្គជំនុំជម្រះបានលើកឡើងអម្បាញ់មិញហើយថា មិនចង់ឲ្យយើងលើកឡើងពីឯកសារដែលនិយាយពីដល់កម្រិតតំណែងលោក ខៀវ សំផន នៅលើនោះទេ។ ហើយលោក ខៀវ សំផន បានឲ្យយោបល់ខ្ញុំថា មិនបាច់បន្តបង្ហាញឯកសារទៀតទេ បើសិនអង្គជំនុំជម្រះយល់ឃើញថា ឯកសារដែលយើងចង់បង្ហាញនេះ ដើម្បីការពារគាត់ហ្នឹង ឬក៏ដើម្បីពន្យល់ពីគោលជំហររបស់លោក ខៀវ សំផន នោះ មិន -- អង្គជំនុំជម្រះមិនអាចទទួលយកបាននោះ។ អ៊ីចឹងគឺមានតែបញ្ឈប់ការបង្ហាញឯកសារនេះត្រឹមណេះតែប៉ុណ្ណោះឯងសម្រាប់ក្រុមយើង លោកប្រធាន។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៩:៥៦]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងលោកចង់និយាយតែអំពីតួនាទីរបស់ ខៀវ សំផន ទេតើមេធាវីការពារក្តី? ប្រសិនបើខ្ញុំយល់មិនខុសទេ គឺលោកចង់ ខ្ញុំព្យាយាមវិភាគទៅលើអ្វីដែលលោកបាននិយាយ។ អ៊ីចឹងលោកចង់បង្ហាញអំពីតួនាទីរបស់ជនជាប់ចោទ អ៊ីចឹងមែនទេ? គឺថាវាមានផ្នែកពាក់ព័ន្ធតែទៅលើតួនាទីរបស់ជនជាប់ចោទ តើអ៊ីចឹងមែនទេ? គ្រាន់តែឆ្លើយថា បាទ ឬក៏មិនមែន?--

**លោក អាកទួរ វែកកែន៖**

ភាគី -- ផ្នែកដែលពាក់ព័ន្ធនោះគឺថា ខ្ញុំចង់ -- អ្វីដែលខ្ញុំចង់ពន្យល់ជូនអង្គតុលាការអម្បាញ់មិញនោះ គឺថាគោលបំណងរបស់យើង គឺចង់បង្ហាញទស្សនវិស័យ។ បាទគឺចង់បង្ហាញទស្សនវិស័យនៃទ្រឹស្តីហើយក៏ដូចជាការអនុវត្ត ទាក់ទងទៅនឹងសហករណ៍ ហើយនិងមន្ទីរសន្តិសុខដែលជាកម្មវត្ថុនៃសវនាការនេះ។ អ៊ីចឹងយើងចង់គ្រាន់តែនិយាយប៉ុណ្ណឹងទេ មិននិយាយដល់តួនាទីលោក ខៀវ សំផន អីនោះទេ ពីព្រោះថាខ្ញុំចង់អានទង់បដិវត្ត ដែលយើងទាំងអស់គ្នាយល់ស្របគ្នាហើយ ថាវាជាលទ្ធិ ឬបណ្តុំឯកសារលទ្ធិនៃរបបខ្មែរក្រហមនេះ។ អ៊ីចឹងជាការសំខាន់ណាស់ ក្នុងការយល់ថាតើទ្រឹស្តីផ្ទៃក្នុងនៃអំណាចខ្មែរក្រហមនោះ ខ្មែរក្រហមដែលទាក់ទងទៅនឹងសហករណ៍ ឬប្រជាជន ហើយទាក់ទងចំណុចមួយចំនួននោះ វាយ៉ាងណា មុននឹងចូលនិយាយព័ត៌មានលម្អិត។ ឥឡូវនេះពេល១ម៉ោង១៥នាទីហើយដែលយើងនៅតែមិនទៅមុខ នៅតែមានការជំទាស់ទៅមកអ៊ីចឹងរហូត។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៤៣:០៥]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះអង្គជំនុំជម្រះអនុញ្ញាត។ ការពិតអង្គជំនុំជម្រះមិនយល់អំពីការបកស្រាយរបស់មេធាវីការពារក្ដីលោក ខៀវ សំផន ទេពាក់ព័ន្ធនឹងបញ្ហានេះ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយអង្គជំនុំជម្រះអនុញ្ញាតឲ្យលោកមេធាវីដាក់បង្ហាញឯកសារ ដែលលោកមានបំណងបង្ហាញនៅពេលនេះបាន។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ហើយជាការបន្ថែម គឺយើងនឹងពិភាក្សាទៅតាមករណីជាក់ស្ដែង ព្រោះថាឥឡូវនេះយើងមិនយល់ថាតើលោកចង់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងផ្នែកសវនាការនេះ ឬក៏អត់។ ហើយនៅពេលដែលលោកធ្វើការបង្ហាញ បង្ហាញបណ្ដើរយើងនឹងពិចារណាសម្រេចបណ្ដើរទៅតាមស្ថានភាពជាក់ស្ដែង។

**លោក អាកទួរ វែកគែន៖**

ខ្ញុំមិនអាចធ្វើការតាមករណីអ៊ីចឹងទេ ក្នុងលក្ខខណ្ឌនេះពិបាកណាស់។ ខ្ញុំផ្ញើឯកសារខ្ញុំចង់ពីរសប្ដាហ៍ ហើយ មិនមានអ្នកណាធ្វើការកត់សម្គាល់ ហើយប្រាប់ខ្ញុំថា មិនអាចធ្វើអ៊ីចឹងបានទេ។ អ៊ីចឹងខ្ញុំត្រូវបង្ហាញឯកសារ យើងគ្រាន់តែចំណាយពេល១ម៉ោង១៥នាទី ហើយគ្រាន់តែដើម្បីនិយាយគ្នាអំពីតែពាក្យថា "មិនមានអ្នកណាជំទាស់ទេ" ប៉ុន្តែខាតពេលដល់១ម៉ោង១៥នាទីហើយ។ ខ្ញុំសោកស្ដាយដែរ ថាការងើបឡើងនិយាយម្ដងទៀត ហើយក្រោយមកមានគេជំទាស់ទៀតអីទៀតនេះ ខ្ញុំមើលទៅឃើញថាដល់ពេលណាមួយនោះវា អ៊ីចឹងមើលទៅឃើញថា កែវទឹកវាចង់ហៀរទៅហើយ។ បើសិនពេលមានបង្ហាញបន្តិចចេះតែមានការពិភាក្សាគ្នារហូត ដេញដោលរហូត ហើយមិនអាចទទួលយកបានអីនោះ ខ្ញុំមិនដឹង ថាបន្តបង្ហាញឯកសារយ៉ាងម៉េចទេ។

[១៤:៤៥:០៧]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី វែកគែន លោកចង់បង្ហាញឯកសារ ឬក៏យ៉ាងម៉េច? យើងផ្ដល់វេទិកាឲ្យ លោកទៅនិយាយ -- អង្គជំនុំជម្រះផ្ដល់លទ្ធភាពឲ្យហើយៗ ហើយលោកមានកាតព្វកិច្ចត្រូវធ្វើ ឬក៏លោកថា ឬក៏លោកមិនចង់ធ្វើ?

**លោក អាកទូរ វែកកែន៖**

ខ្ញុំនឹងព្យាយាមធ្វើ។ បាទ ទាក់ទង -- ចុះចំនួនម៉ោងដែលខាតប៉ុន្មាននោះ គិតយ៉ាងណាដែរ?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកមេធាវី លោកមានពេលវេលាគ្រប់គ្រាន់ហើយ ខ្ញុំគិតថា លោកមិនបានត្រៀមលក្ខណៈការងាររបស់ខ្លួនឯងបានត្រឹមត្រូវ។ អានេះ វាជារឿងរបស់លោកទេ។

[១៤:៤៥:៥១]

**លោក អាកទូរ វែកកែន៖**

លោកចៅក្រម លោកកំពុងតែអំពីនិយាយអ្វី?

**ប្រធានអង្គជំនុំ៖**

លោក វែកកែន សូមអញ្ជើញ ហើយលោកបំពេញការងាររបស់លោកទៅ។ ឥឡូវហ្នឹង អង្គជំនុំជម្រះផ្តល់វេទិកាឲ្យ ហើយប្រសិនបើលោកមានការខ្វះពេលវេលា អង្គជំនុំជម្រះនឹងបន្ថែមពេលវេលាសមស្របសម្រាប់លោកធ្វើការងារនេះ។ លោកនៅមានពេលវេលាពេញ១ម៉ោង១៥នាទី ពីនេះទៅរហូតដល់ម៉ោងបួន។ ទំនងជាប្រើប្រាស់ពេលវេលាហ្នឹងមិនអស់ទេ តាមយើងប៉ាន់ស្មាន។

**លោក អាកទូរ វែកកែន៖**

លោកប្រធាន រយៈពេលដែលសល់នេះមិនគ្រប់គ្រាន់ទេ លោកប្រធាន។ ពេលដែលឮនិយាយថា ខ្ញុំមិនបានត្រៀមលក្ខណៈគ្រប់គ្រាន់ ខ្ញុំផ្តល់ឯកសារជាមុនឲ្យភាគីហើយៗនោះ។ ហើយឥឡូវនេះ គេបំផ្លាញពេលវេលាខ្ញុំ ១ម៉ោង១៥នាទីហើយ ហើយក្រោយមកមានគេចោទប្រកាន់ថា ខ្ញុំមិនបានធ្វើត្រៀមលក្ខណៈគ្រប់គ្រាន់ទៀតនោះ។ ខ្ញុំគិតថា គួរតែឲ្យភាគីទាំងអស់ត្រឡប់ទៅផ្ទះវិញទៅ ល្អជាង។

[១៤:៤៧:០០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះយល់ហើយថា គាត់មិនមានសមត្ថភាព និងលទ្ធភាពក្នុងការបំពេញការងារក្នុងឋានៈជាមេធាវីការពារក្តីទេ ព្រោះអង្គជំនុំជម្រះផ្តល់វេទិកាឲ្យលោកហើយ គឺគាត់មិនបំពេញធ្វើទេ ទោះបីពេលវេលា ទាំងពេលវេលាដែលយើងសន្មតថា សន្យាថានឹងបន្ថែមឲ្យក្នុងករណីចាំបាច់ ទោះបីធ្វើថ្ងៃស្អែកក៏យើងធ្វើដែរ ប៉ុន្តែលោកនៅតែមានះមិនបំពេញភារកិច្ចទេ ដូច្នេះអង្គជំនុំជម្រះសន្មតថា គាត់មិនមានលទ្ធភាព និងមិនបានរៀបចំកិច្ចការនេះសម្រាប់ធ្វើដាក់បង្ហាញ ពាក់ព័ន្ធនឹងឯកសារគន្លឹះ ពាក់ព័ន្ធ

ជាមួយនឹងមន្ទីរសន្តិសុខក្រាំងតាចាន់ និងសហករណ៍ត្រាំកក់ទេ។

ហេតុដូច្នេះ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។

លោក -- អញ្ជើញលោក ខៀវ សំផន! ហើយទំនងលោកផ្លាស់ប្តូរជំហរពីនៅស្ងៀមមិនឆ្លើយមកឆ្លើយតបហើយ តាមមើល? ចាំលោកឆ្លើយបញ្ជាក់សំណួរនេះផង។

[១៤:៤៨:០៣]

**លោក ខៀវ សំផន៖**

ថ្ងៃដំបូងហើយ ថាខ្ញុំសូមប្រើសិទ្ធិនៅស្ងៀមស្ងាត់ ក៏ប៉ុន្តែសុំឲ្យឱកាសពេលណាដែលខ្ញុំត្រូវបញ្ជាក់ខ្ញុំសូមឱកាសបញ្ជាក់ ហើយខ្ញុំសូមឱកាសបញ្ជាក់ លោកមេធាវី -- អ៎ លោកប្រធានបានអនុញ្ញាតឲ្យខ្ញុំខ្ញុំបញ្ជាក់។ ខ្ញុំប្រើសិទ្ធិខ្ញុំប៉ុណ្ណឹង។ ឥឡូវនេះ ដែលខ្ញុំចង់និយាយ គឺថាមិនមែនមេធាវីខ្ញុំអត់សមត្ថភាពរៀបចំទេ។ ខ្ញុំចង់និយាយអ៊ីចឹង។ រៀបចំហើយ ប៉ុន្តែវាមានការរំខានរអាក់រអួលអ៊ីចឹង។ ខ្ញុំ--

**ប្រធានអង្គជំនុំ៖**

យើងបានផ្តល់ពេលវេលាឲ្យគាត់ហើយ។ អង្គុយចុះ ខៀវ សំផន!

ហ្នឹងជាសិទ្ធិរបស់លោកទេ។ សិទ្ធិរបស់យើងអនុវត្តសិទ្ធិអង្គជំនុំជម្រះ។

អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃព្រហស្បតិ៍ ទី៣០ ខែមេសា ឆ្នាំ២០១៥ ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅសូមភាគីជ្រាប និងអញ្ជើញចូលរួមតាមកាលវេលាដែលបានកំណត់នេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន និងលោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនពួកគាត់ត្រឡប់មកចូលរួមសវនាការវិញ នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី៣០ ខែមេសា ឆ្នាំ២០១៥ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៤:៤៩ នាទី)*